# ក្រមសីលធម៌

# នៃអាកប្បកិរិយាសិស្ស

## Code Of Student Conduct

## សំរាប់ឆ្នាំសិក្សា ២០០៧-២០០៨

## For the School Year 2007-2008

## ក្រសួងអប់រំធីក្រុងហ្វីឡាដែលហ្វីយ៉ា

## School District of Philadelphia

# ក្រសួងអប់រំក្រុងហ្វីឡាដែលហ្វីយ៉ា

## គណៈកម្មាធិការកែទំរង់សាលារៀន

Sandra Dungee Glenn
ប្រធាន

សមាជិក

Denise McGregor Armbrister
Martin G. Bednarek
James P. Gallagher, Ph.D

Tom M. Brady
ប្រធានអគ្គនាយកបណ្ដោះអាសន្ននៃក្រសួងអប់រំ

Claudia Averette
នាយកមន្ទីររដ្ឋបាលកណ្ដាល

Gregory E.Thornton, Ed.D.
ប្រធាននាយកនៃការសិក្សា

# មាតិការឿង

**ផ្នែកទីមួយ៖ សេចក្តីផ្តើម**

១.១ ការបញ្ជាក់ពីគោលនយោបាយ........................................................................................១
១.២ គោលបំណងរបស់ក្រមសីលធម៌......................................................................................១
១.៣ ទំហំនៃក្រមសីលធម៌...................................................................................................១
១.៤ ការប្រកាសពីការមានឱកាសស្មើគ្នា.................................................................................២
១.៥ សេចក្តីបញ្ជាក់អំពីជំនួយផ្នែកភាសា.................................................................................២
១.៦ សន្ទានុក្រមនៃប្រជុំស័ព្ទបច្ចេកទេស.................................................................................២

**ផ្នែកទីពីរ៖ សិទ្ធិ និងការទទួលខុសត្រូវរបស់សិស្សនិងមាតាបិតាសិស្ស**.............................................៤

២.១ ការទទួលខុសត្រូវរបស់សិស្ស........................................................................................៤
២.២ សិទ្ធិរបស់សិស្សានុសិស្ស............................................................................................៤
២.៣ ការទទួលខុសត្រូវរបស់មាតាបិតា និងអណាព្យាបាលសិស្ស.....................................................៤
២.៤ សិទ្ធិរបស់មាតាបិតា/អណាព្យាបាលសិស្ស.........................................................................៥
២.៥ សិទ្ធិរបស់ជនរងគ្រោះ ក្នុងសាលារៀនដែលជាប់ទាក់ទងជាមួយនឹងការបំពាន.................................៥

**ផ្នែកទីបី៖ ការប្រព្រឹត្តបទល្មើសរបស់សិស្ស និងផលវិបាក**..................................................................៦

**៣.១. វិន័យកម្រិត ទី ១** ...............................................................................................................៦

**វិន័យទី ១.** ការហាមមិនឲ្យមានការរំខានដល់សាលារៀន..........................................................៦
**វិន័យទី ២.** ការប្រព្រឹត្តតាមក្រមសីលធម៌នៃការស្លៀកពាក់.........................................................៦
**វិន័យទី ៣.** ការហាមមិនឲ្យប្រើពណ៌ និងនិម្មិត្តសញ្ញានៃក្រុមអ្នកលេង(Gang)...................................៧
**វិន័យទី ៤.** ការហាមមិនឲ្យប្រើភាសាកំរោលវាយប្រហារគ្នា......................................................៧
**វិន័យទី ៥.** កំណត់លើបទបញ្ញានៃភាពថ្លៃថ្នូរ និងភាពទៀងត្រង់ក្នុងការសិក្សា.....................................៧
**វិន័យទី ៦.** ការបំពានលើបុព្វសិទ្ធិនៃការប្រើកុមព្យូទ័រ និងអ៊ិនធឺរណេត...............................................៧
**វិន័យទី ៧.** ការហាមមិនឲ្យបំផ្លិចបំផ្លាញ និងលួចទ្រព្យសម្បត្តិ.......................................................៨
**វិន័យទី ៨.** ការហាមមិនឲ្យលេងល្បែងស៊ីសង.......................................................................៨
**វិន័យទី ៩.** ការហាមមិនឲ្យប្រព្រឹត្តអំពើឃោរឃៅប្រកបដោយគ្រោះថ្នាក់..........................................៨
**វិន័យទី ១០.** ការហាមមិនឲ្យគំរាមកំហែងគ្នា.........................................................................៨
**វិន័យទី ១១.** ការហាមមិនឲ្យវាយតប់គ្នា..............................................................................៨
**វិន័យទី ១២.** ការហាមមិនឲ្យបំពានរំខានគ្នាណាមួយ................................................................៨
**វិន័យទី ១៣.** ការហាមមិនឲ្យបញ្ចេញភាពអាសអាភាស និងការប៉ះពាល់មិនសមរម្យ.................................៨
**វិន័យទី ១៤.** ការហាមមិនឲ្យប្រើប្រាស់ផលិតផលថ្នាំជក់ និងParaphemalia.......................................៩
**វិន័យទី ១៥.** ការហាមមិនឲ្យប្រើប្រាស់គ្រឿងញៀន ឬគ្រឿងស្រវឹងផ្ទាល់ខ្លួន.........................................៩

**៣.២. វិន័យកម្រិត ទី ២** ...............................................................................................................៩

**វិន័យទី ១៦.** ការប្រព្រឹត្តបំពានដដែលៗនៅសាលារៀន................................................................៩
**វិន័យទី ១៧.** ការហាមមិនឲ្យបំផ្លិចបំផ្លាញ និងលួចទ្រព្យសម្បត្តិ.......................................................៩
**វិន័យទី ១៨.** ការហាមមិនឲ្យបំពានដោយកម្លាំង និងគំរាមដោយធ្ងន់ធ្ងរ............................................៩
**វិន័យទី ១៩.** ការហាមមិនឲ្យមានការរំខានគ្នាទៅវិញទៅមកក្នុងផ្លូវភេទ..........................................១០

វិន័យទី ២០. ការហាមមិនឲ្យរួមភេទដោយស្ម័គ្រចិត្ត..........១០
វិន័យទី ២១ ការហាមមិនឲ្យរួមភេទដោយបំពាន..........១០
វិន័យទី ២២. ការហាមមិនឲ្យវាយតប់បុគ្គលិកសាលា..........១០
វិន័យទី ២៣. ការហាមមិនឲ្យជំរុញការវាយតប់ធ្ងន់ធ្ងរ..........១០
វិន័យទី ២៤. ការហាមមិនឲ្យលួចប្លន់..........១០
វិន័យទី ២៥. ការហាមមិនឲ្យមានអាវុធ..........១០
វិន័យទី ២៦. ការហាមមិនឲ្យចែកចាយគ្រឿងញៀន ឬគ្រឿងស្រវឹង..........១០
វិន័យទី ២៧. ការហាមមិនឲ្យដាក់ជនណាម្នាក់ក្នុងស្ថានភាពគ្រោះថ្នាក់..........១០
៣.៣ វិធីផ្តល់ជំនួយដល់សិស្ស..........១១
៣.៤ អន្តរាគមន៏/ការឆ្លើយតបដោយសមស្របអំពីបទល្មើសលើក្រមសីលធម៏ របស់សិស្ស ពីថ្នាក់មត្តេយ្យដល់ទី៤..........១១
៣.៥ អន្តរាគមន៏/ការឆ្លើយតបដោយសមស្របអំពីបទល្មើសលើក្រមសីលធម៏ របស់សិស្សថ្នាក់ទី៥ដល់ទី១២..........១៩
**ផ្នែកទីបួន៖ វិធីរៀបរាប់ពីវិន័យ**..........២៧
៤.១ វិធីរៀបរាប់អំពីការព្យួរទោសមិនឲ្យរៀនចំនួនបីថ្ងៃឬតិចជាង..........២៧
៤.២ វិធីរៀបរាប់អំពីការព្យួរទោសមិនឲ្យរៀនចំនួនបីថ្ងៃឬច្រើនជាង..........២៧
៤.៣ វិធីរៀបរាប់អំពីការប្តូរសាលាសំរាប់សិស្ស ពីថ្នាក់មត្តេយ្យទៅថ្នាក់ទី៤..........២៧
៤.៤ វិធីរៀបរាប់អំពីការប្តូរទៅសាលាដ៏ទៃទៀត សំរាប់សិស្សពីថ្នាក់ទី៥ដល់ទី១២..........២៨
៤.៥ វិធីរៀបរាប់អំពីការដេញសិស្សចេញពីសាលារៀន..........២៨
៤.៦ វិធីរៀបរាប់អំពីវិន័យសំរាប់សិស្សសិក្សាពិសេស..........២៨
៤.៧ ផលវិបាកនៃយុត្តិធ៏មយុវវ័យ និងយុត្តិធ៏មឧក្រិដ្ឋកម្ម សំរាប់ការបំពានទៅលើក្រមសីលធ៏មនៃអាកប្បកិរិយាសិស្ស..........៣០
៤.៨ វិធីរៀបរាប់សំរាប់សិស្សដែលត្រឡប់មកពីការទទួលចាត់តាំងពីតុលាការ..........៣១
**ផ្នែកទីប្រាំ៖ ការផ្តើមបន្ថយការឈប់ឥតច្បាប់**..........៣១
៥.១ ជំនួយដល់សេចក្តីការពារកុំឲ្យមានការឈប់ឥតច្បាប់(ATIPS)1
និងភ្នាក់ងារមាតាបិតាផ្នែកសិស្សឈប់ឥតច្បាប់(PTO)..........៣១
៥.២ កម្មវិធីបោសសំអាតនៃការឈប់ឥតច្បាប់(Truancy Sweep Program)..........៣១
៥.៣ មជ្ឈមណ្ឌលនៃការឈប់ឥតច្បាប់..........៣២
**ផ្នែកទីប្រាំមួយ៖ គោលនយោបាយ**..........៣២
៦.១ នយោបាយមិនប្រកាន់ និងមិនរំខានយាយី..........៣២
៦.២ នយោបាយនៃការត៉វា/ពាក្យបណ្តឹង..........៣២
៦.៣ នយោបាយនៃការឆែកឆេរកូនទូដាក់ឥ៉វ៉ាន់នៅសាលារៀន..........៣៤
៦.៤ ឯកសាររបស់សិស្ស..........៣៤
៦.៥ នយោបាយនៃការរក្សាទុកប៊ីពីរ, ទូរស័ព្ទដៃ និងគ្រឿងទូរស័ព្ទផ្សេងៗ..........៣៤
៦.៦ នយោបាយនៃការបញ្ចេញបង្ហាញខ្លួនរបស់សិស្ស..........៣៤
**ផ្នែកទីប្រាំពីរ. លេខទូរស័ព្ទដែលត្រូវយកមកប្រើជាញឹកញាប់**..........៣៥

# ផ្នែកទីមួយ . សេចក្តីផ្តើម

## ១.១. ការបញ្ជាក់ពីគោលនយោបាយ៖

ក្រសួងអប់រំក្រុងហ្វីឡាដែលហ្វីយ៉ា បាន និងកំពុងតែកសាងនូវបរិដ្ឋានមួយ ប្រកបដោយសុខសុវត្ថិភាព និងវិជ្ជមានសំរាប់សិស្សានុសិស្ស,បុគ្គលិកសិក្សា,មាតាបិតា និងសហគមន៏ជាដៃគូរបស់យើងទាំងអស់។ ក្រសួងនឹងធ្វើការ ដើម្បីបញ្ជាក់ឲ្យប្រាកដថា សិស្សានុសិស្ស និងបុគ្គលិកសិក្សាយើង នឹងទទួលការសប្បាយរីករាយ, ហើយដឹងដោយច្បាស់លាស់នូវឋាមពល និងការឧទ្ទិសរបស់សិស្សទៅក្នុងរយៈពេលដ៏វែងនៃជីវិតសិក្សា ឲ្យក្លាយជាមនុស្សជាតិដែលមានសមត្ថភាព និងប្រកបដោយការស្ថាបនា។ ស្រួងអប់រំក្រុងជឿជាក់ថា សិស្សានុសិស្សទាំងអស់ អាចរៀនសូត្រក្នុងបរិដ្ឋានដ៏សុខសុវត្ថិភាពមួយ។ ក្រសួងអប់រំបានប្រើប្រាសនូវវិសាលភាពនៃសកម្មភាពនានា ដើម្បីទទួលស្គាល់ និងរៀបចំពិធី ព្រមទាំងផ្តល់រង្វាន់ដល់អាកប្បកិរិយាជាវិជ្ជមាននៅក្នុងបន្ទប់រៀន, សាលារៀន, និងទូទាំងទីក្រុង។

ជាមួយនឹងក្រមសីលធម៏នៃអាកប្បកិរិយាសិស្ស, ក្រសួងមានគោលនយោបាយទូលំទូលាយ ដើម្បីដឹកនាំសីលចរិយាធម៏នៅក្នុងក្រុង។ ការចំលងមួយច្បាប់នៃគោលនយោបាយនោះ អាចនឹងបោះពុម្ពយកចេញពីគេហទំព័រ www.phila.k12.pa.us/offices/ofeles ឬក៏មន្ទីរទំនាក់ទំនងនៃអប់រំក្រុងតាមលេខ ២១៥-៤០០-៤០០០។

ជាមួយនឹងកិច្ចសន្យាសំរាប់ម្នាក់ៗទៅលើក្រមសីលធម៏នេះ, យើងនឹងអាចកសាងបាន នូវបរិដ្ឋានសិក្សាមួយដ៏សមស្របនៅក្នុងទីក្រុង។ ដើម្បីសុំការចំលងមួយច្បាប់សំរាប់ភាសាដែលមិនមែនជាភាសាអង់គ្លេស, សូមទាក់ទងទៅមន្ទីរទំនាក់ទំនង (Office of Communications) តាមលេខ២១៥-៤០០-៤០៤០។

## ១.២ គោលបំណងរបស់ក្រមសីលធម៏៖

ក្រសួងអប់រំក្រុងបានសំរេចយកក្រមសីលធម៏នេះ ដើម្បីជួយឧបត្ថម្ភដល់ការកសាងនូវបរិដ្ឋានរៀនសូត្រមួយដ៏សុខសុវត្ថិភាពសំរាប់សមាជិកម្នាក់ៗនៃសាលារៀនក្នុងសហគមន៏។ គោលបំណងនេះ គឺបញ្ជាក់ឲ្យបានច្បាស់ នូវកំរិតស្តង់ដាក្នុងការទទួលបាននៃអាកប្បកិរិយារបស់សិស្ស។ ជាមួយនេះដែរ, ក្រមសីលធម៏នេះបានពន្យល់អំពីផលវិបាកនៃការអនុវត្តន៏ ដែលមិនអាចឈានដល់កំរិតស្តង់ដា នៃអាកប្បកិរិយារបស់សិស្សនេះ។ ក្រមសីលធម៏បានបង្កើតឡើង ដោយមានគោលនយោបាយ គ្មានការអនុគ្រោះ(អត់អោន)ឡើយសំរាប់អាកប្បកិរិយាដែលបង្កើតឲ្យមានគ្រោះថ្នាក់ដល់សុខសុវត្ថិភាពបរិដ្ឋាននៃសាលារៀន និង/ឬក៏រំខានដល់បទពិសោធន៏នៃការអប់រំរបស់សិស្សដ៏ទៃទៀត។

ជាមួយគ្នានេះដែរ, ក្រមសីលធម៏បានរៀបចំជាស្រេច នូវរបៀបរបបវិន័យនានា សំរាប់សិស្សដែលបានប្រព្រឹត្តបំពានលើក្រមសីលធម៏។ ក្រមសីលធម៏នេះ មិនមែនមានន័យថាជាកិច្ចសន្យារវាងក្រសួងអប់រំក្រុង និងសិស្សានុសិស្សឡើយ ហើយអាចនឹងត្រូវធ្វើវិសោធនៈកម្មនៅពេលណាមួយក៏បាន។ ក្រមសីលធម៏នេះ គឺជាកន្លែងដែលក្រសួងអប់រំក្រុងពន្យល់ ពីគោលនយោបាយពិតនានា សំរាប់ឲ្យសិស្សអនុវត្តតាម។ ក្រសួងអប់រំក្រុងហ្វីឡាដែហ្វីយ៉ាមិនអនុញ្ញាត្តិឲ្យមាន "វិធីដាក់ទណ្ឌកម្មលើរាងកាយ" (Corporal punishment) ឡើយ។

**១.៣. ទំហំនៃក្រមសីលធម៏៖** ក្រមសីលធម៏ អនុវត្តលើអាកប្បកិរិយាណាមួយដែលបានកើតឡើងៈ

ក-នៅក្នុងសាលារៀន នៅពេលណាមួយ។

ខ-ក្រៅទីធ្លាសាលារៀននៅក្នុងសកម្មភាព(អំពើ)នានា, ដំណើរការ, ឬក៏ព្រឹត្តិការណ៏របស់សាលារៀន។

គ-ក្រៅពីទីធ្លាសារៀននៅពេលដែលអាកប្បកិរិយាអាចនឹងកើតឡើងដោយសមស្រប (១)ធ្វើឲ្យអន្តរាយដល់អាជ្ញាវិន័យរបស់សាលា, (២)ធ្វើឲ្យមានគ្រោះថ្នាក់ដល់សុខសុវត្ថិភាពនៃសមាជិករបស់សាលារៀនក្នុងសហគមន៏, (៣)រំខានដល់សាលារៀន និង

ឃ-នៅពេលដើរទៅ និងមកពីសាលារៀន, ក៏ប៉ុន្តែនឹងបន្ថែមដោយមិនមានកំណត់ ទៅលើអំពើនានា ដែលកើតឡើងនៅលើរថយន្តដឹកសិស្សរបស់សាលា, រថយន្ត, ឬក៏ការដឹកជញ្ជូនសាធារណៈផងដែរ។

## ១.៤. ការប្រកាសពីការមានឱកាសស្មើគ្នា៖

ក្រសួងអប់រំក្រុង អនុវត្តតាមច្បាប់នៃសហព័ន្ធ, រដ្ឋ, និងមូលដ្ឋាន ហើយបានផ្តល់នូវសមធម៌(ភាពស្មើគ្នា) សំរាប់សិស្សទាំងអស់។ ក្រសួងបានហាមឃាត់ដល់ការប្រកាន់ជាតិសាសន៏ក្នុងការអនុញ្ញាត្តិឲ្យចូល, ការឲ្យពិន្ទុ, វិន័យ, ឬក៏សកម្មភាពផ្សេងៗទៀត ដែលមានមូលដ្ឋានពី ពូជសាសន៍ លទ្ធិ ព៌ណសម្បុរ សញ្ជាតិដើម សាសនា បុព្វការីជន អាយុ ក្របខ័ណ្ឌរៀបការ ភាពតំរង់តាមភេទ (ដឹង ឬយល់ឃើញ) ការបញ្ចេញពីសញ្ញាណភាពខាងភេទ (ដឹង ឬយល់ឃើញ) ភេទ ពិការភាព សញ្ជាតិ ឬក៏ភាពជាពលរដ្ឋ។ គ្រប់ការសំរេចទាំងអស់របស់ក្រសួងនឹងត្រូវគ្រប់គ្រងដឹកនាំ ដោយមិនគិតទៅលើផ្នែកនានា នៃបញ្ជីរាយឈ្មោះខាងលើនោះឡើយ។ សិស្សនិងមាតាបិតាសិស្ស ដែលមានភាសាកំណើតរបស់ខ្លួន មិនមែនជាភាសាអង់គ្លេស មានសិទ្ធិទទួលយកសេវាកម្មនៃភាសាវិវត្តន៏ និងការបកប្រែជូនដោយមិនមានគិតថ្លៃ។ ក្រសួងអប់រំក្រុង តំរូវឲ្យមានការជូនពត៏មានទៅដល់សិស្ស និងសមាជិកគ្រួសារ អំពីសិទ្ធិនៃការទទួលយកភាសានេះ។ផ្អែកទៅលើច្បាប់ជាចាំបាច់នៃសហរដ្ឋ, រដ្ឋ, និងមូលដ្ឋាន, ក្រសួងអប់រំមានកាតព្វកិច្ច ផ្តល់នូវលទ្ធភាពនៃសេវាកម្មកម្មភាសា ដោយឆ្លងកាត់បុគ្គលិកដែលមានគុណសម្បត្តិគ្រប់គ្រាន់។ បើសិនជាសេវាកម្មនេះត្រូវបានសុំ, ក្រសួងអប់រំក្រុងត្រូវតែផ្តល់នូវសេវាកម្មនេះ ដើម្បីធ្វើឲ្យច្បាស់ថាបុគ្គលិកដែលមានគុណសម្បត្តិគ្រប់គ្រាន់ ត្រូវផ្តល់សេវាកម្មនោះ។

## ១.៥. សេចក្តីបញ្ជាក់អំពីជំនួយផ្នែកភាសា

សិស្សនិងមាតាបិតា ដែលនិយាយភាសាកំណើតផ្សេងពីភាសាអង់គ្លេស មានសិទ្ធិសុំឲ្យមានការបកប្រែ ដោយមិនបាច់បង់ថ្លៃ។ ក្រសួងត្រូវប្រាប់ទៅសិស្ស និងមាតាបិតាទាំងអស់ អំពីជំនួក្នុងការបកប្រែនេះ។

យោងទៅតាមច្បាប់របស់ក្រុង, រដ្ឋ និងសហរដ្ឋ, ក្រសួងត្រូវមានផ្តល់អ្នកជំនួយផ្នែកភាសា ដែលមានសមត្ថភាពត្រឹមត្រូវ។ ក្រសួងត្រូវផ្តល់ជំនួយផ្នែកភាសាប្រកបដោយគុណភាពប្រសើរបំផុត បើសិនជាមានសេចក្តីត្រូវការពីសិស្ស និងមាតាបិតា។

## ១.៦. សន្ទានុក្រមនៃប្រជុំស័ព្ទបច្ចេកទេស៖

១.៦.១ <u>ការដាក់ឲ្យរៀននៅជំរើសសាលា</u>៖ មានន័យថាសាលារៀន ឬកម្មវិធីដែលសង្កត់ធ្ងន់ទៅលើការកែលំអនូវអាកប្បកិរិយា, ការមកសាលារៀន, និងការសិក្សារបស់សិស្ស។

១.៦.២ <u>ទង្វើពិនិត្យឡើងវិញនូវអាកប្បកិរិយា</u>៖ គឺជាការពិនិត្យឡើងវិញនៃការសិក្សា និងការរីកចំរើនផ្នែកអាកប្បកិរិយារបស់សិស្ស។

១.៦.៣ <u>ការសំឡុត ឬធ្វើបាប</u>៖ មានន័យថាបង្ករក្នុងអាកប្បកិរិយាដែលបង្ការ ឬក៏មិនលើកទឹកចិត្តសិស្សដ៏ទៃទៀត ឲ្យចូលរួមក្នុងការអនុវត្តន៏សិទ្ធិរបស់ពួកគេក្នុងការសិក្សា។ ការសំឡុត ឬធ្វើបាប គឺការធ្វើឲ្យមានការឈឺចាប់ម្តងហើយម្តងទៀត ក្នុងកំលុងពេលមួយរយៈ នៅក្នុងទំនាក់ទំនងមួយ រវាងជនដែលមានកម្លាំងពុំស្មើគ្នា (យោងទៅតាម ភេទ, រាងកាយ ឬកម្លាំងផ្នែកខួរក្បាល, ការទទួលផ្នែកសង្គម ជាដើម)។ អាកប្បកិរិយាហាមឃាត់បែបនេះ នឹងរាប់បញ្ចូលនូវការប្រើការគំរាមកំហែង, បង្ខិតបង្ខំ, ឬក៏បង្ខំឲ្យប្រឆាំងនឹងសិស្ស, បុគ្គលិកសិក្សា, ឬអ្នកមកទស្សនាសាលារៀន ឬក៏មិនរាប់បញ្ចូលជនណាមួយដោយយោងទៅលើ រូបរាងកាយ, ចិត្ត, ភេទ ឬតាមអ៊ិនធ័រណេត។

១.៦.៤ <u>ក្រមសីលធម៌</u>៖ នោះមានន័យថា គឺជាក្រមសីលធម៌នៃអាកប្បកិរិយាសិស្ស, ជាក្បួន ឬច្បាប់ទូន្មានសំរាប់សិស្ស។

១.៦.៥ <u>ទំរង់បែបបទនៃជំនួយឧបត្ថម្ភសិស្សដ៏ទូលំទូលាយឬក៏CSAP</u>៖ មានន័យថា ទំរង់ការជួយឧបត្ថម្ភជាចាំបាច់ដល់សិស្សពីថ្នាក់មត្តេយ្យដល់ទី១២។ ទំរង់ជំនួយនោះ នឹងលៃទុកសំរាប់អត្តសញ្ញាណភាព, អន្តរាគមន៏ និងតាមដានបន្តការសិក្សារបស់សិស្ស ដែលមានបទពិសោធន៏ នៃការលំបាកក្នុងការសិក្សារៀនសូត្រ។

១.៦.៦ <u>ទណ្ឌកម្មលើរាងកាយ</u>៖ មានន័យថា ដាក់ទណ្ឌកម្មដោយផ្លូវកាយដល់សិស្ស ដែលធ្វើបំពានដល់ក្រមសីលធម៌។ ទណ្ឌកម្មនេះមិនបានរួមបញ្ចូលការប្រើកំលាំងរបស់គ្រូ និងរដ្ឋបាលសាលារៀនឡើយ (១)បង្ក្រាបការរំខាននានា, (២)មានអាវុធឬវត្ថុដ៏មានគ្រោះថ្នាក់ដ៏ទៃទៀត, (៣)សំរាប់វត្ថុបំណងនៃការការពារខ្លួនឯង, ឬក៏(៤)សំរាប់ការការពារមនុស្សនានាឬក៏ទ្រព្យសម្បត្តិ។

១.៦.៧ <u>ពិការភាព</u>៖ មានន័យថាភាពអន់ថយនៃកាយ និងចិត្ត ដែលក៏រិតដោយត្រឹមត្រូវទៅលើធាតុមួយ ឬក៏ច្រើននៃសកម្មភាពជីវិតភាគច្រើនរបស់បុគ្គលម្នាក់ៗ, ឯកសារនៃភាពអន់ថយ, ឬក៏ត្រូវបានមើលឃើញថាមានភាពអន់ថយ, ឬក៏វិកលភាពជាក់ស្តែងដូចជាពហុវិកលភាព

(មានវិកលកម្មច្រើន), austism, វិកលកម្មខាងបញ្ញា, វិកលភាពក្នុងការសិក្សាជាក់លាក់, ភាពអន់ខ្សោយក្នុងការឮ, ភាពអន់ថយខាងនិយាយ/ភាសា, ភាពអន់ថយខាងគំហើញ, មានវិបល្លាសផ្នែកអារម្មណ៍, ភាពអន់ថយខាងការកែលំអរូបកាយ, ការប៉ះទង្គិចនាំឲ្យរបួសខួរក្បាល, និងភាពអន់ថយនៃសុខភាពដ៏ទៃទៀត។

១.៦.៨ ទីក្រុង៖ មានន័យថា ក្រសួងអប់រំក្រុងហ្វីឡាដែលហ្វីយ៉ា។

១.៦.៩ EH-21 Form៖ គឺជាគំរូពាក្យសុំ ដែលប្រើដោយក្រសួងអប់រំក្រុងក្នុងការទុកជាឯកសារនូវឧប្បត្តិហេតុ និងមតិយោបល់អនុសាសន៏ (មូលវិចារណ៏) ក្នុងការផ្លាស់ចេញដោយលក្ខ័ណវិន័យ។

១.៦.១០ ការបណ្តេញចេញ៖ គឺជាការដកសិស្សចេញពីសាលារៀនច្រើនជាង១០ថ្ងៃ, ព្រោះសិស្សបានប្រព្រឹត្តបំពានលើសីលក្រម។

១.៥.១១ ក្រុមអ្នកលេង៖ គឺជាអង្គការ ឬក្រុមដ៏រស់រវើករបស់ប្រជាជន ដែលបានបើកបង្ហាញឈ្មោះ ឬក៏ការបញ្ជាក់ពីសញ្ញា ឬនិមិត្តរូប ឬសមាជិកនោះ បានចូលរួមជាបុគ្គល ឬជាសមូហភាព ឬក៏បានចូលរួមក្នុងគំរូនៃសកម្មភាព ដែលបានធ្វើឲ្យមានគ្រោះថ្នាក់ ឬក៏រំខានដល់សុខសុវត្ថិភាពនៃសាលារៀន ឬក៏សមាជិកទាំងឡាយនៃសាលារៀនរបស់សហគមន៏។

១.៦.១២ “IEP ”៖ គឺជាគំរោងការអប់រំបុគ្គលផ្ទាល់ ដើម្បីជួយឧបត្ថម្ភដល់សិស្ស ដែលមានវិកលភាព ហើយដែលតំរូវឲ្យមានការរៀបចំជាពិសេស សំរាប់ការសិក្សាដែលជាប់ទាក់ទងទៅសេវាកម្ម។

១.៦.១៣ “ការព្យួរ ឬផ្អាកការសិក្សានៅសាលារៀន” គឺជាមធ្យោបាយវិន័យ ដែលអនុញ្ញាត្តិឲ្យសិស្សមកសាលារៀន, ប៉ុន្តែហាមឃាត់ពួកគេមិនចូលរូមក្នុងថ្នាក់រៀនធម្មតា។

១.៦.១៤ “ការសំដែងការកំណត់” មានន័យថា ការពិនិត្យមើលឡើងវិញនូវកម្មវិធីនៃការអបរំពិសេសរបស់សិស្ស ហើយវិកលភាពត្រូវបានកំណត់ បើសិនជាការប្រព្រឹត្តអាកប្បកិរិយាខុស ដែលបានជាប់ទាក់ទងនឹងវិកលភាពនោះ។

១.៦. ១៥ “សមាជិកនៃសាលារៀនសហគមន៏ ”គឺមានន័យថាសិស្ស, មាតាបិតា, លោកគ្រូ, មន្ត្រីសាលារៀន, ឬក៏បុគ្គលិកនៃសាលាក្នុងក្រុង ឬក៏អ្នកមកទស្សនានៅសាលាណាមួយ។

១.៦.១៦ “NOREP ”មានន័យថា គឺជាការជូនពត៏មាននៃមូលវិចារណ៏ ដើម្បីរៀបចំកន្លែងក្នុងការអប់រំ។ ការជូនពត៏មាននេះគួរតែបង្ហាញមាតាបិតា/អាណាព្យាបាលនៃសិស្ស ដែលមានវិកលភាព ហើយគួរតែសង្ខេបកម្មវិធីនោះ សំរាប់អប់រំកូន។

១.៦.១៧ “ការមាន” មានន័យថា គ្រប់គ្រងលើទ្រព្យសម្បត្តិ (ទោះបីបាត់, រកឃើញ, ឬក៏ត្រូវគេលួច) ដូចជាសំលៀកបំពាក់, កូនទូដាក់របស់របរនៅសាលា, ឬក៏កាតាប និងរបស់របរដែលមាននៅខាងក្នុង។

១.៦.១៨ “កម្មវិធីSMART” មានន័យថាកម្មវិធីដ៏ទូលំទូលាយមួយសំរាប់ព្រឹកថ្ងៃសៅរ៏។ កម្មវិធីបានផ្តល់ឲ្យសិស្សនូវការកសាងលក្ខណៈសម្ប័ត្តិ, និងមុខជំនាញខាងដំណោះស្រាយទំនាស់, ក៏ដូចជាការបង្ការ, អន្តរាគមន៏, ការបញ្ជូន, និងសេវាជំនួយសំរាប់គ្រឿងស្រវឹង, និងថ្នាំញៀនដែលពាក់ព័ន្ធនឹងបញ្ហា ហើយនិងការប្រព្រឹត្តខុសជាទូទៅ។

១.៦.១៩ “នៅសាលារៀន” មានន័យថា កម្មសិទ្ធិណាដែលប្រើប្រាស់ដោយក្រសួងអប់រំ ឬក៏កម្មសិទ្ធិណាដែលប្រើប្រាស់ដោយពាណិជ្ជករណាមួយ នៅក្រោមកិច្ចសន្យារបស់ក្រសួងអប់រំក្រុង។

១.៦.២០ “បុព្វសិទ្ធិរបស់សាលារៀន” មានន័យថា សកម្មភាព ឬកម្មវិធីដែលជាប់ទាក់ទងនឹងសាលារៀន, រាប់បញ្ចូល ក៏ប៉ុន្តែបន្ថែមដោយមិនមានកំណត់ទៅលើពិធីបញ្ចប់ការសិក្សា, ដំណើរកំសាន្តរបស់ថ្នាក់រៀន, របាំ, ក្រុមកីឡា, ក្លឹប ឬការសំរាកផងដែរ។

១.៦.២១ “ការយល់ព្រមនៃសេវាកម្ម” ជាការតំរូវតាមសេចក្តីត្រូវការសិស្សពិសេស ដែលអាចចូលក្នុងកម្មវិធី ឬបរិដ្ឋាននៃសាលារៀន។

១.៦.២២ ការមានរបួសលើរូបកាយដ៏ធ្ងន់ធ្ងរ មានន័យថារបួសរូបកាយដែលបង្កើតឡើង ដោយភាពប្រថុយប្រថានដល់ស្លាប់ដ៏ខ្លាំងក្លា ឬដែលបណ្តាលឲ្យមានការខូចរូបកាយធ្ងន់ធ្ងរនិងអចិន្ត្រៃយ៏, ឬក៏បាត់បង់, ឬក៏ខូចខាតដល់ដំណើរការនៃរូបកាយរបស់សមាជិកណាម្នាក់ ឬក៏គ្រឿងខាងក្នុងណាមួយ។

១.៦.២៣ “SRC” មានន័យថា គណកម្មាធិការកែទំរង់សាលារៀន

១.៦.២៤ “ការព្យួរ ឬផ្អាកការរៀនសូត្រ”មានន័យថា គឺជាការយកចេញដោយស្ម័គ្រចិត្ត នៃសិស្សពីបន្ទប់រៀន ឬសាលារៀនសំរាប់រយះពេល១០ថ្ងៃ ឬតិចជាង។

១.៦.២៥ “ហាមមិនឲ្យចូល” គឺជាច្រកសាលារៀន ដែលត្រូវហាមមិនឲ្យចូល។

១.៦.២៦ “អាវុធ” ជារបស់របរដូចតទៅ ប៉ុន្តែបន្ថែមដោយមិនមានកំណត់, កាំបិត, ប្រដាប់កាត់របស់របរ, ប្រដាប់កាត់ឧបករណ៍, កាំបិតស្លា, គ្រឿងផ្ទុះ, កាំភ្លើងបាញ់, កាំភ្លើងវែង, កន្ត្រៃនិងឧបករណ៍ដ៏ទៃទៀត, ឧបករណ៍ ឬវត្ថុដែលប្រើ និងមានបំណងយកទៅប្រើ ដើម្បីឲ្យមានការឈឺចាប់របួសដល់រាងកាយនៃសមាជិកដ៏ទៃទៀតក្នុងសហគមន៍សាលារៀន។ និយមន័យនេះរួមបញ្ចូល តែមិនមានកំរិតក្នុងការប្រើប្រាស់ ឬក៏មានបំណងក្នុងការប្រើប្រាស់ ដូចជាកំប៉ុងបាញ់ម្ទេស (Pepper Spray), Laser Pointer, ប្រដាប់ឡេស័រ, គ្រឿងទេស ដែលធ្វើឲ្យមានរបួសដល់សមាជិកក្នុងសហគមន៍សាលារៀនផងដែរ។

## ផ្នែកទីពីរ៖ សិទ្ធិ និង ការទទួលខុសត្រូវរបស់សិស្ស និងមាតាបិតា

**២.១ ការទទួលខុសត្រូវរបស់សិស្ស៖** សិស្សានុសិស្សទាំងអស់ គួរតែចូលរួមចែករំលែកគ្នា នូវការទទួលខុសត្រូវជាមួយរដ្ឋបាលរបស់សាលារៀន ព្រមទាំងបុគ្គលិកសិក្សានិងលោកគ្រូអ្នកគ្រូ ដើម្បីពង្រីក និងបណ្តុះនូវបរិដ្ឋានសុខសុវត្ថិភាព នៃការរៀនសូត្រនៅក្នុងសាលារៀន។ សិស្សគួរតែមានការទទួលខុសត្រូវដូចខាងក្រោមនេះ :

២.១.១ មកសាលារៀនឲ្យបានទាន់ពេលវេលា និងជារៀងរាល់ថ្ងៃ។

២.១.២ យកចិត្តទុកដាក់ ដោយការខំប្រឹងប្រែងធ្វើកិច្ចការក្នុងថ្នាក់រៀន និងលំហាត់ធ្វើនៅផ្ទះ។

២.១.៣ ត្រូវដឹងនឹងចេះ និងអនុលោមទៅតាមបទវិធាន និងបទបញ្ជារបស់សាលារៀន, ហើយអនុវត្ត(ប្រព្រឹត្ត)តាមច្បាប់។

២.១.៤ ត្រូវស្លៀកពាក់ ដោយអនុលោមទៅតាមច្បាប់នៃសំលៀកបំពាក់ និងផ្នែកទី៣។

២.១. ៥ ហាមមិនឲ្យប្រើភាសាឥតសីលធម៌ជាមនុស្ស, ពាក្យអាសអាភាស, និងភាសាអាក្រក់អាក្រីឡើយ។

២.១.៦ បង្ហាញនូវភាពជាកីឡាករ នៅពេលមកសាលារៀន និងនៅពេលជាប់ពាក់ព័ន្ធជាមួយព្រឹត្តិការណ៍នានា។

២.១.៧ រាយការការណ៍នូវឧប្បត្តិហេតុ ឬសកម្មភាពនានា ដែលអាចគំរាម ឬក៏រំខានដល់បរិដ្ឋានរបស់សាលារៀន ទៅបុគ្គលិកសិក្សា **ឬក៏ទូរស័ព្ទលេខទូរស័ព្ទសុខសុវត្ថិភាពផ្ទាល់ តាមលេខ 215-400-SAFE (7233)។**

**២.២ សិទ្ធិរបស់សិស្សានុសិស្ស៖**

២.២.១ សិស្សពីអាយុ៦ឆ្នាំដល់២១ឆ្នាំ ត្រូវទទួលការអប់រំសិក្សា ដោយសមរម្យ និងឥតគិតថ្លៃ។

២.២.២ មិនអាច មិនឲ្យសិស្សចូលរៀនសាលាសាធារណៈ ឬសាលាបុព្វសិទ្ធិ ពីព្រោះសិស្សបានរៀបការ, មានផ្ទៃពោះ, ពិការភាព ទទួលជំនួយក្នុងកម្មវិធី ឬការអប់រំពិសេស ឬក៏បណ្តាលមកពីជាតិសាសន៏, ភេទ, សាសនា, មុខសញ្ញានៃការរួមភេទ (ដឹងឬទទួលបាន), ការបង្ហាញនូវគំនិតអារម្មណ៍ពីអត្តសញ្ញាណរបស់ភេទ (ដឹងឬបានទទួលបាន) ឬក៏សញ្ជាតិដើម។

២.២.៣ មិនអាចទទួល ទណ្ឌកម្មលើរាងកាយ, និង

២.២.៤ ធ្វើតាមរបៀបរបបវិន័យ ដែលមានចែងក្នុងផ្នែកទី៤។

២.២.៥ អាចស្នើ និងទទួលជំនួយក្នុងការបកប្រែ ចំពោះបញ្ហាទាក់ទងទៅសាលារៀន បើសិនអង់គ្លេសមិនមែនជាភាសាទីមួយ។

**២.៣ ការទទួលខុសត្រូវរបស់មាតាបិតា និងអណាព្យាបាលសិស្ស៖** មាតាបិតា/អណាព្យាបាល មានការទទួលការខុសត្រូវដូចខាងក្រោមនេះ៖

២.២.១ ពិនិត្យឲ្យប្រាកដថា កូនរបស់លោកអ្នក ដែលមានអាយុពី៨ទៅ១៧ឆ្នាំ បានចុះឈ្មោះចូលរៀន ហើយទៅរៀនដោយទៀងទាត់, ទាន់ពេលវេលា និងនៅពេញមួយថ្ងៃ យោងតាមច្បាប់រដ្ឋពិនស៊ីលវ៉េនីញ៉ា។ **បើសិនជាកូនលោកអ្នក បានចូលរៀនមុនអាយុ៨ឆ្នាំ កូននោះនឹងក្លាយជាសិស្សមានអាយុមកសាលារៀន ដោយជាក់លាក់ ហើយត្រូវបន្តមកសាលារៀន ។**

២.៣.២ ពិនិត្យឲ្យប្រាកដប្រជាថា កូនលោកអ្នកដែលមានអាយុតិចជាង៨ឆ្នាំ ប៉ុន្តែបានចុះឈ្មោះចូលរៀននៅសាលារៀន មកសាលាជាទៀងទាត់ និងទាន់ពេលវេលា ព្រមទាំងនៅក្នុងសាលាមួយថ្ងៃពេញ, នេះផ្អែកទៅលើច្បាប់របស់រដ្ឋពិនស៊ីវ៉េនីញ៉ា។

២.២.៣ ចុះឈ្មោះកូនក្នុងសាលាក្រៅពីសាលាសាធារណៈ៖ នៅពេលណាដែលកូននោះត្រូវបានដេញចេញពីសាលាសាធារណៈ។

២.២.៤ ជូនពត៌មាន និងផ្តល់នូវតឹកតាង ទៅក្រសួងអប់រំក្រុងចំនួន៣០ថ្ងៃ បន្ទាប់ពីថ្ងៃដែលត្រូវបណ្តេញចេញ, បើសិនជាគេមិនអាចផ្តល់នូវកន្លែងក្នុងសាលា ដែលមិនមែនជាសាលារបស់ក្រុង...។

២.៣.៥ បង្ហាញទៅមន្ត្រីរបស់សាលារៀន នូវកង្វល់ណាមួយ ឬក៏តវ៉ាក្នុងការស្នើមស្ងាត់, ឥរិយាបទសមស្រប។

២.៣.៦ ធ្វើការជាមួយសាលារៀនអំពីប្រធានបទនៃការសិក្សា, វិន័យ ឬក៏បញ្ហាដ៏ទៃទៀត ដែលទាក់ទងជាមួយកូនលោកអ្នក។

២.៣.៧ រៀបផែនការពីពេលវេលា, ទីកន្លែងដើម្បីលំហាត់នៅផ្ទះ ហើយផ្តល់នូវការគយឃ្លាំជាចាំបាច់ដល់កូន។

២.៣.៨ និយាយជាមួយកូនលោកអ្នក អំពីសកម្មភាពនានា និងការប្រមើលមើលនៃអាកប្បកិរិយាកូន។

២.៣.៩ ដឹងពីវិធានបទ ដែលបានរៀបចំក្នុងក្រមសីលធម៌នេះ, ហើយមើលឡើងវិញ នូវបទវិធានទាំងនោះជាមួយកូនលោកអ្នក, ហើយ

២.២.១០ ឲ្យបានដឹងប្រាកដប្រជាថា កូនលោកអ្នកបានទទួលការពិនិត្យសុខភាព តាមដំណាក់កាលដែលតំរូវឡើងដោយច្បាប់។

## ២.៤ សិទ្ធិរបស់មាតាបិតា/អណាព្យាបាលសិស្ស៖ មាតាបិតា/អណាព្យាបាល គួរតែមានសិទ្ធិដូចខាងក្រោមនេះ៖

២.៤.១ ទទួលរបាយការណ៍ធម្មតាជាផ្លូវការ នៃការរីកចំរើនខាងការសិក្សារបស់កូនលោកអ្នក។

២.៤.២ ពិនិត្យ, ថតចំលង, និងជំទាស់ឲ្យបានសមស្រប ត្រឹមត្រូវ ទៅនឹងពត៌មានណា ដែលមាននៅក្នុងឯកសាររបស់កូនលោកអ្នក។

២.៤.៣ ទទួលនូវការពន្យល់ សំរាប់មូលដ្ឋាននៃថ្នាក់ដែលបានឲ្យ ដោយលោកគ្រូអ្នកគ្រូ។

២.៤.៤ ទទួលដោយភ្លាមៗ នូវរបាយការណ៍ ដែលបញ្ជាក់ពីកូនលោកអ្នកមកសាលាយឺត, ឬក៏អវត្តមានពីបន្ទប់រៀនមួយ ឬក៏បន្ទប់រៀនច្រើនទៀត។

២.៤.៥ សុំឲ្យមានជំនួបជាមួយគ្រូ/ ឬក៏នាយកសាលា។

២.៤.៦ ទទួលការបកប្រែ និង/ឬ ការសំរួលបកស្រាយភាសា ក្នុងលិខិតទំនាក់ទំនងនានា ចំពោះកូនលោកអ្នក និងការអប់រំរបស់គេ។

២.៤.៧ ទទួលនូវលិខិតឆ្លងឆ្លើយនានាជាភាសាដែលគ្រួសារចូលចិត្ត, បើភាសានោះមិនមែនជាភាសាអង់គ្លេស, ល្គឹគណាភាសានោះមិនមែនជាភាសាប្រើញឹកញាប់។ ក្នុងករណីនោះ ការបកប្រែភាសានិយាយដោយមាត់ នឹងត្រូវផ្តល់ជូន, និងធ្វើឡើងដោយបុគ្គលិកនិយាយភាសាពីរ ដែលមានគុណវឌ្ឍន៏។

២.៤.៨ ក្រសួងអប់រំក្រុងនឹងផ្តល់អ្នកបកប្រែ នៅពេលក្នុងអង្គប្រជុំ, បើសាលាយល់ថា មាតាបិតាឬក៏សិស្ស មិននិយាយភាសាអង់គ្លេសឬក៏មានការលំបាកក្នុងការនិយាយទាក់ទងជាភាសាអង់គ្លេស។

២.៤.៩ តវ៉ាទៅឧទ្ធរផ្នែកសកម្មភាពវិន័យ ដូចដែលមានផ្តល់ជូននៅផ្នែកទីបួន, និង..

២.៤.១០ ទទួលនូវការសំរបសំរួលសំរាប់ពិការភាពណា ដើម្បីមានលទ្ធភាពអាចចូលរួមក្នុងការអប់សំរាប់ពួកគេ ធ្វើយ៉ាងណាឲ្យតែមាតាបិតាទាំងអស់ ត្រូវបានអនុញ្ញាត្តិឲ្យចូលរួម ទៅតាមសំណូមពរសំរាប់ការសំរបសំរួល និងភាពចាំបាច់ខាងសុខភាព។

## ២.៥. សិទ្ធិរបស់ជនរងគ្រោះ នៅសាលារៀន ដែលជាប់ទាក់ទងនឹងការបំពាន៖

២.៥.១ សិស្សរងគ្រោះណាមួយ ដែលបានប្រព្រឹត្តក៏រិតទោសទី២ណាមួយ ក្នុងក្រមសិលធម៌នៃអាកប្បកិរិយាសិស្ស មានសិទ្ធិឡើងទៅឧទ្ធរក្នុងសវនាការវិន័យ ដើម្បីបង្ហាញភស្តុតាងអំពីព្រឹត្តិការពិតនៃឧប្បត្តិហេតុ ដូចដែលមានជាប់ពាក់ព័ន្ធជាមួយគេ។

២.៥.២ អ្នករងគ្រោះអាចនឹងទាក់ទងជាមួយ Safe School Advocate នៃនាយកដ្ឋានអប់រំតាមលេខ២១៥-៦៤៥-១២៧៧ ឬក៏ទូរស័ព្ទសុខសុវត្ថិភាពលេខ២១៥-៤០០-SAFE។

២.៥.៣ ជនរងគ្រោះ អាចនឹងដាក់ពាក្យបណ្តឹងថ្លែងនូវទុក្ខសោក ដោយអនុលោមទៅតាមរបៀបរបប (វិធីសាស្រ្ត) នៃទុក្ខសោករបស់សិស្សដូចដែលមានចែងក្នុងផ្នែកទីប្រាំមួយ។

២.៥.៣ សិស្សរងគ្រោះ អាចនឹងដាក់ពាក្យបណ្តឹងសម្តែងសារទុក្ខ ដោយអនុលោមទៅតាម វិធីសាស្រ្តនៃសារទុក្ខរបស់ស្រួងអប់រំដូចមានពន្យល់ជូនក្នុងផ្នែកទី៦។

# ផ្នែកទី៣៖ ការប្រព្រឹត្តបទល្មើសរបស់សិស្ស និងផលវិបាក

ក្រមសីលធម៌ បានបែងចែកការប្រព្រឹត្តខុសជាពីរផ្នែក៖ (១)ទោសកំរិតទី១, (២)ទោសកំរិតទី២។ ក្រសួងអប់រំ នឹងបង្ខំដាក់នូវកំរិតទោសទាំងពីរនេះ ដែលបាននិយាយពីភាពធ្ងន់ធ្ងរនៃមធ្យោបាយ សំរាប់ធ្វើឲ្យបានគ្រាន់បើឡើង។ **ហួសពីនេះ, ទោសពិសេសដែលបានចាប់ផ្តើមនៅផ្នែកខាងក្រោម, ក្រសួងអប់រំក្រុងមានសិទ្ធិដាក់វិន័យលើសិស្ស ដែលបានប្រព្រឹត្តអាកប្បកិរិយា ដែលមិនមានចែងនៅខាងក្រោម, ដូចជាការគំរាមដល់សុខភាព, សុខសុវត្ថិភាព ឬផាសុកភាពរបស់អ្នកដទៃ ឬក៏រំខានដល់បរិដ្ឋាននៃការរៀនសូត្រ។** មធ្យោបាយសមស្របនឹងត្រូវកំណត់នៅលើឋាមពលតែមួយនៃការសំរេចរបស់ក្រសួងអប់រំ ដោយអនុលោមទៅតាមច្បាប់។

សិស្សមានសិទ្ធិធ្វើតាមរបៀបរបបនោះ ដែលបានចាប់ផ្តើមឡើងនៅក្នុងផ្នែកទី៤ ចំពោះមូលវិចារណ៏សំរាប់ការកែលំអនៃអំពើប្រព្រឹត្ត។

បើសិនជាសមាជិកនៃសាលាសហគមន៏មានសំនួរចំពោះក្រមសីលធម៌នេះ, អស់លោកអ្នក គួរទាក់ទងជាមួយការិយាល័យអន្តរៈកាល និងជំរើសនៃការអប់រំតាមលេខ២១៥-៤០០-៤២២០។ សំរាប់ឯកសារចំលងដែលក្រៅពីភាសាអង់គ្លេស, សូមទាក់ទងនឹងការិយាល័យទំនាក់ទំនងតាមលេខ ២១៥-៤០០-៤០៤០។

## ៣.១ វិន័យ កម្រិតទី ១

**វិន័យទី ១.** **ការហាមមិនឲ្យមានការរំខានដល់សាលារៀន៖** សិស្សគួរតែប្រព្រឹត្តនូវចរិយាថ្លៃថ្នូរជាពលរដ្ឋ ចំពោះសមាជិកនៃសាលាសហគមន៏ទាំងអស់ ហើយមិនត្រូវបង្អាក់រំខាននូវកម្មវិធីអប់រំណាមួយ ឬក៏កម្មវិធីដែលទាក់ទងនឹងសាលារៀន។ ការបំពានលើវិន័យនេះ នឹងត្រូវបូកបញ្ចូលប៉ុន្តែមិនមានកំណត់ទៅនឹង :

ក. ខកខានមិនគោរពការណែនាំពីនាយកសាលា, លោកគ្រូអ្នកគ្រូ និងបុគ្គលិកសិក្សាដ៏ទៃទៀត។

ខ. ខកខានមិនធ្វើតាមបទវិធានរបស់សាលារៀន។

គ. មាន ឬក៏ប្រើប៊ីពើរ(Beeper), ទូរស័ព្ទដៃ, Walkman, និងប្រដាប់ទូរស័ព្ទដ៏ទៃទៀតនៅក្នុងពេលម៉ោងសាលារៀន ឬកម្មវិធីអប់រំនានា។

ឃ. មានគ្រឿងទេស, pepper spray, ឬ ប្រដាប់ប្រើពន្លឺលេសឺរ។

ង. រត់ និង/ឬក៏ធ្វើឲ្យមានសំលេងយ៉ាងឮ នៅតាមផ្លូវក្នុងអាគារ និងក្នុងអាគារសិក្សា។

ច. ចូលតំបន់ហាមឃាត់, ត្រេតត្រត, និង/ឬក៏មិនបានផ្តល់នូវអត្តសញ្ញាណប័ណ្ណ នៅពេលដែលគេសុំមើល។

ឆ. ខកខានមិនបានចូលក្នុងថ្នាក់រៀន ដោយមិនមានលិខិតលើកលែងមានតំលៃណាមួយ។

ជ. ធ្វើឲ្យមានសំលេងអាសន្ន នៅពេលដែលមិនមានភាពអាសន្ននៃអគ្គីភ័យ។

ឈ. មកសាលានឹងថ្នាក់រៀន ដោយយឺតយ៉ាវមិនទាន់ពេល។

**វិន័យទី ២.** **ការប្រព្រឹត្តតាមក្រមសីលធម៌នៃការស្លៀកពាក់៖** សិស្សគួរតែស្លៀកពាក់ទៅតាមខ្នាតកំណត់ ដែលបានពិពណ៌នាដូចខាងក្រោម ហើយខ្នាតនោះបានចាប់ផ្តើមនៅក្នុងក្រមសីលធម៌នៃការស្លៀក ដែលសំរេចឡើងដោយសាលារៀន និងដែលត្រូវបានរៀបចំពណ៌ និងម៉ូតនៃសំលៀកបំពាក់សមរមសំរាប់សិស្សស្លៀកពាក់។

សិស្សបានបំពានលើវិន័យនេះ បើសិនពួកគេបាន៖

ក. ខកខានមិនបានស្លៀកពាក់ ទៅតាមពណ៌ឯកសណ្ឋានដែលបានកំណត់។

ខ. ខកខានមិនបានស្លៀកពាក់ តាមម៉ូតដែលកំណត់ឲ្យស្លៀកពាក់។
គ. ខកខានមិនបានស្លៀកពាក់ ឲ្យបានត្រឹមត្រូវតាមទំហំចង្កេះ ឬក៏មិនមានខ្សែក្រវ៉ាត់។
ឃ. ស្លៀកពាក់ខោអាវបញ្ច្រាសឡើងលើ(ស្លៀកពាក់ខាងខុស)។
ង. ពាក់អាវយឺតខាងខុស, ពាក់អាវបញ្ចេញសាច់ដុំ ឬអាវដែលមានខ្សែពីរបន្តោងពីលើ។
ច. ស្លៀកពាក់ដោយបង្ហាញខោអាវទ្រនាប់, ឬក៏Spaghetti strap (សរសៃក្រណាត់គ្របពីលើទ្រូង)។
ឆ. ពាក់មួកកន្តិប, ខ្សែចងក្បាល, ក្រណាត់រុំក្បាល ឬក៏មួក។

**វិន័យទី ៣.** **__ការហាមមិនឲ្យប្រើព៌ណ និង(និមិត្ត)សញ្ញារបស់ក្រុមអ្នកលេង៖__** សិស្សមិនគួរស្លៀកពាក់ពណ៌/សញ្ញារបស់ក្រុមអ្នកលេងទេ។ សិស្សដែលបានបំពានលើវិន័យនេះ, បើសិនជាពួកគេបាន៖

ក. ពាក់ពណ៌របស់ក្រុមអ្នកលេង ជាមួយនិងបំណងបង្ហាញ នូវសេចក្តីស្មោះចំពោះក្រុមនោះ។
ខ. ស្លៀកពាក់សំលៀកបំពាក់កីឡាវិមាណវត្ថុ (ខោអាវប្រចាំក្រុមកីឡាណាមួយ) ដោយមានបំណងបង្ហាញនូវភាពស្មោះត្រង់ចំពោះក្រុមនោះ។
គ. ស្លៀកពាក់ខោអាវណាដែលសរសេរអក្សរ ដោយបញ្ជាក់ន័យថាជានិមិត្តសញ្ញារបស់ក្រុមអ្នកលេងមួយ។

**វិន័យទី ៤.** **__ការហាមមិនឲ្យប្រើភាសាកំរោលវាយប្រហារគ្នា៖__** សិស្សមិនគួរប្រើភាសាកំរោលវាយប្រហារគ្នាទេ។ សិស្សបានបំពានលើវិន័យនេះ បើសិនជាគេបាន៖

ក. ជេរឬក៏ប្រើពាក្យចង្រៃសថ្លោស, ពាក្យអាសអាភាស, ឬក៏ភាសាកំរោលវាយប្រហារគ្នា ឬក៏
ខ. ផ្ញើ ឬបញ្ជូនសំនេរ, រូបភាព ឬក៏និមិត្តសញ្ញាពីប្រភពណាមួយ ដែលបង្កប់ដោយភាសាកំរោលវាយប្រហារគ្នា, ភាសាមុខសញ្ញាក្នុងបំណងផ្លូវភេទ ឬក៏គំរាមកំហែង ទៅកាន់សមាជិកដទៃទៀតនៃសាលារៀនសហគមន៍។

**វិន័យទី ៥.** **__ការកំណត់លើបទបញ្ញាំនៃភាពថ្លៃថ្នូរ និងទៀងត្រង់ក្នុងការសិក្សា៖__** សិស្សត្រូវបានសង្ឃឹមថានឹងពង្រឹងឲ្យបានខ្ពស់បំផុតនូវកំរិតខ្នាតនៃភាពទៀងត្រង់ ក្នុងការងាររបស់ពួកគេ។ សិស្សបានបំពានលើវិធាននេះ បើសិនជាពួកគេលួចបន្លំ, ចំលងការងារពីអ្នកដទៃ ការលួចចំលងពីអ្នកដទៃ ឬក៏បង្ខំយកកំណត់ការពីអ្នកដទៃ។ សិស្សលួចបន្លំនូវតែសសំរាប់វាស់កំរិតនៃការចេះដឹង ឬកំរិតពិន្ទុ ឬក៏ចំណាត់ថ្នាក់ និង/ឬក៏ឯកសារនៃការមកសាលារៀន នឹងត្រូវចាត់ទុកថាបានបំពានលើវិន័យទី២។

**វិន័យទី ៦.** **__ការបំពានលើបុព្វសិទ្ធិនៃការប្រើកុំព្យូទ័រ និងអ៊ិនធឺណេត៖__** សិស្សគួរគោរពនូវបុព្វសិទ្ធិរបស់កុំព្យូទ័រ ដែលបានផ្តល់ឲ្យពួកគេ។ សិស្សបានបំពានលើវិន័យនេះ បើសិនជាពួកគេបាន៖

ក. ឲ្យពាក្យសំងាត់របស់គេ ទៅអ្នកណាម្នាក់ ឬក៏បានប្រើនូវនូវលេខ ឬពាក្យរបស់បុគ្គលដទៃទៀត។
ខ. ចុះចំលងដោយខុសច្បាប់ នូវសំភារៈដែលមានការរក្សាសិទ្ធិចេញពីអ៊ិនធឺណេត។
គ. ចូលទៅកាន់គេហទំព័រណា ដែលមានសំភារៈនៃផ្លូវភេទយ៉ាងជាក់លាក់។
ឃ. ធ្វើឲ្យខូចឬបំផ្លិចបំផ្លាញឯកសាររបស់សិស្សម្នាក់ទៀត ឬរបស់មនុស្សម្នាក់ទៀត, អ៊ិនធឺណេត ឬក៏បណ្តាញការងារផ្សេងទៀត។
ង. បង្កើត, ចុះចំលង (download) ឬក៏ចុះបង្កើត (upload) មេរោគចម្លងរបស់កុំព្យូទ័រ, ឬក៏
ច. បំពានលើបទវិធានណាមួយ ដែលមាននៅក្នុងគោលនយោបាយ នៃការយល់ទទួលយកក្នុងការប្រើប្រាស់នៃក្រសួងអប់រំក្រុង ដែលអាចនឹងរកឃើញនៅលើគេហទំព័រ www.phila.k12.pa.us។

**វិន័យទី ៧.** <u>**ការហាមមិនឲ្យបំផ្លិចបំផ្លាញ និងលួចទ្រព្យសម្បត្តិ**</u>៖ សិស្សគួរតែគោរពដល់ទ្រព្យសម្បត្តិ ហើយមិនគួរធ្វើឲ្យខូច, បំផ្លិចបំផ្លាញ និងលួចយកទ្រព្យសម្បត្តិណាមួយឡើយ។ សិស្សបានបំពានលើលើបទវិធាននេះ, បើសិនជាគេបានធ្វើឲ្យខូច ឬក៏លួចទ្រព្យសម្បត្តិនោះ ក្នុងចំនួនមួយ ដែលមិនហួសពី១៥០ដុល្លារ ដោយ៖

ក. លាបពណ៌ ឬក៏គូសវាសផ្តេសផ្តាស (graffiti) នៅលើកម្មសិទ្ធិទ្រព្យសម្បត្តិ។

ខ. បណ្តាលឲ្យ ឬក៏មានគោលបំណង លួចទ្រព្យសម្បត្តិ។

គ. លួច ឬមានបំណងលួចទ្រព្យសម្បត្តិ នៅក្នុងសាលារៀន ឬក៏នៅក្នុងទីកន្លែងមួយដែលត្រូវធានា។

**វិន័យទី ៨.** <u>**ការហាមមិនឲ្យលេងល្បែងស៊ីសង**</u>៖ សិស្ស មិនគួររកកន្លែង ឬភ្នាល់ សំរាប់ផលប្រយោជន៏របស់ខ្លួនឡើយ។

**វិន័យទី ៩.** <u>**ការហាមមិនឲ្យប្រព្រឹត្តអំពើឃោរឃៅប្រកបដោយគ្រោះថ្នាក់**</u>៖ សិស្ស មិនគួរប្រព្រឹត្តក្នុងឥរិយាបទ ដែលធ្វើមិនដឹងមិនឮដល់សុខភាព, សុខសុវត្ថិភាព, ឬក៏ផាសុកភាពរបស់សមាជិកណាម្នាក់ ក្នុងសាលារៀនសហគមន៏ ដោយដាក់អ្នកនោះឲ្យស្ថិតក្នុងគ្រោះថ្នាក់នៃរបួស ឬឈឺចាប់ឡើយ។

**វិន័យទី ១០.** <u>**ការហាមមិនឲ្យគំរាមកំហែងគ្នា**</u>៖ សិស្ស មិនគួរទាក់ទងដោយផ្ទាល់ ឬដោយប្រយោលទៅនឹងការគំរាមកំហែងណាទៅលើសមាជិកដ៏ទៃទៀតនៃសាលារៀនសហគមន៏ ដែលបានដាក់អ្នកនោះ ឲ្យស្ថិតក្នុងការភ័យខ្លាចនៃការរបួស, ឈឺចាប់ ឬក៏ដើម្បីការលេងសើចឡើយ។ ការគំរាមដ៏ធ្ងន់ធ្ងរទៅដល់ជីវិត ឬក៏សុវត្ថិភាព នឹងត្រូវចាត់នៅក្នុងជំពូកនៃការបំពានលើ វិន័យទី២ (សូមអានវិន័យទី១៨, ការហាមឃាត់មិនឲ្យបំពានប្រើកំលាំង និងការគំរាមដ៏ធ្ងន់ធ្ងរ)។

**វិន័យទី ១១.** <u>**ការហាមមិនឲ្យវាយតប់គ្នា**</u>៖ សិស្ស គួរតែបន្ថយល្បឿនពីការដែលត្រូវទទួលការប្រឈមមុខដាក់គ្នាទៅវិញទៅមក ដោយពាក់ព័ន្ធទៅនឹងកំលាំងកាយ ជាមួយនិងសមាជិកទាំងឡាយ នៃសាលារៀនសហគមន៏។

**វិន័យទី ១២.** <u>**ការហាមមិនឲ្យបំពានរំខានគ្នាណាមួយ**</u>៖ សិស្ស មិនគួរបណ្តាលឲ្យ ឬក៏មានបំណងបណ្តាលឲ្យមានរបួសដល់រាងកាយនៃសិស្ស ឬអ្នកទស្សនាសាលារៀនឡើយ។ អំពើដែលធ្វើឲ្យមានរបួសដល់រូបកាយធ្ងន់ធ្ងរដែលតំរូវឲ្យមានការយកចិត្តទុកដាក់ពីវេជ្ជវិធី នឹងត្រូវចាត់ទុកថាបានបំពានលើវិន័យទី២ (សូមអានវិន័យទី២៣,ការហាមឃាត់មិនឲ្យវាយប្រតប់ធ្ងន់ធ្ងរ)។

**វិន័យទី ១៣.** <u>**ការហាមមិនឲ្យបញ្ចេញភាពអាសអាភាស និងការប៉ះពាល់មិនសមរម្យ**</u>៖ សិស្ស មិនគួរបង្ហាញនូវប្រដាប់បន្តពូជ ទៅសមាជិកណាម្នាក់នៃសាលាសហគមន៍ ឬក៏ប៉ះពាល់ដល់គ្រឿងបន្តពូជរបស់អ្នកដ៏ទៃ។ វិន័យនេះ បានបូកបញ្ចូលជាមួយនិងការប៉ះពាល់ដោយឧប្បត្តិហេតុ ដែលនៅទីនោះ សិស្សមិនមានបំណង ឬមិនមានចេតនា ក្នុងការយល់អំពីផលវិបាកនៃអាកប្បកិរិយារបស់គេ។ ការបំពានជារឿយៗទៅលើវិន័យនេះ នឹងត្រូវចាត់ទុកទៅក្នុងកំរិតទី២ នៃបទល្មើស (សូមអានវិន័យទី២១, ការហាមមិនឲ្យមានការបំពានដោយផ្លូវភេទ)។

បទល្មើសនៃវិន័យនេះ មិនបានបូលបញ្ចូលៈ

ក) ការបំពានដោយផ្លូវភេទ

ខ) ការរំខានដោយផ្លូវភេទ, ឬក៏

គ) ការប្រព្រឹត្តិខាងផ្លូវភេទ។

**វិន័យទី ១៤.** **ការហាមមិនឲ្យប្រើប្រាស់ផលិតផលថ្នាំជក់ និង Paraphernalia**៖ សិស្សមិនអាចមាន ឬប្រើផលិតផលថ្នាំជក់, ដែកកេះអុជបារី, ឈើគូស, ក្រដាសមូលបារី, ខ្សែ, ឬក៏របស់ដ៏ទៃទៀតដូចជា Paraphernalia ឡើយ។

**វិន័យទី ១៥.** **ការហាមមិនឲ្យប្រើប្រាស់គ្រឿងញៀន ឬគ្រឿងស្រវឹងផ្ទាល់ខ្លួន**៖ សិស្សមិនគួរមាន, ឬក៏ស្ថិតនៅក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង, ថ្នាំញៀន ឬក៏ថ្នាំដែលគ្មានការអនុញ្ញាត្តិបញ្ជាទិញពីវេជ្ជបណ្ឌិត, ឬក៏គ្មានលិខិតបញ្ជាទិញពីវេជ្ជបណ្ឌិត។ ការរំលោភជាលើកទី២នៃច្បាប់នេះ ត្រូវចាត់បញ្ចូលក្នុងបទល្មើសកំរិតទី២ ហើយទណ្ឌកម្ម នឹងត្រូវផ្អែកទៅលើច្បាប់នេះ។

សិស្សមិនបានបំពានលើវិន័យនេះទេ, បើសិនជាគេមានថ្នាំចេញដោយវេជ្ជបណ្ឌិត្យ ដែលមានអាជ្ញាប័ណ្ណចុះលើដបផ្តល់ឲ្យដោយឱសថការី, ដែលបង្ហាញពីឈ្មោះរបស់សិស្ស ឬក៏ថ្នាំដែលមិនមានលិខិតបញ្ជាពីវេជ្ជបណ្ឌិត្យ តែសិស្សគួរតែមានកំណត់ការពីមាតាបិតា ឬក៏វេជ្ជបណ្ឌិត្យ។ សិស្ស គួរតែមានថ្នាំគ្រប់គ្រាន់សំរាប់ប្រើមួយថ្ងៃ នៅថ្ងៃទៅសាលារៀន។

## ៣.២. វិន័យ កម្រិតទី ២

**វិន័យទី ១៦.** **ការប្រព្រឹត្តបំពានដដែលៗ នៅសាលារៀន**៖ សិស្សគ្រប់រូប មិនត្រូវប្រព្រឹត្តល្មើសជាច្រើនលើក ទៅលើ**កម្រិតទី១ នៃវិន័យ ទី ១, ៣, ៥-១៤**។ គេមិនអាចចាត់ទុកថាសិស្សបំពានវិន័យទាំងនេះបានទេ បើសិនជាសាលារៀន មិនបានធ្វើអន្តរាគមន៍ដោយជោគជ័យ ទៅលើការបំពានវិន័យទាំងនេះ។

**វិន័យទី ១៧.** **ការហាម មិនឲ្យបំផ្លាញ និងលួចទ្រព្យសម្បត្តិ**៖ សិស្សគ្រប់រូប ត្រូវគោរពដល់ទ្រព្យសម្បត្តិទាំងអស់ ហើយមិនត្រូវធ្វើឲ្យខូចខាត បំផ្លាញ ឬ លួចទ្រព្យសម្បត្តិទាំងនោះឡើយ។ សិស្សនឹងចាត់ទុកថាល្មើសវិន័យនេះ ប្រសិនបើបានធ្វើឲ្យខូចខាត ឬលួចទ្រព្យសម្បត្តិដែលមានតម្លៃ ១៥០ ដុល្លារ ឬច្រើនជាងនេះ ដោយបាន៖

ក. លាបពណ៌ ឬគូសវាសលើទ្រព្យសម្បត្តិ,

ខ. ធ្វើ ឬមានបំណងនឹងធ្វើឲ្យខូចខាតដល់ទ្រព្យសម្បត្តិ,

គ. លួច ឬមានបំណងនឹងលួចទ្រព្យសម្បត្តិ។

**វិន័យទី ១៨.** **ការហាមឃាត់ មិនឲ្យបំពានដោយកម្លាំង និងការគំរាមដោយធ្ងន់ធ្ងរ**៖ សិស្សគ្រប់រូប មិនត្រូវបំភ័យ ឬសម្លុតធ្វើបាបដល់សមាជិកណាម្នាក់ នៃសហគមន៍របស់សាលា។ សិស្សណាម្នាក់ដែលល្មើសវិន័យនេះ ប្រសិនបើសិស្សនោះ ប្រើកម្លាំងបាយ និយាយ សរសេរ ឬប្រើផ្លូវចិត្ត ក្នុងការធ្វើឲ្យមានការឈឺចាប់ ឬធ្វើឲ្យអាម៉ាសមុខ ដោយចេតនា ដល់សមាជិកណាម្នាក់នៅសាលារៀន។ ការល្មើសច្បាប់នេះ នឹងមានរួម ហើយមិនកំរិតត្រឹមតែ៖

ក. រាងកាយៈ វាយ, ទាត់ធាក់, រុញ, ច្រាន ប្រាប់ឲ្យអ្នកណាម្នាក់ធ្វើឲ្យមានការឈឺចាប់ដល់ជនណាម្នាក់ទៀត

ខ. និយាយៈ មើលងាយតាមពូជសាសន៍, ជេរ, ល, ផ្តន្ទា, សកសៀតលើផ្លូវភេទ, ចចាមអារាម, ផ្សាយពាក្យមិនពិត; ឬ

គ. ក្រៅពីប្រើពាក្យសម្តីៈ គំរាម, ឲ្យសញ្ញាមិនប្រពៃ, រុកឲ្យនៅម្នាក់ឯង, មិនឲ្យចូលរួម, តាមដាន, គំរាមកំហែងតាមអ៊ិនធឺរណិត (ការគំរាមកំហែងដែលធ្វើតាមគ្រឿងអេឡិកត្រូនិក ដូចជា អ៊ីម៉ែល, សារភ្លាមៗ, សារដោយសរសេរ, ប្លក, ទូរស័ព្ទដៃ, ទូរស័ព្ទ, ផេជីរ ឬវ៉ិបសៃត៍)។

**វិន័យទី ១៩.** **<u>ការហាម មិនឲ្យមានការរំខានគ្នាទៅវិញទៅមក ក្នុងផ្លូវភេទ</u>**៖ សិស្សគ្រប់រូប មិនត្រូវប៉ះពាល់កេរ្តិ៍ខ្មាស របស់សមាជិកណាម្នាក់ នៃសហគមន៍របស់សាលាឡើយ។

**វិន័យទី ២០.** **<u>ការហាម មិនឲ្យរួមភេទ ដោយស្ម័គ្រចិត្ត</u>**៖ សិស្សគ្រប់រូប មិនត្រូវព្រមព្រៀងប្រព្រឹត្តការរួមភេទណាមួយ (តាមមាត់ ឬ រួមរ័ក្ស) នៅក្នុងបរិវេណសាលា ឬ នៅគ្រប់សកម្មភាពទាំងឡាយ ដែលសាលាជាអ្នករៀបចំឡើង។

**វិន័យទី ២១.** **<u>ការហាម មិនឲ្យរួមភេទ ដោយបំពាន</u>**៖ សិស្សគ្រប់រូប មិនត្រូវបង្ខំ ឬប៉ងនឹងបង្ខំ សមាជិកណាម្នាក់នៃសហគមន៍របស់សាលា ដើម្បីរួមភេទឡើយ។ តាមវិន័យនេះ ការប្រព្រឹត្តដោយផ្លូវភេទ ត្រូវបូកបញ្ចូលជាមួយ ប៉ុន្តែមិនមានកំណត់ត្រឹមតែ:

ក) ការរួមភេទ;

ខ) ការរួមភេទ ដោយមាត់;

គ) ការរួមភេទជាក្រុម; ឬក៏

ឃ) ការរួមភេទ ដោយប្រើសម្ភារៈ

**វិន័យទី ២២.** **<u>ការហាម មិនឲ្យវាយតប់ បុគ្គលិកសាលា</u>**៖ សិស្សគ្រប់រូប មិនត្រូវមានចិត្ត ឬមានបំណង ធ្វើឲ្យគ្រោះថ្នាក់ ឬ ឈឺដល់រូបរាងកាយ បុគ្គលិករបស់សាលាឡើយ។

**វិន័យទី ២៣.** **<u>ការហាម មិនឲ្យជំរុញការវាយតប់ធ្ងន់ធ្ងរ</u>**៖ សិស្សគ្រប់រូប មិនត្រូវធ្វើឲ្យមាន ប៉ងធ្វើឲ្យមាន ឬសម្លុតគំរាម ធ្វើឲ្យមានគ្រោះថ្នាក់ ធ្ងន់ធ្ងរដល់រូបរាងកាយ របស់សិស្ស ឬភ្ញៀវណាម្នាក់ ដោយមាន ឬគ្មានអាវុធ ដែលមិនគិតពីតម្លៃនៃជីវិតរបស់មនុស្ស។

**វិន័យទី ២៤.** **<u>ការហាម មិនឲ្យលួចប្លន់</u>**៖ សិស្សគ្រប់រូប មិនត្រូវប្រើ ឬ មានបំណងប្រើកម្លាំង ដើម្បីលួច ឬ ប៉ងលួចទ្រព្យសម្បត្តិរបស់សមាជិក ណាម្នាក់ នៃសហគមន៍របស់សាលាឡើយ។

**វិន័យទី ២៥.** **<u>ការហាម មិនឲ្យមានអាវុធ</u>**៖ សិស្សគ្រប់រូប មិនត្រូវមានអាវុធគ្រប់ធុន ដូចបានបញ្ជាក់ប្រាប់នៅក្នុង **អក្ខរានុក្រម** នៃក្រមនេះ។ សិស្សនឹងចាត់ទុកថាល្មើសវិន័យនេះ ទោះបីជាសិស្សនោះ គ្មានបំណងយករបស់ទាំងនេះប្រើជាអាវុធក្តី។

**វិន័យទី ២៦.** **<u>ការហាម មិនឲ្យចែកចាយគ្រឿងញៀន ឬ គ្រឿងស្រវឹង</u>**៖ សិស្សគ្រប់រូប មិនត្រូវលក់ ឬចែកចាយ គ្រឿងញៀន គ្រឿងស្រវឹង ឬ ថ្នាំពេទ្យ ដែលតម្រូវឲ្យមានវេជ្ជបញ្ជា ឬ គ្មានវេជ្ជសញ្ញា; ឬក៏មានរបស់បែបនេះក្នុងខ្លួន ដែលអាចបញ្ជាក់ប្រាប់ថា ជារបស់សម្រាប់ចែកចាយ ហើយមិនមែនសំរាប់ការប្រើប្រាស់ខ្លួនឯងឡើយ។

**វិន័យទី ២៧.** **<u>ការហាម មិនឲ្យដាក់ជនណាម្នាក់ ក្នុងស្ថានភាពគ្រោះថ្នាក់</u>**៖ សិស្សគ្រប់រូប មិនត្រូវប្រព្រឹត្ត ឬមានបំណងប្រព្រឹត្តនូវគ្រប់ទង្វើ ដែលធ្វើឲ្យមានគ្រោះថ្នាក់ដល់ សុខភាព សន្តិសុខ ឬ សុខុមាលភាព របស់សមាជិកណាម្នាក់ នៃសហគមន៍របស់សាលា ឡើយ។ ការបំពានលើវិន័យនេះ ត្រូវបូកបញ្ចូលជាមួយ ប៉ុន្តែមិនកំណត់ត្រឹមតែ:

ក. ដុតភ្លើង នៅក្នុងបរិវេណសាលា

ខ. សងសឹក ទៅលើសមាជិកណាម្នាក់ នៃសហគមន៍របស់សាលា ដោយសារការរួមចំណែករបស់ជននោះ

ក្នុងការស៊ើបអង្កេតអ្វីមួយ ចាត់វិធានការបន្តក្នុងរឿងការសិក្សា ឬវិន័យ។

គ. ទាញកណ្ដឹងអគ្គិភ័យ ក្នុងពេលដែលគ្មានអាសន្នភ្លើងឆេះ ហើយស្ថានីយសង្គ្រោះអគ្គិភ័យបានបញ្ចេញសកម្មភាព ឬ សាលាបានជំលៀសមនុស្សចេញ ឬ

ឃ. សម្លុតគំរាម ក្នុងការគ្រោងដាក់គ្រាប់បែក ឬ គ្រឿងផ្ទុះដ៏ទៃទៀត។

## ៣.៣ វិធីផ្តល់ជំនួយដល់សិស្ស:

វិធីផ្តល់ជំនួយដល់សិស្ស (CSAP) នៃក្រសួងអប់រំក្រុងហ្វីឡាដែលហ្វីយ៉ា មានបីជាន់, គឺជាវិធីរួបរួមគ្នា ដែលសាលារៀនទាំងឡាយ បានចង្អុលប្រាប់ពីឧបសគ្គដល់ការសិក្សា និងការដកឧបសគ្គទាំងនេះចេញ ដោយធ្វើការឲ្យតំលៃខាងក្នុង និងខាងក្រៅ (សាលា) ព្រមទាំងមានជំនួយ ពីខាងក្រៅផង (សហគមន៍)។ ចំណុចសំខាន់របស់ CSAP គឺថ្នាក់រៀន, ដែលមានគ្រូបង្រៀនជាអ្នកវិភាគ ពីកម្លាំង និងសេចក្តីត្រូវការផ្នែកការសិក្សារបស់សិស្ស ហើយនិងការតាក់តែងមេរៀន និងបរិយាកាស ដើម្បីបង្កើតឲ្យមានការសិក្សាដ៏ល្អប្រសើរបំផុត។

## CSAP នៅតាមសាលារៀននានា:

វិធីជំនួយនិមួយៗ ត្រូវផ្តើមឡើង ដោយមានការបង្កើតសម័ន្ធជំនួយសំរាប់សិស្ស និងបុគ្គលិកសិក្សា ដែលនឹងមានផ្តល់លទ្ធផលនៅក្នុងតំបន់មួយដែលប្រកបទៅដោយសន្តិសុខ និងការសិក្សាដ៏ប្រសើរ។ នៅតាមសាលារៀន, ធាតុទាំងឡាយដែលបង្កើតឲ្យមានបរិយាកាសបែបនេះ គឺមានរួមទាំង តាំងពីការបង្កើតឲ្យមានការប៉ិនប្រសព្វបន្តទៅរវាងបុគ្គលិកសិក្សា និងសិស្សានុសិស្ស, ការចូលរួមរបស់គ្រួសារក្នុងការសិក្សា, គំរូនៃការរៀបចំអាកប្បកិរិយាមួយដែលមានចែងយ៉ាងច្បាស់ពីការអនុវត្តដោយម៉ឺងម៉ាត់ ហើយនិងការបង្កើតឲ្យមានសេចក្តីសំរេចចិត្តយោងទៅតាមស្ថិតិ។

## CSAP Tier ជាន់ទី១:

អន្តរាគមន៍ **Tier** ជាន់ទី១ បានបង្កើតឡើងទៅតាមសេចក្តីត្រូវការរបស់ក្រុមសិស្ស ដែលមានការពិសោធន៍ដូចគ្នាក្នុងបញ្ហារៀនសូត្រ។ នៅជាន់នេះ, គ្រូបង្រៀនជួបជាមួយសិស្សជាអចិន្ត្រៃយ៍ ជាមួយក្រុមសិស្ស ឬបុគ្គលិកសិក្សាដែលធ្វើការជាមួយគ្នា ដើម្បីចង្អុលបង្ហាញ និងអនុវត្តវិធានការណ៍ផ្សេងៗ នៅក្នុងថ្នាក់រៀន។ មេក្រុម ឬមេផ្នែកសិក្សា នឹងដឹកនាំអង្គប្រជុំនៃជាន់ទី១នេះ។

## CSAP Tier ជាន់ទី២:

ជួនកាលសិស្សម្នាក់ៗ មានការពិសោធន៍ផ្ទាល់ខ្លួន អំពីបញ្ហានៃការរៀនសូត្រ។ **Tier** ជាន់ទី២ បានបង្កើតឡើងដើម្បីជួយសិស្សម្នាក់ៗផ្ទាល់ខ្លួន។ នៅជាន់ទី២នេះ, ក្រុមឯកទេសយ៉ាងស្ទាត់ជំនាញ (គ្រូបង្រៀនដែលធ្វើសេចក្តីស្នើ, ខោនសីល័រ, និង/ឬគ្រូពេទ្យប្រចាំសាលា) នឹងធ្វើការរួមគ្នាជាមួយមាតាបិតា/អណាព្យាបាល នៅក្នុងអង្គប្រជុំ ដែលបានរៀបចំឡើងដោយខោនសីល័រ។ ក្រុមនេះ នឹងបង្កើតគំរោងអន្តរាគមន៍មួយ ដែលបានបង្កើតឡើងដើម្បីបញ្ជាក់ពីសេចក្តីត្រូវការរបស់សិស្ស និង/ឬគ្រួសាររបស់សិស្ស។ គំរោងនេះមានរួមទាំងជំនួយពីខាងសាលារៀន និងសហគមន៍, ហើយក្រុមនេះ អាចរួមបញ្ចូលសមាជិក (ចិត្តវិទូ, បុគ្គលិកមកពីសមាគម) ទៅតាមសេចក្តីត្រូវការ។

## CSAP Tier ជាន់ទី៣:

នៅ **Tier** ជាន់ទី៣, គោលសំខាន់បំផុតនៃការវាយតំលៃ គឺសំដៅទៅលើការផ្លាស់ប្តូរសំរាប់ក្មេង ដែលនៅតែរៀនមិនបានជោគជ័យ។ ការផ្លាស់ប្តូរនៃការចាត់តាំងនេះ នឹងធ្វើឡើង យោងទៅតាមការសិក្សា ឬអាកប្បកិរិយារបស់សិស្ស។ សមាជិកប្រចាំក្រុម, ឯកសារផ្សេងៗ និងពេលវេលា នឹងត្រូវរៀបចំឡើង ទៅតាមវិធីដែលមានចែងដោយក្រសួងអប់រំក្រុងហ្វីឡាដែលហ្វីយ៉ា និងរដ្ឋផិនស៊ីលវេនីញ៉ា។

## ៣.៤ អន្តរាគមន៍/ការឆ្លើយតបដោយសមស្រប អំពីបទល្មើសលើក្រមសីលធ៌ម របស់សិស្ស ពីថ្នាក់មត្តេយ្យ ដល់ថ្នាក់ទី៤

តារាងបន្តទៅនេះ គឺសម្រាប់រាយរាប់ប្រាប់អំពីការធ្វើអន្តរាគមន៍/ប្រតិកម្មតប ដោយសមរម្យ ដែលអាចយកទៅអនុវត្តដាច់ដោយឡែក ឬដោយរួមគ្នា ក្នុងការឆ្លើយតបទៅនឹងបទល្មើសណាមួយ។  ឧទាហរណ៍ សម្រាប់ការបំពានម្តងទៅលើ វិន័យទី១, សិស្សប្រហែលជាត្រូវបានតម្រូវឲ្យសរសេរអត្ថបទ នឹងសូមទោស ជួបជាមួយឪពុកម្តាយសិស្សនោះ នឹងចាត់ឲ្យមនុស្សពេញវ័យម្នាក់ជួយផ្តល់ឱវាទ។ **លើកលែងតែដូចការរៀបរាប់ខាងក្រោមនេះ នាយកសាលា អាចបង្គំឲ្យធ្វើអន្តរាគមន៍ផ្សេងទៀត ដែលគ្មានចែងក្នុងតារាងនេះ ដែលអាចចាត់ទុកថាជាការសមរម្យ ដោយនាយកសាលា។**

សូមកត់ចំណាំថា សិស្សណាដែលមានបង្ហាញការប្រព្រឹត្តជាញយៗ អំពីអាកប្បកិរិយាល្មើសច្បាប់ ត្រូវបញ្ជូនទៅក្រុម CSAP ដើម្បីឲ្យធ្វើអន្តរាគមន៍ តាម TIER ជាន់ទី១ (ជាក្រុម) ឬ TIER ជាន់ទី២ (ម្នាក់ៗ)។

| **វិន័យកម្រិត១ និងការធ្វើអន្តរាគមន៍<br>ថ្នាក់មត្តេយ្យ–ថ្នាក់ទី៤** | |
|---|---|
| **វិន័យ** | **អន្តរាគមន៍ក្នុងថ្នាក់រៀន** |
| **វិន័យទី ១៖ ការហាមឃាត់ មិនឲ្យរំខានដល់សាលា**<br><br>**សម្គាល់៖** ប្រសិនបើសិស្សណាម្នាក់មកសាលា ឬមកថ្នាក់មិនទាន់ពេល សិស្សនោះនឹងអាចមិនឲ្យចូលថ្នាក់ ក្នុងខណៈដែលសិស្សនោះមកថ្នាក់មិនទាន់ពេល ឬក៏ថ្នាក់កំពុងតែដំណើរការក្នុងពេលដែលសិស្សនោះមកដល់សាលា។ មិនត្រូវបញ្ជូនសិស្សទៅផ្ទះវិញ ពីព្រោះការមកមិនទាន់ពេលនោះទេ។ **មិនត្រូវពិន័យសិស្សមិនឲ្យមករៀន ពីព្រោះតែការមិនមករៀន ការមករៀនមិនទាន់ពេល ឬការគេចសាលានោះទេ។**<br>សិស្សដែលទៅរៀនយឺត ឬឈប់ជាញយៗ ត្រូវបញ្ជូនទៅក្រុម CSAP ដើម្បីឲ្យធ្វើអន្តរាគមន៍ តាម TIER ជាន់ទី១ (ជាក្រុម) ឬ TIER ជាន់ទី២ (ម្នាក់ៗ)។ | • ពិភាក្សាជាមួយសិស្សអំពី ហេតុការណ៍ដែលបានកើតឡើង។<br>• ប្រើវិធីអប់រំ/ឈ្លាសវៃ ក្នុងការធ្វើអន្តរាគមន៍ (ឧ. សិស្សសរសេរអត្ថបទ រៀបរាប់ពីបទល្មើស, ឪពុកម្តាយចុះអត្ថលេខាលើអត្ថបទនោះ)។<br>• ណែនាំឲ្យសិស្សសូមទោស ដោយពាក្យសំដី ឬ ដោយសរសេរ ដែលមានឥទ្ធិពលដល់សមាជិកគ្រប់គ្នា នៃសហគមន៍របស់សាលា។<br>• ជួបជាមួយ សិស្ស/ឪពុកម្តាយ និងបុគ្គលិករបស់សាលា។<br>• ចាត់មិត្តជិតស្និទ្ធក្នុងសាលា ឬ អ្នកផ្តល់ឱវាទ (កន្លែងដែលមាន)<br>• បញ្ជូនសិស្សទៅជួបអ្នកជំនាញ ខាងការផ្តល់ឱវាទ_និងការអប់រំ ឬទៅអ្នកជំនួយការទាក់ទងនឹងសាលារៀន ខាងផ្នែកសុខភាព អាកប្បកិរិយា (កន្លែងដែលមាន, តម្រូវឲ្យមានការអនុញ្ញាតពីឪពុកម្តាយ)។<br>• ប្តូរសិស្សទៅថ្នាក់ផ្សេង បណ្តោះអាសន្ន (ថ្នាក់ដែលសមរម្យ)។<br>• ផ្អាកមិនឲ្យសិស្សមានបុព្វសិទ្ធិគ្រប់យ៉ាងនៅក្នុងសាលា។<br>• ប្តូរសិស្សឲ្យទៅថ្នាក់ផ្សេងជារៀងរហូត (ថ្នាក់ដែលសមរម្យ)។<br>• បញ្ជូនសិស្សទៅក្នុងកម្មវិធី SMART ។<br>• បញ្ឈប់សិស្សមិនឲ្យរៀនបណ្តោះអាសន្ន ប៉ុន្តែឲ្យនៅក្នុងសាលា។<br>• បញ្ឈប់សិស្សមិនឲ្យមករៀនបណ្តោះអាសន្ន (អាចអនុវត្តទៅបាន ក្រោយពេលដែលសាលាបានធ្វើអន្តរាគមន៍ តាមគ្រប់វិធីរាយរាប់មកពីខាងលើរួចហើយ)។ |

| វិន័យកម្រិត១ និងការធ្វើអន្តរាគមន៍<br>ថ្នាក់មត្តេយ្យ–ថ្នាក់ទី៥ | |
|---|---|
| **វិន័យ** | **អន្តរាគមន៍ក្នុងថ្នាក់រៀន** |
| **វិន័យទី ២៖ ការប្រព្រឹត្តតាមក្រុម នៃការស្មៀកពាក់** | • ពិភាក្សាជាមួយសិស្ស អំពីហេតុការណ៍ដែលបានកើតឡើង។<br>• ប្រគល់ឯកសណ្ឋានដែលសាលាមានក្នុងឃ្លាំង ឲ្យទៅសិស្ស សម្រាប់ថ្ងៃនេះ។<br>• ជួបជាមួយ សិស្ស/ឪពុកម្តាយ និងបុគ្គលិករបស់សាលា។<br>• ផ្អាកមិនឲ្យសិស្សមានបុព្វសិទ្ធិគ្រប់យ៉ាងនៅក្នុងសាលា។<br>• បញ្ឈប់សិស្សមិនឲ្យរៀនបណ្តោះអាសន្ន ប៉ុន្តែឲ្យនៅក្នុងសាលា។<br>• បញ្ជូនសិស្សទៅក្នុងកម្មវិធី SMART ។ |
| **វិន័យទី ៣៖ ការហាមឃាត់ មិនឲ្យប្រើពណ៌/សញ្ញានៃក្រុមអ្នកលេង** | • ពិភាក្សាជាមួយសិស្ស អំពីហេតុការណ៍ដែលបានកើតឡើង។<br>• ប្រគល់ឯកសណ្ឋានដែលសាលាមានក្នុងឃ្លាំង ឲ្យទៅសិស្ស សម្រាប់ថ្ងៃនេះ។<br>• ជួបជាមួយ សិស្ស/ឪពុកម្តាយ និងបុគ្គលិករបស់សាលា។<br>• បញ្ជូនសិស្សទៅក្នុងកម្មវិធី SMART ។<br>• បញ្ជូនសិស្សទៅឲ្យអង្គការ ដែលមានទីតាំងនៅក្នុងសហគម។<br>• ផ្អាកមិនឲ្យសិស្សមានបុព្វសិទ្ធិគ្រប់យ៉ាងនៅក្នុងសាលា។<br>• បញ្ឈប់សិស្សមិនឲ្យមករៀនបណ្តោះអាសន្ន (អាចអនុវត្តទៅបាន ក្រោយពេលដែលសាលាបានធ្វើអន្តរាគមន៍ តាមគ្រប់វិធីរាយរាប់មកពីខាងលើរួចហើយ)។ |
| **វិន័យទី ៤៖ ការហាមឃាត់ មិនឲ្យប្រើពាក្យវាយប្រហារ** | • ពិភាក្សាជាមួយសិស្ស អំពីហេតុការណ៍ដែលបានកើតឡើង។<br>• ប្រើវិធីអប់រំ/ឈ្លាសវៃ ក្នុងការធ្វើអន្តរាគមន៍ (ឧ. សិស្សសរសេរអត្ថបទ រៀបរាប់ពីបទល្មើស និងផលវិបាក, ឪពុកម្តាយចុះអត្ថលេខាលើអត្ថបទនោះ)។<br>• ណែនាំឲ្យសិស្សសូមទោស ដោយពាក្យសំដី ឬ ដោយសរសេរ ដែលមានឥទ្ធិពលដល់សមាជិកគ្រប់គ្នា នៃសហគមន៍របស់សាលា។<br>• ជួបជាមួយ សិស្ស/ឪពុកម្តាយ និងបុគ្គលិករបស់សាលា។<br>• ប្តូរសិស្សទៅថ្នាក់ផ្សេង បណ្តោះអាសន្ន (ថ្នាក់ដែលសមរម្យ)។<br>• បញ្ជូនសិស្សទៅជួបអ្នកជំនាញ ខាងការផ្តល់ឱវាទ និងការអប់រំ ឬទៅអ្នកជំនួយការទាក់ទងនឹងសាលារៀន ខាងផ្នែកសុខភាព អាកប្បកិរិយា (កន្លែងដែលមាន, តម្រូវឲ្យមានការអនុញ្ញាតពីឪពុកម្តាយ) តាម CSAP។<br>• ផ្អាកមិនឲ្យសិស្សមានបុព្វសិទ្ធិគ្រប់យ៉ាងនៅក្នុងសាលា។<br>• ប្តូរសិស្សឲ្យទៅថ្នាក់ផ្សេងជារៀងរហូត (ថ្នាក់ដែលសមរម្យ)។<br>• បញ្ជូនសិស្សទៅក្នុងកម្មវិធី SMART ។<br>• បញ្ឈប់សិស្សមិនឲ្យរៀនបណ្តោះអាសន្ន ប៉ុន្តែឲ្យនៅក្នុងសាលា។<br>• បញ្ឈប់សិស្សមិនឲ្យមករៀនបណ្តោះអាសន្ន (អាចអនុវត្តទៅបាន ក្រោយពេលដែលសាលាបានធ្វើអន្តរាគមន៍ តាមគ្រប់វិធីរាយរាប់មកពីខាងលើរួចហើយ)។ |

| វិន័យកម្រិត១ និងការធ្វើអន្តរាគមន៍<br>ថ្នាក់មត្តេយ្យ–ថ្នាក់ទី៨ | |
|---|---|
| **វិន័យ** | **អន្តរាគមន៍ក្នុងថ្នាក់រៀន** |
| **វិន័យទី ៥៖**<br>**សេចក្តីតំរូវអំពីការស្មោះត្រង់ដល់ការសិក្សា** | • ពិភាក្សាជាមួយសិស្ស អំពីហេតុការណ៍ដែលបានកើតឡើង។<br>• ណែនាំឲ្យសិស្ស ប្រឡង ឬ ធ្វើកិច្ចការ សាឡើងវិញ ហើយត្រូវសរសេររបាយការណ៍ ពីផលវិបាក នៃអំពើនោះ; ឪពុកម្តាយ ចុះហត្ថលេខាលើរបាយការណ៍នោះ។<br>• ប្រើអក្សរសិល្ប៍ដែលមានសារៈសំខាន់ ចង្អុលបង្ហាញពីភាពស្មោះត្រង់ក្នុងការសិក្សា និងភាពស្មោះត្រង់ ជាទូទៅ។<br>• ណែនាំឲ្យសិស្សសូមទោស ដោយពាក្យសំដី ឬ ដោយសរសេរ ដែលមានឥទ្ធិពល ដល់សមាជិកគ្រប់គ្នា នៃសហគមន៍របស់សាលា។<br>• ជួបជាមួយ សិស្ស/ឪពុកម្តាយ និងបុគ្គលិករបស់សាលា។<br>• ផ្អាកមិនឲ្យសិស្សមានបុព្វសិទ្ធិគ្រប់យ៉ាងនៅក្នុងសាលា។<br>• បញ្ជូនសិស្សទៅក្នុងកម្មវិធី SMART ។<br>• បញ្ឈប់សិស្សមិនឲ្យរៀនបណ្តោះអាសន្ន ប៉ុន្តែឲ្យនៅក្នុងសាលា។<br>• បញ្ឈប់សិស្សមិនឲ្យមករៀនបណ្តោះអាសន្ន (អាចអនុវត្តទៅបាន ក្រោយពេលដែលសាលាបានធ្វើអន្តរាគមន៍ តាមគ្រប់វិធីរាយរាប់មកពីខាងលើរួចហើយ)។ |
| **វិន័យទី ៦៖ ការហាមឃាត់មិនឲ្យប្រើកុំព្យូទ័រ និងអ៊ិនធឺណិតខុសច្បាប់** | • ពិភាក្សាជាមួយសិស្ស អំពីហេតុការណ៍ដែលបានកើតឡើង។<br>• ប្រើវិធីអប់រំ/ឈ្លាសវៃ ក្នុងការធ្វើអន្តរាគមន៍ (ឧ. សិស្សសរសេរអត្ថបទ រៀបរាប់ពីបទល្មើស នឹងលទ្ធផលដែលត្រូវទទួល, ឪពុកម្តាយចុះអត្ថលេខាលើអត្ថបទនោះ)។<br>• ជួបជាមួយឪពុកម្តាយ។<br>• ដកហូតសិទ្ធិ មិនឲ្យប្រើកុំព្យូទ័រ និង អ៊ីនធឺរណេិត ចំនួន១ ថ្ងៃ។<br>• ដកហូតសិទ្ធិ មិនឲ្យប្រើកុំព្យូទ័រ និង អ៊ីនធឺរណេិត ចំនួន ៥ ថ្ងៃ។<br>• ដកហូតសិទ្ធិ មិនឲ្យប្រើកុំព្យូទ័រ និង អ៊ីនធឺរណេិត ជារៀងរហូត។<br>• បញ្ជូនសិស្សទៅកម្មវិធី SMART។ |

| វិន័យកម្រិត១ និងការធ្វើអន្តរាគមន៍<br>ថ្នាក់មត្តេយ្យ–ថ្នាក់ទី៨ | |
|---|---|
| **វិន័យ** | **អន្តរាគមន៍ក្នុងថ្នាក់រៀន** |
| **វិន័យទី ៧៖ ការហាមឃាត់**<br>**មិនឲ្យបំផ្លាញវត្ថុសម្បត្តិផ្សេងៗ** | • ពិភាក្សាជាមួយសិស្ស អំពីហេតុការណ៍ដែលបានកើតឡើង។<br>• ណែនាំឲ្យសិស្សសម្អាត (បើសិនជាមានគូសក្រវេមក្រវាម) និងសរសេរសំបុត្រសូមទោសចំពោះជនរងគ្រោះ បុគ្គលិក និងនាយកសាលា; ឪពុកម្តាយចុះហត្ថលេខាលើសំបុត្រនោះ។<br>• ជួបជាមួយ សិស្ស/ឪពុកម្តាយ និងបុគ្គលិករបស់សាលា។<br>• តម្រូវឲ្យមានដំណោះស្រាយសមស្រប បើអាចធ្វើទៅបាន។ |

| | |
|---|---|
| | • ផ្អាកមិនឲ្យសិស្សមានបុព្វសិទ្ធិគ្រប់យ៉ាងនៅក្នុងសាលា។<br>• បញ្ជូនសិស្សទៅក្នុងកម្មវិធី SMART ។<br>• បញ្ឈប់សិស្សមិនឲ្យរៀនបណ្ដោះអាសន្ន ប៉ុន្តែឲ្យនៅក្នុងសាលា។<br>• បញ្ឈប់សិស្សមិនឲ្យមករៀនបណ្ដោះអាសន្ន (នៅពេលដែលមានការខូចខាតខ្លាំង ការបញ្ឈប់សិស្សមិនឲ្យមករៀនបណ្ដោះអាសន្ន ប្រហែលជាប្រតិកម្មដំបូង ដ៏សមរម្យ)។ |
| **វិន័យទី ៨៖ ការហាមឃាត់ មិនឲ្យលេងល្បែង** | • ពិភាក្សាជាមួយសិស្ស អំពីហេតុការណ៍ដែលបានកើតឡើង។<br>• ជួបជាមួយ សិស្ស/ឪពុកម្ដាយ និងបុគ្គលិករបស់សាលា។<br>• តម្រូវឲ្យមានដំណោះស្រាយសមស្រប បើអាចធ្វើទៅបាន។<br>• ណែនាំឲ្យសិស្សសរសេរវិញ្ញាសារអំពីឥទ្ធិពលនៃល្បែងស៊ីសង នៅក្នុងសង្គម។<br>• ឃាត់សិស្សមិនឲ្យទៅផ្ទះ ក្រោយម៉ោងសិក្សា។<br>• ផ្អាកមិនឲ្យសិស្សមានបុព្វសិទ្ធិគ្រប់យ៉ាងនៅក្នុងសាលា។<br>• បញ្ជូនសិស្សទៅក្នុងកម្មវិធី SMART ។<br>• បញ្ឈប់សិស្សមិនឲ្យរៀនបណ្ដោះអាសន្ន ប៉ុន្តែឲ្យនៅក្នុងសាលា។<br>• បញ្ឈប់សិស្សមិនឲ្យមករៀនបណ្ដោះអាសន្ន (នៅពេលដែលមានការខូចខាតខ្លាំង ការបញ្ឈប់សិស្សមិនឲ្យមករៀនបណ្ដោះអាសន្ន ប្រហែលជាប្រតិកម្មដំបូង ដ៏សមរម្យ)។ |

| **វិន័យកម្រិត១ និងការធ្វើអន្តរាគមន៍<br>ថ្នាក់មត្តេយ្យ–ថ្នាក់ទី៨** | |
|---|---|
| **វិន័យ** | **អន្តរាគមន៍ក្នុងថ្នាក់រៀន** |
| **វិន័យទី ៩៖ ការហាមឃាត់<br>មិនឲ្យធ្វើឲ្យមានគ្រោះថ្នាក់** | • ពិភាក្សាជាមួយសិស្ស អំពីហេតុការណ៍ដែលបានកើតឡើង។<br>• ណែនាំឲ្យសិស្សសរសេរសំបុត្រសូមទោសចំពោះជនរងគ្រោះ បុគ្គលិក និងនាយកសាលា; ឪពុកម្ដាយចុះហត្ថលេខាលើសំបុត្រនោះ។<br>• ប្រើឱកាសនេះដើម្បីពន្យល់អំពីការបង្ការកុំឲ្យមានគ្រោះថ្នាក់ទៅថ្នាក់ទាំងមូល; ឲ្យសិស្សបង្កើតប័ណ្ណប្រកាសអំពីការបង្ការកុំឲ្យមានគ្រោះថ្នាក់ ដើម្បីបិទនៅក្នុងថ្នាក់។<br>• ជួបជាមួយ សិស្ស/ឪពុកម្ដាយ និងបុគ្គលិករបស់សាលា។<br>• ចាត់ឲ្យមានមិត្តរួមថ្នាក់ជិតស្និទ្ធ ឬ អ្នកផ្ដល់ឱវាទ។<br>• ប្ដូរសិស្សទៅថ្នាក់ផ្សេង បណ្ដោះអាសន្ន (ថ្នាក់ដែលសមរម្យ)។<br>• ផ្អាកមិនឲ្យសិស្សមានបុព្វសិទ្ធិគ្រប់យ៉ាងនៅក្នុងសាលា។<br>• ប្ដូរសិស្សឲ្យទៅថ្នាក់ផ្សេងជារៀងរហូត (ថ្នាក់ដែលសមរម្យ)។<br>• បញ្ឈប់សិស្សមិនឲ្យរៀនបណ្ដោះអាសន្ន ប៉ុន្តែឲ្យនៅក្នុងសាលា។<br>• បញ្ជូនសិស្សទៅក្នុងកម្មវិធី SMART ។<br>• បញ្ឈប់សិស្សមិនឲ្យមករៀនបណ្ដោះអាសន្ន។ |
| **វិន័យទី ១០៖ ការហាមឃាត់<br>មិនឲ្យមានការគំរាមកំហែង** | • ពិភាក្សាជាមួយសិស្សអំពី ហេតុការណ៍ដែលបានកើតឡើង។<br>• ណែនាំឲ្យសិស្សសរសេរសំបុត្រសូមទោសចំពោះជនរងគ្រោះ បុគ្គលិក និងនាយកសាលា; ឪពុកម្ដាយ ចុះអត្ថលេខាលើសំបុត្រនោះ។ |

| | |
|---|---|
| | • ប្រើហេតុការណ៍ដែលកើតឡើងជាឱកាសដើម្បីពន្យល់អំពីការគំរាមកំហែង និងអំពីអារម្មណ៍ដែលគេធ្វើឲ្យកើតឡើង។<br>• ជួបជាមួយ សិស្ស/ឪពុកម្តាយ នឹងបុគ្គលិក ហើយចាត់ឲ្យមានមិត្តរួមថ្នាក់ពិតស្និទ្ធ ឬ អ្នកផ្តល់ឱវាទ។<br>• វាយតម្លៃសិស្សសម្រាប់ការធ្វើអន្តរាគមន៍ CSAP កម្រិតទី I ។<br>• ប្តូរសិស្សទៅថ្នាក់ផ្សេង បណ្តោះអាសន្ន (ថ្នាក់ដែលសមរម្យ)។<br>• ផ្អាកមិនឲ្យសិស្សមានបុព្វសិទ្ធិគ្រប់យ៉ាងនៅក្នុងសាលា។<br>• ប្តូរសិស្សឲ្យទៅថ្នាក់ផ្សេងជារៀងរហូត (ថ្នាក់ដែលសមរម្យ)។<br>• បញ្ឈប់សិស្សមិនឲ្យរៀនបណ្តោះអាសន្ន ប៉ុន្តែឲ្យនៅក្នុងសាលា។<br>• បញ្ជូនសិស្សទៅក្នុងកម្មវិធី SMART ។<br>• វាយតម្លៃសិស្សសម្រាប់ការធ្វើអន្តរាគមន៍ CSAP កម្រិតទី II ។<br>• បញ្ឈប់សិស្សមិនឲ្យមករៀនបណ្តោះអាសន្ន។ |

| វិន័យកម្រិត១ និងការធ្វើអន្តរាគមន៍<br>ថ្នាក់មត្តេយ្យ-ថ្នាក់ទី៨ | |
|---|---|
| **វិន័យ** | **អន្តរាគមន៍ក្នុងថ្នាក់រៀន** |
| **វិន័យទី ១១៖ ការហាមឃាត់មិនឲ្យមានការវាយតប់គ្នា** | • ពិភាក្សាជាមួយសិស្សអំពី ហេតុការណ៍ដែលបានកើតឡើង។<br>• ណែនាំឲ្យសិស្សសរសេរសំបុត្រសូមទោសចំពោះជនរងគ្រោះ បុគ្គលិក និងនាយកសាលា; ឪពុកម្តាយចុះអត្ថលេខាលើអត្ថបទនោះ)។<br>• ជួបជាមួយ សិស្ស/ឪពុកម្តាយ និងបុគ្គលិក ហើយចាត់ឲ្យមានមិត្តរួមថ្នាក់ពិតស្និទ្ធ ឬ អ្នកផ្តល់ឱវាទ។<br>• ប្តូរសិស្សទៅថ្នាក់ផ្សេង បណ្តោះអាសន្ន (ថ្នាក់ដែលសមរម្យ)។<br>• ផ្អាកមិនឲ្យសិស្សមានបុព្វសិទ្ធិគ្រប់យ៉ាងនៅក្នុងសាលា។<br>• ប្តូរសិស្សឲ្យទៅថ្នាក់ផ្សេងជារៀងរហូត (ថ្នាក់ដែលសមរម្យ)។<br>• បញ្ឈប់សិស្សមិនឲ្យរៀនបណ្តោះអាសន្ន ប៉ុន្តែឲ្យនៅក្នុងសាលា។<br>• បញ្ជូនសិស្សទៅក្នុងកម្មវិធី SMART ។<br>• បញ្ឈប់សិស្សមិនឲ្យមករៀនបណ្តោះអាសន្ន។ |
| **វិន័យទី ១២៖ ការហាមឃាត់មិនឲ្យមានការវាយលុកធម្មតា** | • ពិភាក្សាជាមួយសិស្សអំពី ហេតុការណ៍ដែលបានកើតឡើង។<br>• ណែនាំឲ្យសិស្សសរសេរសំបុត្រសូមទោសចំពោះជនរងគ្រោះ បុគ្គលិក និង នាយកសាលា; ឪពុកម្តាយចុះអត្ថលេខាលើសំបុត្រនោះ)។<br>• ជួបជាមួយ សិស្ស/ឪពុកម្តាយ និងបុគ្គលិក ហើយចាត់ឲ្យមានមិត្តរួមថ្នាក់ពិតស្និទ្ធ ឬ អ្នកផ្តល់ឱវាទ។<br>• ចាត់សិស្ស ឲ្យមានការនាំសម្រុះសម្រួល ការដោះស្រាយទំនាស់, ឬបញ្ជូនសិស្សទៅផ្នែកគ្រប់គ្រងកំហឹង។<br>• ប្តូរសិស្សទៅថ្នាក់ផ្សេង បណ្តោះអាសន្ន (ថ្នាក់ដែលសមរម្យ)។ |

| | |
|---|---|
| | • ផ្អាកមិនឲ្យសិស្សមានបុព្វសិទ្ធិគ្រប់យ៉ាងនៅក្នុងសាលា។<br>• ប្តូរសិស្សឲ្យទៅថ្នាក់ផ្សេងជារៀងរហូត (ថ្នាក់ដែលសមរម្យ)។<br>• បញ្ឈប់សិស្សមិនឲ្យរៀនបណ្តោះអាសន្ន ប៉ុន្តែឲ្យនៅក្នុងសាលា។<br>• បញ្ជូនសិស្សទៅក្នុងកម្មវិធី SMART ។<br>• បញ្ឈប់សិស្សមិនឲ្យមករៀនបណ្តោះអាសន្ន។ |

| វិន័យកម្រិត១ និងការធ្វើអន្តរាគមន៍<br>ថ្នាក់មត្តេយ្យ-ថ្នាក់ទី៨ | |
|---|---|
| **វិន័យ** | **អន្តរាគមន៍ក្នុងថ្នាក់រៀន** |
| **វិន័យទី ១៣៖ ការហាមឃាត់ មិនឲ្យមានការបញ្ចេញពាក្យមិនសមរម្យ និងការប៉ះពាល់មិនសមរម្យ** | • ពិភាក្សាពីឧប្បត្តិហេតុ ដែលកើតឡើងជាមួយនឹងសិស្ស ហើយបញ្ជូនសិស្សទៅ សេវកម្មឧបត្ថម្ភ សមហេតុសមផលនៃគ្រួសារ។<br>• ផ្តល់ការណែនាំសិស្ស ឲ្យសរសេរលិខិតអភ័យទោសទៅសិស្សមួយទៀត, បុគ្គលិកសាលារៀន និងនាយកនាយិកាសាលា, មាតាបិតា ចុះហត្ថលេខាលើលិខិតនោះ។<br>• ជួបជាមួយនឹងសិស្ស/មាតាបិតា និងសមាជិកនៃបុគ្គលិកសាលារៀន ហើយរៀបចំឲ្យមាន មិត្តភ័ក្រ្តក្នុងបន្ទប់រៀន ឬក៍អ្នកអប់រំពេញវ័យ (បើនៅទីនោះអាចមាន)។<br>• បញ្ជូនទៅសាលាវិន័យ C&E (បើសិនជាអាចទៅបាន)។<br>• ចាត់ឲ្យសិស្សជាបណ្តោះអាសន្ន ទៅកាន់ថ្នាក់ផ្សេងៗគ្នា (ទីកន្លែងដែលសមរម្យ)។<br>• មិនអាចឲ្យសិស្សទទួលបុព្វសិទ្ធិរបស់សាលារៀន។<br>• ចាត់ឲ្យសិស្ស ទៅកាន់បន្ទប់ដ៏ទៃដោយជាប់លាប់ (ទីនោះសមហេតុផល)។<br>• ចាត់ឲ្យសិស្សចូលទៅក្នុង ការព្យួរទោសមិនឲ្យចូលរៀន ក្នុសាលា។<br>• ចាត់ឲ្យសិស្សទៅក្នុងកម្មវិធី SMART។<br>• ព្យួរទោសសិស្ស មិនឲ្យចូលរៀន។ |
| **វិន័យទី ១៤៖ ការហាមឃាត់ មិនឲ្យមានប្រើគ្រឿងថ្នាំជក់** | • ដកហូតយករបស់នោះ។<br>• ពិភាក្សាជាមួយសិស្ស អំពីហេតុការណ៍ដែលបានកើតឡើង។<br>• ណែនាំឲ្យសិស្សសរសេរពំពីការប្រើប្រាស់ផលិតផលថ្នាំជក់ និងការប្រើផលិតផល ថ្នាំជក់ហួសចំណុះ។<br>• ប្រើឱកាសនេះដើម្បីបង្រៀនពីការរស់នៅប្រកបដោយសុខមាលភាព ដល់ថ្នាក់ទាំងមូល។<br>• ជួបជាមួយសិស្ស/ឳពុកម្តាយ និងបុគ្គលិករបស់សាលា។<br>• វាយតម្លៃសិស្សសម្រាប់ការធ្វើអន្តរាគមន៍ CSAP កម្រិតទី II ។<br>• ផ្អាកមិនឲ្យសិស្សមានបុព្វសិទ្ធិគ្រប់យ៉ាងនៅក្នុងសាលា។<br>• បញ្ជូនសិស្សទៅក្នុងកម្មវិធី SMART ។ |

<table>
<tr><td></td><td>• បញ្ឈប់សិស្សមិនឲ្យរៀនបណ្ដោះអាសន្ន ប៉ុន្តែឲ្យនៅក្នុងសាលា។<br>• បញ្ឈប់សិស្សមិនឲ្យមករៀនបណ្ដោះអាសន្ន។</td></tr>
<tr><td>វិន័យទី ១៥៖ ការហាមឃាត់<br>មិនឲ្យមានប្រើគ្រឿងញៀន និងស្រវឹង</td><td>• ដកហូតយករបស់នោះ។<br>• ពិភាក្សាជាមួយសិស្សអំពី ហេតុការណ៍ដែលបានកើតឡើង។<br>• បញ្ជូនសិស្សទៅ C&E (បើសិនជាមាន) តាម CSAP។<br>• ណែនាំឲ្យសិស្សសរសេរពំពីការប្រើប្រាស់គ្រឿងញៀន និងគ្រឿងស្រវឹង នឹងការប្រើគ្រឿងញៀន និងគ្រឿងស្រវឹង ហួសចំណុះ។<br>• ឃាត់សិស្សមិនឲ្យចេញទៅផ្ទះ ក្រោយម៉ោងសិក្សា។<br>• បញ្ជូនសិស្ស ឲ្យទៅក្នុងកម្មវិធីព្យាបាលគ្រឿងញៀន។<br>• ជួបជាមួយសិស្ស/ឪពុកម្ដាយ និងបុគ្គលិករបស់សាលា។<br>• បញ្ជូនសិស្សទៅ អន្តរាគមន៍ផ្នែក CSAP TIER ជាន់ទី២ ហើយឲ្យមានទំនាក់ទំនងទៅ ការឲ្យតំលៃ D&A (ត្រូវមានការអនុញ្ញាតិពីមាតាបិតា)។<br>• ផ្អាកមិនឲ្យសិស្សមានបុព្វសិទ្ធិគ្រប់យ៉ាងនៅក្នុងសាលា។<br>• បញ្ជូនសិស្សទៅក្នុងកម្មវិធី SMART ។<br>• បញ្ឈប់សិស្សមិនឲ្យរៀនបណ្ដោះអាសន្ន ប៉ុន្តែឲ្យនៅក្នុងសាលា។<br>• បញ្ឈប់សិស្សមិនឲ្យមករៀនបណ្ដោះអាសន្ន។</td></tr>
</table>

<table>
<tr><th colspan="2">វិន័យកម្រិត២ និងការធ្វើអន្តរាគមន៍<br>ថ្នាក់កុមារដ្ឋាន-ថ្នាក់ទី៤</th></tr>
<tr><th>វិន័យ</th><th>អន្តរាគមន៍ក្នុងថ្នាក់រៀន</th></tr>
<tr><td>វិន័យទី ១៦៖ ការប្រព្រឹត្តល្មើសលើក្រម ម្ដងហើយ ម្ដងទៀត<br>សម្គាល់៖ មិនមែនជាបទល្មើសទេ ប្រសិនបើសាលាមិនបាន ធ្វើអន្តរាគមន៍តបទៅនឹងបទល្មើសនីមួយៗជាបន្ទាន់។</td><td>សូមអានទំព័រទី ១៩</td></tr>
<tr><td>វិន័យទី ១៧៖ ហាមបំផ្លាញ និង លួច ទ្រព្យសម្បត្តិ</td><td rowspan="10">• បញ្ឈប់សិស្សមិនឲ្យមករៀនបណ្ដោះអាសន្ន បញ្ជូនសិស្សទៅក្នុងកម្ម វិធី SMART និងផ្ដល់យោបល់ឲ្យសិស្សប្ដូរសាលា នៅលើសំណុំ លិខិត EH-21 form ។<br><br>• សំរាប់ការបំពានដោយផ្លូវភេទ, សិស្ស គួរតែត្រូវបញ្ជូនឲ្យទៅទទួលជំនួយសេវកម្ម សំរាប់គ្រួសារផងដែរ។</td></tr>
<tr><td>វិន័យទី ១៨៖ ហាម សម្លុតធ្វើបាប/សម្លុតតាមកុំព្យូទ័រ</td></tr>
<tr><td>វិន័យទី ១៩៖ ហាម ប៉ះពាល់លូកលាន់លើផ្លូវភេទ</td></tr>
<tr><td>វិន័យទី ២០៖ ហាម រួមភេទ ដោយស្ម័គ្រចិត្ត +</td></tr>
<tr><td>វិន័យទី ២១៖ ហាម  រួមភេទ ដោយបង្ខំ</td></tr>
<tr><td>វិន័យទី ២២៖ ហាម វាយតប់ បុគ្គលិករបស់សាលា</td></tr>
<tr><td>វិន័យទី ២៣៖ ហាម ជំរុញការវាយតប់</td></tr>
<tr><td>វិន័យទី ២៤៖ ហាម លួចប្លន់</td></tr>
<tr><td>វិន័យទី ២៥៖ ហាម មិនឲ្យមានអាវុធ</td></tr>
<tr><td>វិន័យទី ២៦៖ ហាម ចែកចាយគ្រឿងញៀន ឬ គ្រឿងស្រវឹង</td></tr>
</table>

| វិន័យទី ២៧៖ ហាម ធ្វើឲ្យជនណាម្នាក់ស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ | |
|---|---|
| | |
| | |

## ៣.៥ អន្តរាគមន៍/ការឆ្លើតតបដោយសមស្រប អំពីបទល្មើសលើក្រមសីលធម៌ របស់សិស្ស ថ្នាក់ទី ៥-១២

តារាងបន្តទៅនេះ គឺសម្រាប់រាយរាប់ប្រាប់អំពីការធ្វើអន្តរាគមន៍/ប្រតិកម្មតប ដោយសមរម្យ ដែលអាចយកទៅអនុវត្តដាច់ដោយឡែក ឬដោយរួមគ្នា ក្នុងការឆ្លើយតបទៅនឹងបទល្មើសណាមួយ។ ឧទាហរណ៍ សម្រាស់ការបំពានម្តងទៅលើ វិន័យទី១, សិស្សប្រហែលជាត្រូវបាន តម្រូវឲ្យ ជួបជាមួយឪពុកម្តាយសិស្សនោះ សរសេរសំបុត្រសូមទោស និងឃាត់មិនឲ្យចេញទៅផ្ទះក្រោយម៉ោងសិក្សា។ **លើកលែងតែ ដូចការរៀបរាប់ខាងក្រោមនេះ នាយកសាលា អាចបង្គំឲ្យធ្វើអន្តរាគមន៍ផ្សេងទៀត ដែលគ្មានចែងក្នុងតារាងនេះ ដែលអាចចាត់ទុកថាជាការសមរម្យ ដោយនាយកសាលា។**

សូមកត់ចំណាំថា សិស្សណាដែលមានបង្ហាញការប្រព្រឹត្តជាញយៗ អំពីអាកប្បកិរិយាល្មើសច្បាប់ ត្រូវបញ្ជូនទៅក្រុម CSAP ដើម្បីឲ្យធ្វើអន្តរាគមន៍ តាម TIER ជាន់ទី១ (ជាក្រុម) ឬ TIER ជាន់ទី២ (ម្នាក់ៗ)។

| **វិន័យកម្រិត១ និងការធ្វើអន្តរាគមន៍<br>ថ្នាក់ទី ៥-១២** | |
|---|---|
| **វិន័យ** | **អន្តរាគមន៍ក្នុងថ្នាក់រៀន** |
| **វិន័យទី ១៖ ហាម ខំខានដល់សាលា**<br>**សម្គាល់៖** ប្រសិនបើសិស្សណាម្នាក់ មកសាលា ឬមកថ្នាក់មិនទាន់ពេល សិស្សនោះនឹងអាចមិនឲ្យចូលថ្នាក់ ក្នុងខនៈដែលសិស្សនោះមកថ្នាក់មិនទាន់ពេល ឬក៏ថ្នាក់កំពុងតែដំណើរការក្នុងពេលដែលសិស្សនោះមកដល់សាលា។ មិនត្រូវបញ្ជូនសិស្សទៅផ្ទះវិញ ពីព្រោះការមកមិនទាន់ពេលនោះទេ។ មិនត្រូវពិន័យសិស្សមិនឲ្យមករៀន ពីព្រោះតែការមិនមករៀន ការមករៀនមិនទាន់ពេល ឬការគេចសាលានោះទេ។ សិស្សដែលទៅរៀនយឺត ឬឈប់ជាញយៗ ត្រូវបញ្ជូនទៅក្រុម CSAP ដើម្បីឲ្យធ្វើអន្តរាគមន៍ តាម TIER ជាន់ទី១ (ជាក្រុម) ឬ TIER ជាន់ទី២ (ម្នាក់ៗ)។ | • ពិភាក្សាជាមួយសិស្សអំពី ហេតុការណ៍ដែលបានកើតឡើង។<br>• ជួបជាមួយសិស្ស/ឪពុកម្តាយ និងបុគ្គលិករបស់សាលា។<br>• ណែនាំឲ្យសិស្សសូមទោស ដោយសរសេរ ឬ ដោយពាក្យសំដី ដែលមានឥទ្ធិពលដល់សមាជិកគ្រប់គ្នា នៃសហគមន៍របស់លាសា។<br>• ឃាត់មិនឲ្យសិស្សចេញទៅផ្ទះ ក្រោយម៉ោងសិក្សា។<br>• ប្តូរសិស្សទៅថ្នាក់ផ្សេង បណ្តោះអាសន្ន (ថ្នាក់ដែលសមរម្យ)។<br>• បញ្ជូនសិស្សទៅសាលាក្តីសម្រាប់ក្មេងជំទង់ (កន្លែងដែលមាន)។<br>• បញ្ជូនសិស្សឲ្យទៅធ្វើការបំរើសហគមន៍ (កន្លែងដែលមាន)។<br>• <u>ឲ្យសិស្សរាយការណ៍ប្រចាំថ្ងៃ រៀងរាល់ថ្ងៃ។</u><br>• ផ្អាកមិនឲ្យសិស្សមានបុព្វសិទ្ធិគ្រប់យ៉ាងនៅក្នុងសាលា។<br>• ប្តូរសិស្សឲ្យទៅថ្នាក់ផ្សេងជារៀងរហូត (ថ្នាក់ដែលសមរម្យ)។<br>• បញ្ឈប់សិស្សមិនឲ្យរៀនបណ្តោះអាសន្ន ប៉ុន្តែឲ្យនៅក្នុងសាលា។<br>• បញ្ជូនសិស្សទៅក្នុងកម្មវិធី SMART ។<br>• បញ្ឈប់សិស្សមិនឲ្យមករៀនបណ្តោះអាសន្ន (អាចអនុវត្តទៅបាន ក្រោយពេលដែលសាលាបានធ្វើអន្តរាគមន៍ តាមគ្រប់វិធីរាយរាប់មកពីខាងលើរួចហើយ លើកលែងតែក្នុងករណីដែលធ្ងន់ធ្ងរ។ សិស្សដែលត្រូវបានបញ្ឈប់មិនឲ្យមករៀន ចំពោះបទល្មើសលើកទីមួយ សិស្សនោះក៏គប្បីបញ្ជូនឲ្យទៅ CSAP ផងដែរ។) |

| វិន័យកម្រិត១ និងការធ្វើអន្តរាគមន៍<br>ថ្នាក់ទី ៥-១២ | |
|---|---|
| **វិន័យ** | **អន្តរាគមន៍ក្នុងថ្នាក់រៀន** |
| **វិន័យទី ២៖ ការប្រព្រឹត្តតាមក្រម នៃការស្លៀកពាក់** | • ពិភាក្សាជាមួយសិស្ស អំពីហេតុការណ៍ដែលបានកើតឡើង។<br>• ប្រគល់ឯកសណ្ឋានដែលសាលាមានក្នុងឃ្លាំង ឲ្យទៅសិស្ស សម្រាប់ថ្ងៃនេះ។<br>• ឃាត់សិស្សមិនឲ្យចេញទៅផ្ទះ ក្រោយម៉ោងសិក្សា<br>• ជួបជាមួយ សិស្ស/ឪពុកម្តាយ<br>• បញ្ជូនសិស្សទៅសាលាក្តីសម្រាប់ក្មេងជំទង់ (កន្លែងដែលមាន)។<br>• បញ្ជូនសិស្សឲ្យទៅធ្វើការបំរើសហគមន៍ (កន្លែងដែលមាន)។<br>• ផ្អាកមិនឲ្យសិស្សមានបុព្វសិទ្ធិគ្រប់យ៉ាងនៅក្នុងសាលា។<br>• បញ្ឈប់សិស្សមិនឲ្យរៀនបណ្តោះអាសន្ន ប៉ុន្តែឲ្យនៅក្នុងសាលា។<br>• បញ្ជូនសិស្សទៅក្នុងកម្មវិធី SMART ។ |
| **វិន័យទី ៣៖ ហាម ប្រើពណ៌/សញ្ញា នៃក្រុមអ្នកលេង** | • ពិភាក្សាជាមួយសិស្សអំពី ហេតុការណ៍ដែលបានកើតឡើង។<br>• ប្រគល់ឯកសណ្ឋានដែលសាលាមានក្នុងឃ្លាំង ឲ្យទៅសិស្ស សម្រាប់ថ្ងៃនេះ។<br>• ឃាត់មិនឲ្យសិស្សចេញទៅផ្ទះ ក្រោយម៉ោងសិក្សា។<br>• ជួបជាមួយ សិស្ស/ឪពុកម្តាយ។<br>• បញ្ជូនសិស្សទៅសាលាក្តីសម្រាប់ក្មេងជំទង់ (កន្លែងដែលមាន)។<br>• បញ្ជូនសិស្សឲ្យទៅធ្វើការបំរើសហគមន៍ (កន្លែងដែលមាន)។<br>• បញ្ជូនសិស្សឲ្យទៅអង្គការដែលមានមូលដ្ឋាននៅក្នុងសហគមន៍។<br>• ឲ្យសិស្សរាយការណ៍ប្រចាំថ្ងៃ រៀងរាល់ថ្ងៃ។<br>• ផ្អាកមិនឲ្យសិស្សមានបុព្វសិទ្ធិគ្រប់យ៉ាងនៅក្នុងសាលា។<br>• បញ្ជូនសិស្សទៅក្នុងកម្មវិធី SMART ។<br>• បញ្ឈប់សិស្សមិនឲ្យមករៀនបណ្តោះអាសន្ន (អាចអនុវត្តទៅបាន ក្រោយពេលដែលសាលាបានធ្វើអន្តរាគមន៍ តាមគ្រប់វិធីរាយរាប់មកពីខាងលើរួចហើយ លើកលែងតែក្នុងករណីដែលធ្ងន់ធ្ងរ។ សិស្សដែលត្រូវបានបញ្ឈប់មិនឲ្យមករៀន ចំពោះបទល្មើសលើកទីមួយ សិស្សនោះក៏គប្បីបញ្ជូនឲ្យទៅ CSAP ផងដែរ។) |

| វិន័យកម្រិត១ និងការធ្វើអន្តរាគមន៍<br>ថ្នាក់ទី ៥-១២ | |
|---|---|
| **វិន័យ** | **អន្តរាគមន៍ក្នុងថ្នាក់រៀន** |
| **វិន័យទី ៤៖ ហាមមិនឲ្យប្រើពាក្យវាយប្រហារ** | • ពិភាក្សាជាមួយសិស្សអំពី ហេតុការណ៍ដែលបានកើតឡើង។<br>• ឃាត់មិនឲ្យសិស្សចេញទៅផ្ទះ ក្រោយម៉ោងសិក្សា។<br>• ជួបជាមួយ សិស្ស/ឪពុកម្តាយ។<br>• ណែនាំឲ្យសិស្សសូមទោស ដោយសរសេរ ឬ ដោយពាក្យសំដី ដែលមានឥទ្ធិពល |

| | |
|---|---|
| | ដល់សមាជិកគ្រប់គ្នា នៃសហគមន៍របស់លាសា។<br>• ប្តូរសិស្សទៅថ្នាក់ផ្សេង បណ្តោះអាសន្ន (ថ្នាក់ដែលសមរម្យ)។<br>• បញ្ជូនសិស្សទៅសាលាក្តីសម្រាប់ក្មេងជំទង់ (កន្លែងដែលមាន)។<br>• បញ្ជូនសិស្សឲ្យទៅធ្វើការបំរើសហគមន៍ (កន្លែងដែលមាន)។<br>• <u>ឲ្យសិស្សរាយការណ៍ប្រចាំថ្ងៃ រៀងរាល់ថ្ងៃ។</u><br>• ផ្អាកមិនឲ្យសិស្សមានបុព្វសិទ្ធិគ្រប់យ៉ាងនៅក្នុងសាលា។<br>• ប្តូរសិស្សឲ្យទៅថ្នាក់ផ្សេងជារៀងរហូត (ថ្នាក់ដែលសមរម្យ)។<br>• បញ្ឈប់សិស្សមិនឲ្យរៀនបណ្តោះអាសន្ន ប៉ុន្តែឲ្យនៅក្នុងសាលា។<br>• បញ្ជូនសិស្សទៅក្នុងកម្មវិធី SMART ។<br>• បញ្ឈប់សិស្សមិនឲ្យមករៀនបណ្តោះអាសន្ន (អាចអនុវត្តទៅបាន ក្រោយពេលដែលសាលាបានធ្វើអន្តរាគមន៍ តាមគ្រប់វិធីរាយរាប់មកពីខាងលើរួចហើយ លើកលែងតែក្នុងករណីដែលធ្ងន់ធ្ងរ។ សិស្សដែលត្រូវបានបញ្ឈប់មិនឲ្យមករៀន ចំពោះបទល្មើសលើកទីមួយ សិស្សនោះក៏គប្បីបញ្ជូនឲ្យទៅ CSAP ផងដែរ។) |

| **វិន័យកម្រិត១ និងការធ្វើអន្តរាគមន៍<br>ថ្នាក់ទី ៥-១២** | |
|---|---|
| **វិន័យ** | **អន្តរាគមន៍ក្នុងថ្នាក់រៀន** |
| **វិន័យទី ៥៖<br>សេចក្តីតំរូវអំពីការស្មោះត្រង់ដល់ការសិក្សា** | • ពិភាក្សាជាមួយសិស្សអំពី ហេតុការណ៍ដែលបានកើតឡើង។<br>• ឃាត់មិនឲ្យសិស្សចេញទៅផ្ទះ ក្រោយម៉ោងសិក្សា។<br>• ណែនាំឲ្យសិស្ស ប្រឡង ឬ ធ្វើកិច្ចការ សាឡើងវិញ ហើយត្រូវសរសេររបាយការណ៍ពីផលវិបាក នៃអំពើនោះ។<br>• ណែនាំឲ្យសិស្សសូមទោស ដោយសរសេរ ឬ ដោយពាក្យសំដី ដែលមានឥទ្ធិពលដល់សមាជិកគ្រប់គ្នា នៃសហគមន៍របស់លាសា។<br>• ជួបជាមួយ សិស្ស/ឪពុកម្តាយ។<br>• បញ្ជូនសិស្សទៅសាលាក្តីសម្រាប់ក្មេងជំទង់ (កន្លែងដែលមាន)។<br>• <u>ឲ្យសិស្សរាយការណ៍ប្រចាំថ្ងៃ រៀងរាល់ថ្ងៃ។</u><br>• ផ្អាកមិនឲ្យសិស្សមានបុព្វសិទ្ធិគ្រប់យ៉ាងនៅក្នុងសាលា។<br>• បញ្ឈប់សិស្សមិនឲ្យរៀនបណ្តោះអាសន្ន ប៉ុន្តែឲ្យនៅក្នុងសាលា។<br>• បញ្ជូនសិស្សទៅក្នុងកម្មវិធី SMART ។<br>• បញ្ឈប់សិស្សមិនឲ្យមករៀនបណ្តោះអាសន្ន (អាចអនុវត្តទៅបាន ក្រោយពេលដែលសាលាបានធ្វើអន្តរាគមន៍ តាមគ្រប់វិធីរាយរាប់មកពីខាងលើរួចហើយ) |
| **វិន័យទី ៦៖ ការហាមឃាត់មិនឲ្យប្រើកុំព្យូទ័រ និងអ៊ិនធឺរណិតខុសច្បាប់** | • ពិភាក្សាជាមួយសិស្ស អំពីហេតុការណ៍ដែលបានកើតឡើង។<br>• បញ្ជូនសិស្សទៅសាលាក្តីសម្រាប់ក្មេងជំទង់ (កន្លែងដែលមាន)។<br>• ជួបជាមួយឪពុកម្តាយ។<br>• ដកហូតសិទ្ធិ មិនឲ្យប្រើកុំព្យូទ័រ និង អ៊ិនធឺរណិត ចំនួន១ ថ្ងៃ។ |

| | |
|---|---|
| | • ដកហូតសិទ្ធិ មិនឲ្យប្រើកុំព្យូទ័រ និង អ៊ិនធឺរណេត ចំនួន ៥ ថ្ងៃ។<br>• ដកហូតសិទ្ធិ មិនឲ្យប្រើកុំព្យូទ័រ និង អ៊ិនធឺរណេត ជារៀងរហូត។ |

| **វិន័យកម្រិត១ និងការធ្វើអន្តរាគមន៍<br>ថ្នាក់ទី ៥-១២** | |
|---|---|
| **វិន័យ** | **អន្តរាគមន៍ក្នុងថ្នាក់រៀន** |
| **វិន័យទី ៧៖ ការហាមឃាត់ មិនឲ្យបំផ្លាញវត្ថុសម្បត្តិផ្សេងៗ** | • ពិភាក្សាជាមួយសិស្ស អំពីហេតុការណ៍ដែលបានកើតឡើង។<br>• ណែនាំឲ្យសិស្សសម្អាត (បើសិនជាមានគូសក្រវេមក្រវាម)<br>• ណែនាំឲ្យសិស្ស សរសេរសំបុត្រសូមទោសចំពោះជនរងគ្រោះ បុគ្គលិក និងនាយកសាលា; ឪពុក ម្តាយ ចុះហត្ថលេខាលើសំបុត្រនោះ។<br>• ឃាត់មិនឲ្យសិស្សចេញទៅផ្ទះ ក្រោយម៉ោងសិក្សា។<br>• ជួបជាមួយ សិស្ស/ឪពុកម្តាយ។<br>• តម្រូវឲ្យមានសំណងពីសិស្ស ក្នុងលក្ខណៈដែលសមរម្យ។<br>• បញ្ជូនសិស្សទៅសាលាក្តីសម្រាប់ក្មេងជំទង់ (កន្លែងដែលមាន)។<br>• បញ្ជូនសិស្សឲ្យទៅធ្វើការបំរើសហគមន៍ (កន្លែងដែលមាន)។<br>• ផ្អាកមិនឲ្យសិស្សមានបុព្វសិទ្ធិគ្រប់យ៉ាងនៅក្នុងសាលា។<br>• បញ្ជូនសិស្សទៅក្នុងកម្មវិធី SMART ។<br>• បញ្ឈប់សិស្សមិនឲ្យរៀនបណ្តោះអាសន្ន ប៉ុន្តែឲ្យនៅក្នុងសាលា។<br>• បញ្ឈប់សិស្សមិនឲ្យមករៀនបណ្តោះអាសន្ន (នៅពេលដែលមានការខូចខាតខ្លាំង ការបញ្ឈប់សិស្សមិនឲ្យមករៀនបណ្តោះអាសន្ន ប្រហែលជាប្រតិកម្មដំបូង ដ៏សមរម្យ)។ |
| **វិន័យទី ៨៖ ការហាមឃាត់ មិនឲ្យលេងល្បែង** | • ពិភាក្សាជាមួយសិស្ស អំពីហេតុការណ៍ដែលបានកើតឡើង។<br>• ឃាត់សិស្សមិនឲ្យទៅផ្ទះ ក្រោយម៉ោងសិក្សា។<br>• ជួបជាមួយ សិស្ស/ឪពុកម្តាយ។<br>• តម្រូវឲ្យមានសំណងពីសិស្ស ក្នុងលក្ខណៈដែលសមរម្យ។<br>• បញ្ជូនសិស្សទៅសាលាក្តីសម្រាប់ក្មេងជំទង់ (កន្លែងដែលមាន)។<br>• បញ្ជូនសិស្សឲ្យទៅធ្វើការបំរើសហគមន៍ (កន្លែងដែលមាន)។<br>• <u>បញ្ជូនសិស្សទៅក្រុមជំនួយ រឿងល្បែងស៊ីសង</u> (កន្លែងដែលមាន)។<br>• ផ្អាកមិនឲ្យសិស្សមានបុព្វសិទ្ធិគ្រប់យ៉ាងនៅក្នុងសាលា។<br>• បញ្ជូនសិស្សទៅក្នុងកម្មវិធី SMART ។<br>• បញ្ឈប់សិស្សមិនឲ្យរៀនបណ្តោះអាសន្ន ប៉ុន្តែឲ្យនៅក្នុងសាលា។<br>• បញ្ឈប់សិស្សមិនឲ្យមករៀនបណ្តោះអាសន្ន (ក្នុងលក្ខណៈ ដែលបទល្មើសមានសភាពធ្ងន់ធ្ងរ ការបញ្ឈប់សិស្សមិនឲ្យមករៀនបណ្តោះអាសន្ន ប្រហែលជាប្រតិកម្មដំបូង ដ៏សមរម្យ) |

**វិន័យកម្រិត១ និងការធ្វើអន្តរាគមន៍**
**ថ្នាក់ទី ៥-១២**

| វិន័យ | អន្តរាគមន៍ក្នុងថ្នាក់រៀន |
|---|---|
| **វិន័យទី ៩៖ ការហាមឃាត់ មិនឲ្យធ្វើឲ្យមានគ្រោះថ្នាក់** | • ពិភាក្សាជាមួយសិស្ស អំពីហេតុការណ៍ដែលបានកើតឡើង។<br>• ណែនាំឲ្យសិស្សសរសេរសំបុត្រសូមទោសចំពោះជនរងគ្រោះ បុគ្គលិក និងនាយកសាលា; ឳពុក ម្តាយ ចុះហត្ថលេខាលើសំបុត្រនោះ។<br>• ឃាត់សិស្សមិនឲ្យចេញទៅផ្ទះ ក្រោយម៉ោងសិក្សា។<br>• ជួបជាមួយ សិស្ស/ឳពុកម្តាយ។<br>• បញ្ជូនសិស្សទៅសាលាក្តីសម្រាប់ក្មេងជំទង់ (កន្លែងដែលមាន)។<br>• បញ្ជូនសិស្សឲ្យទៅធ្វើការបំរើសហគមន៍ (កន្លែងដែលមាន)។<br>• ប្តូរសិស្សឲ្យទៅថ្នាក់ផ្សេង (ថ្នាក់ដែលសមរម្យ)។<br>• ផ្អាកមិនឲ្យសិស្សមានបុព្វសិទ្ធិគ្រប់យ៉ាងនៅក្នុងសាលា។<br>• បញ្ជូនសិស្សទៅក្នុងកម្មវិធី SMART ។<br>• បញ្ឈប់សិស្សមិនឲ្យរៀនបណ្តោះអាសន្ន ប៉ុន្តែឲ្យនៅក្នុងសាលា។<br>• បញ្ឈប់សិស្សមិនឲ្យមករៀនបណ្តោះអាសន្ន (ក្នុងលក្ខណៈ ដែលបទល្មើសមានសភាពធ្ងន់ធ្ងរ ការបញ្ឈប់សិស្សមិនឲ្យមករៀនបណ្តោះអាសន្ន ប្រហែលជាប្រតិកម្មដំបូង ដ៏សមរម្យ)។ |
| **វិន័យទី ១០៖ ការហាមឃាត់ មិនឲ្យមានការគំរាមកំហែង** | • ពិភាក្សាជាមួយសិស្ស អំពីហេតុការណ៍ដែលបានកើតឡើង។<br>• ណែនាំឲ្យសិស្សសរសេរសំបុត្រសូមទោសចំពោះជនរងគ្រោះ បុគ្គលិក និងនាយកសាលា; ឳពុក ម្តាយ ចុះហត្ថលេខាលើសំបុត្រនោះ។<br>• ឃាត់សិស្សមិនឲ្យចេញទៅផ្ទះ ក្រោយម៉ោងសិក្សា។<br>• ជួបជាមួយ សិស្ស/ឳពុកម្តាយ។<br>• បញ្ជូនសិស្សទៅសាលាក្តីសម្រាប់ក្មេងជំទង់ (កន្លែងដែលមាន)។<br>• វាយតម្លៃសិស្សសម្រាប់ការធ្វើអន្តរាគមន៍ CSAP កម្រិតទី I ។<br>• ផ្អាកមិនឲ្យសិស្សមានបុព្វសិទ្ធិគ្រប់យ៉ាងនៅក្នុងសាលា។<br>• ប្តូរសិស្សឲ្យទៅថ្នាក់ផ្សេង (ថ្នាក់ដែលសមរម្យ)។<br>• បញ្ជូនសិស្សទៅក្នុងកម្មវិធី SMART ។<br>• បញ្ឈប់សិស្សមិនឲ្យរៀនបណ្តោះអាសន្ន ប៉ុន្តែឲ្យនៅក្នុងសាលា។<br>• វាយតម្លៃសិស្សសម្រាប់ការធ្វើអន្តរាគមន៍ CSAP កម្រិតទី II ។<br>• បញ្ឈប់សិស្សមិនឲ្យមករៀនបណ្តោះអាសន្ន (ក្នុងលក្ខណៈ ដែលបទល្មើសមានសភាពធ្ងន់ធ្ងរ ការបញ្ឈប់សិស្សមិនឲ្យមករៀនបណ្តោះអាសន្ន ប្រហែលជាប្រតិកម្មដំបូង ដ៏សមរម្យ)។ នៅទីនោះសិស្សត្រូវព្យួរផុតពីការសិក្សានៅក្នុងបទល្មើសជាដំបូង, សិស្សគួរតែបញ្ជូនទៅ CSAPផងដែរ។ |

| វិន័យកម្រិត១ និងការធ្វើអន្តរាគមន៍<br>ថ្នាក់ទី ៥-១២ | |
|---|---|
| **វិន័យ** | **អន្តរាគមន៍ក្នុងថ្នាក់រៀន** |
| **វិន័យទី ១១៖ ការហាមឃាត់មិនឲ្យមានការវាយគ្នា** | • ពិភាក្សាជាមួយសិស្ស អំពីហេតុការណ៍ដែលបានកើតឡើង។<br>• ណែនាំឲ្យសិស្សសរសេរសំបុត្រសូមទោសចំពោះជនរាងគ្រោះ បុគ្គលិក និងនាយកសាលា; ឪពុកម្តាយ ចុះហត្ថលេខាលើសំបុត្រនោះ។<br>• បញ្ជូនសិស្សទៅសាលាក្តីសម្រាប់ក្មេងជំទង់ (កន្លែងដែលមាន)។<br>• ឃាត់សិស្សមិនឲ្យចេញទៅផ្ទះ ក្រោយម៉ោងសិក្សា។<br>• ជួបជាមួយ សិស្ស/ឪពុកម្តាយ។<br>• ចាត់សិស្ស ឲ្យមានការនាំសម្រុះសម្រួល ការដោះស្រាយទំនាស់, ឬបញ្ជូនសិស្សទៅផ្នែកគ្រប់គ្រងកំហឹង (កន្លែងដែលសមរម្យ)។<br>• ផ្អាកមិនឲ្យសិស្សមានបុព្វសិទ្ធិគ្រប់យ៉ាងនៅក្នុងសាលា។<br>• ប្តូរសិស្សឲ្យទៅថ្នាក់ផ្សេង (ថ្នាក់ដែលសមរម្យ)។<br>• បញ្ជូនសិស្សទៅក្នុងកម្មវិធី SMART ។<br>• បញ្ឈប់សិស្សមិនឲ្យរៀនបណ្តោះអាសន្ន ប៉ុន្តែឲ្យនៅក្នុងសាលា។<br>• បញ្ឈប់សិស្សមិនឲ្យមករៀនបណ្តោះអាសន្ន (ក្នុងលក្ខណៈ ដែលបទល្មើសមានសភាពធ្ងន់ធ្ងរ ការបញ្ឈប់សិស្សមិនឲ្យមករៀនបណ្តោះអាសន្ន ប្រហែលជាប្រតិកម្មដំបូង ដ៏សមរម្យ)។ នៅទីនោះសិស្សត្រូវព្យួរផុតពីការសិក្សា នៅក្នុងបទល្មើសជាដំបូង, សិស្សគួរតែបញ្ជូនទៅ CSAPផងដែរ។ |

| វិន័យកម្រិត១ និងការធ្វើអន្តរាគមន៍<br>ថ្នាក់ទី ៥-១២ | |
|---|---|
| **វិន័យ** | **អន្តរាគមន៍ក្នុងថ្នាក់រៀន** |
| **វិន័យទី ១២៖ ការហាមឃាត់មិនឲ្យមានការវាយលុកធម្មតា** | • ពិភាក្សាជាមួយសិស្ស អំពីហេតុការណ៍ដែលបានកើតឡើង។<br>• ណែនាំឲ្យសិស្សសរសេរសំបុត្រសូមទោសចំពោះជនរងគ្រោះ បុគ្គលិក និងនាយកសាលា; ឪពុកម្តាយ ចុះហត្ថលេខាលើសំបុត្រនោះ។<br>• បញ្ជូនសិស្សទៅសាលាក្តីសម្រាប់ក្មេងជំទង់ (កន្លែងដែលមាន)។<br>• ឃាត់សិស្សមិនឲ្យចេញទៅផ្ទះ ក្រោយម៉ោងសិក្សា។<br>• ជួបជាមួយ សិស្ស/ឪពុកម្តាយ។<br>• ចាត់សិស្ស ឲ្យមានការនាំសម្រុះសម្រួល ការដោះស្រាយទំនាស់, ឬបញ្ជូនសិស្សទៅផ្នែកគ្រប់គ្រងកំហឹង (កន្លែងដែលសមរម្យ)។<br>• ផ្អាកមិនឲ្យសិស្សមានបុព្វសិទ្ធិគ្រប់យ៉ាងនៅក្នុងសាលា។<br>• ប្តូរសិស្សឲ្យទៅថ្នាក់ផ្សេង (ថ្នាក់ដែលសមរម្យ)។<br>• បញ្ជូនសិស្សទៅក្នុងកម្មវិធី SMART ។ |

| | |
|---|---|
| | • បញ្ឈប់សិស្សមិនឲ្យរៀនបណ្ដោះអាសន្ន ប៉ុន្តែឲ្យនៅក្នុងសាលា។<br>• បញ្ឈប់សិស្សមិនឲ្យមករៀនបណ្ដោះអាសន្ន (ក្នុងលក្ខណៈ ដែលបទល្មើសមានសភាពធ្ងន់ធ្ងរ ការបញ្ឈប់សិស្សមិនឲ្យមករៀនបណ្ដោះអាសន្ន ប្រហែលជាប្រតិកម្មដំបូង ដ៏សមរម្យ)។ នៅទីនោះសិស្សត្រូវព្យួរផុតពីការសិក្សានៅក្នុងបទល្មើសជាដំបូង, សិស្សគួរតែបញ្ជូនទៅ CSAPផងដែរ។ |
| **វិន័យទី ១៣៖ ការហាមឃាត់មិនឲ្យមានការបញ្ចេញរាងកាយមិនសមរម្យ និងការប៉ះពាល់មិនសមរម្យ** | • ពិភាក្សាជាមួយសិស្ស អំពីហេតុការណ៍ដែលបានកើតឡើង។<br>• ដកហូតយករបស់នោះ។<br>• ឃាត់សិស្សមិនឲ្យចេញទៅផ្ទះ ក្រោយម៉ោងសិក្សា។<br>• ជួបជាមួយ សិស្ស/ឪពុកម្ដាយ។<br>• បញ្ជូនសិស្សទៅសាលាក្ដីសម្រាប់ក្មេងជំទង់ (កន្លែងដែលមាន)។<br>• ចាត់ឲ្យសិស្សទៅចូលរួមក្នុង ការដោះស្រាយបញ្ហា ឬក៏បញ្ជូនសិស្សទៅសេវកម្មសមហេតុផលរបស់គ្រួសារ ។<br>• ផ្អាកមិនឲ្យសិស្សមានបុព្វសិទ្ធិគ្រប់យ៉ាងនៅក្នុងសាលា។<br>• បញ្ជូនសិស្សទៅក្នុងកម្មវិធី SMART ។<br>• បញ្ឈប់សិស្សមិនឲ្យរៀនបណ្ដោះអាសន្ន ប៉ុន្តែឲ្យនៅក្នុងសាលា។<br>• បញ្ឈប់សិស្សមិនឲ្យមករៀនបណ្ដោះអាសន្ន (ចម្លើយដ៏សមហេតុផល ដែលរួមជាមួយ នឹងការបញ្ជូនទៅសេវកម្មឧបត្ថម្ភសមហេតុសមផលរបស់គ្រួសារ និង CSAP)។ |

| **វិន័យកម្រិត១ និងការធ្វើអន្តរាគមន៍<br>ថ្នាក់ទី ៥-១២** | |
|---|---|
| **វិន័យ** | **អន្តរាគមន៍ក្នុងថ្នាក់រៀន** |
| **វិន័យទី ១៤៖ ការហាមឃាត់ មិនឲ្យមានប្រើគ្រឿងថ្នាំជក់** | • ពិភាក្សាជាមួយសិស្សអំពី ហេតុការណ៍ដែលបានកើតឡើង។<br>• ដកហូតយករបស់នោះ។<br>• ឃាត់សិស្សមិនឲ្យចេញទៅផ្ទះ ក្រោយម៉ោងសិក្សា។<br>• ជួបជាមួយ សិស្ស/ឪពុកម្ដាយ។<br>• បញ្ជូនសិស្សឲ្យទៅក្នុងកម្មវិធីព្យាបាលគ្រឿងញៀន (កន្លែងដែលសមរម្យ)។<br>• បញ្ជូនសិស្សទៅសាលាក្ដីសម្រាប់ក្មេងជំទង់ (កន្លែងដែលមាន)។<br>• វាយតម្លៃសិស្សសម្រាប់ការធ្វើអន្តរាគមន៍ CSAP កម្រិតទី II ។<br>• ផ្អាកមិនឲ្យសិស្សមានបុព្វសិទ្ធិគ្រប់យ៉ាងនៅក្នុងសាលា។<br>• បញ្ជូនសិស្សទៅក្នុងកម្មវិធី SMART ។<br>• បញ្ឈប់សិស្សមិនឲ្យរៀនបណ្ដោះអាសន្ន ប៉ុន្តែឲ្យនៅក្នុងសាលា។<br>• បញ្ឈប់សិស្សមិនឲ្យមករៀនបណ្ដោះអាសន្ន។ |

<table>
<tr><td>វិន័យទី ១៥៖ ការហាមឃាត់ មិនឲ្យមានប្រើគ្រឿងញៀន និងស្រវឹង</td><td>• ដកហូតយករបស់នោះ។<br>• ពិភាក្សាជាមួយសិស្សអំពី ហេតុការណ៍ដែលបានកើតឡើង។<br>• បញ្ជូនសិស្សទៅ C&E (បើសិនជាមាន) តាម CSAP។<br>• ណែនាំឲ្យសិស្សសរសេរពំពីការប្រើប្រាស់គ្រឿងញៀន និងគ្រឿងស្រវឹង នឹងការប្រើ គ្រឿងញៀន និងគ្រឿងស្រវឹង ហួសចំណុះ។<br>• ឃាត់សិស្សមិនឲ្យចេញទៅផ្ទះ ក្រោយម៉ោងសិក្សា។<br>• បញ្ជូនសិស្ស ឲ្យទៅក្នុងកម្មវិធីព្យាបាលគ្រឿងញៀន។<br>• ជួបជាមួយសិស្ស/ឳពុកម្តាយ និងបុគ្គលិករបស់សាលា។<br>• បញ្ជូនសិស្សទៅ អន្តរាគមន៏ផ្នែក CSAP TIER ជាន់ទី២ ហើយឲ្យមានទំនាក់ទំនង ទៅ ការឲ្យតំលៃ D&A (ត្រូវមានការអនុញ្ញាតិពីមាតាបិតា)។<br>• ផ្អាកមិនឲ្យសិស្សមានបុព្វសិទ្ធិគ្រប់យ៉ាងនៅក្នុងសាលា។<br>• បញ្ជូនសិស្សទៅក្នុងកម្មវិធី SMART ។<br>• បញ្ឈប់សិស្សមិនឲ្យរៀនបណ្តោះអាសន្ន ប៉ុន្តែឲ្យនៅក្នុងសាលា។<br>• បញ្ឈប់សិស្សមិនឲ្យមករៀនបណ្តោះអាសន្ន។</td></tr>
</table>

<table>
<tr><th colspan="2">វិន័យកម្រិត២ និងការធ្វើអន្តរាគមន៍<br>ថ្នាក់កុមារដ្ឋាន–ថ្នាក់ទី៨</th></tr>
<tr><th>វិន័យ</th><th>អន្តរាគមន៍ក្នុងថ្នាក់រៀន</th></tr>
<tr><td>វិន័យទី ១៦៖ ការប្រព្រឹត្តល្មើសលើក្រម ម្តងហើយ ម្តងទៀត<br>សម្គាល់៖ មិនមែនជាបទល្មើសទេ ប្រសិនបើសាលាមិនបាន ធ្វើអន្តរាគមន៍តបទៅនឹងបទល្មើសនីមួយៗជាបន្ទាន់។</td><td>ប្រសិនបើសាលារៀនមានផ្តល់ និងកត់ទុកឯកសារត្រឹមត្រូវ សំរាប់ធ្វើអន្តរាគមន៍ រួមទាំង CSAP TIER ជាន់ទី២, សិស្សអាចត្រូវស្នើឲ្យប្តូរសាលារៀន តាមពាក្យ EH-21។</td></tr>
<tr><td>វិន័យទី ១៧៖ ហាមបំផ្លាញ និង លួច ទ្រព្យសម្បត្តិ</td><td rowspan="11">បញ្ឈប់សិស្សមិនឲ្យមករៀនបណ្តោះអាសន្ន និង ស្នើឲ្យសិស្សប្តូរសាលារៀន ឬបណ្តេញមិនឲ្យចូលសាលា តាមពាក្យ EH-21។</td></tr>
<tr><td>វិន័យទី ១៨៖ ហាម សម្លុតធ្វើបាប/សម្លុតតាមកុំព្យូទ័រ</td></tr>
<tr><td>វិន័យទី ១៩៖ ហាម ប៉ះពាល់លូកលាន់លើផ្លូវភេទ</td></tr>
<tr><td>វិន័យទី ២០៖ ហាម រួមភេទ ដោយស្ម័គ្រចិត្ត +</td></tr>
<tr><td>វិន័យទី ២១៖ ហាម រួមភេទ ដោយបង្ខំ</td></tr>
<tr><td>វិន័យទី ២២៖ ហាម វាយតប់ បុគ្គលិករបស់សាលា</td></tr>
<tr><td>វិន័យទី ២៣៖ ហាម ជំរុញការវាយតប់</td></tr>
<tr><td>វិន័យទី ២៤៖ ហាម លួចប្លន់</td></tr>
<tr><td>វិន័យទី ២៥៖ ហាម មិនឲ្យមានអាវុធ</td></tr>
<tr><td>វិន័យទី ២៦៖ ហាម ចែកចាយគ្រឿងញៀន ឬ គ្រឿងស្រវឹង</td></tr>
<tr><td>វិន័យទី ២៧៖ ហាម ធ្វើឲ្យជនណាម្នាក់ស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់</td></tr>
</table>

# ផ្នែកទី៤. វិធីរៀបរាប់ពីវិន័យ

## ៤.១ វិធីរៀបរាប់អំពីការព្យួរទោសមិនឲ្យរៀន ចំនួនបីថ្ងៃ ឬតិចជាង

៤.១.១. សិស្សណាដែលទទួលការព្យួរទោសនេះ ត្រូវទៅជួបប្រជុំជាមួយនាយកសាលា ឬអ្នកតំណាងរបស់គាត់ មុនពេលទទួលទោស។ នៅក្នុងអង្គប្រជុំ, សិស្សត្រូវ៖

ក. ទទួលការពន្យល់អំពីអំពើល្មើសច្បាប់ និងការបញ្ជាក់ពិនិត្យអំពីបញ្ហាជុំវិញនៃការល្មើសផ្សេងៗ;
ខ. អនុញ្ញាតិឲ្យឆ្លើយ ចំពោះពាក្យចោទប្រកាន់ទាំងឡាយ បើសិស្សមិនទាន់បានធ្វើនៅឡើយទេ;
គ. ទទួលព័តមានអំពីវិធានការ នៃសេចក្តីស្នើសុំឲ្យមានការដោះស្រាយបញ្ហា; និង
ឃ. ទទួលព័តមានអំពីផលវិបាក នៃអំពើល្មើសច្បាប់ទៅថ្ងៃក្រោយ។

៤.១.២ ក្រោយពីជួបប្រជុំជាមួយសិស្ស នាយកសាលា ឬអ្នកតំណាងរបស់គាត់ ត្រូវអនុវត្តនូវសេចក្តីស្នើពីការដោះស្រាយ ហើយនិងផ្ញើសំបុត្រអំពីការដាក់វិន័យ ទៅជូនមាតាបិតា ដើម្បីជំរាបគាត់ឲ្យដឹងពីបទល្មើសរបស់សិស្ស ចំនួននៃការព្យួរទោសមិនឲ្យរៀន និងអំពីថ្ងៃដែលមាតាបិតា/អណាព្យាបាល ត្រូវជូនសិស្សត្រឡប់ទៅចុះឈ្មោះចូលរៀនវិញ។

## ៤.២ វិធីរៀបរាប់អំពីការព្យួរទោសមិនឲ្យរៀន ចំនួនបីថ្ងៃ ឬច្រើនជាង

សិស្សណាដែលទទួលការព្យួរទោសចំនួនបីថ្ងៃ ឬច្រើនជាងនេះ ត្រូវធ្វើទៅតាមវិធីរៀបរាប់ ដូចមានចែងនៅផ្នែក ៤.១ ខាងលើ។ ជាបន្ថែមទៀត មាតាបិតា/អណាព្យាបាល ត្រូវទៅជួបប្រជុំដើម្បីពិភាក្សាអំពីអំពើល្មើសច្បាប់ ព្រមទាំងពីវិធីផ្សេងៗសំរាប់ការពារកុំឲ្យមានការល្មើសច្បាប់នៅថ្ងៃក្រោយទៀត។

## ៤.៣ វិធីរៀបរាប់អំពីការប្តូរសាលា សំរាប់សិស្ស ពីថ្នាក់មត្តេយ្យ ដល់ទី៤

៤.៣.១ សិស្សណាបានប្រព្រឹត្តបទល្មើសណាមួយ ដែលតម្រូវឲ្យដូរទៅសាលាមួយទៀត នឹងត្រូវទទួលាការព្យួរទោសមិនឲ្យរៀន ហើយត្រូវធ្វើទៅតាមវិធីដែលមានចែងខាងលើ ផ្នែកទី ៤.១ និង ៤.២។ ជាបន្ថែមទៀត នៅក្នុងអង្គប្រជុំជាមួយមាតាបិតា សេចក្តីពិនិត្យសើរើអំពីការប្រព្រឹត្តិនៃអាកប្បកិរិយា នឹងត្រូវលើកយកមកពិភាក្សា។

៤.៣.២. មុននឹងបញ្ជូនសិស្សទៅសាលាមួយទៀត សិស្សត្រូវទៅស្តាប់ពីការតវ៉ាក្រៅផ្លូវការ ដែលត្រូវ៖

ក. ប្រព្រឹត្តិទៅក្រោមការដឹកនាំរបស់សមាជិកនៃការិយាល័យផ្លាស់ប្តូរនិងការសិក្សាម្យ៉ាងទៀត ហើយនិង
ខ. ផ្តល់ពេលឲ្យមាតាបិតា/អាណាព្យាបាលធ្វើការពិនិត្យសើរើ ពីឯកសាររបស់សិស្ស ភ័ស្តុតាង និងសាក្សីថ្មីៗ ហើយនិង អាចសួរសំនួរដល់សាក្សីពីក្រសួងអប់រំ បើគាត់នៅទីនោះ។

៤.៣.៣. ការិយាល័យផ្លាស់ប្តូរនិងការសិក្សាម្យ៉ាងទៀត ត្រូវធ្វើការសំរេច ថាតើការផ្លាស់ប្តូរនេះ មានលក្ខណៈត្រឹមត្រូវឬទេ។ បើការផ្លាស់ប្តូរមានលក្ខណៈត្រឹមត្រូវ សិស្សនឹងត្រូវផ្លាស់សាលាជាចាំបាច់។

## ៤.៤ វិធីរៀបរាប់អំពីការប្តូរទៅសាលាដ៏ទៃទៀត សំរាប់សិស្ស ពីថ្នាក់ទី ៥ ដល់ទី ១២

៤.៤.១ សិស្សណាដែលបានប្រព្រឹត្តល្មើសច្បាប់ ដែលត្រូវប្តូរទៅសាលាម្យ៉ាងទៀត នឹងត្រូវទទួលការព្យួរទោសមិនឲ្យរៀន ហើយនិងត្រូវធ្វើទៅតាមច្បាប់ ដូចមានចែងតាមវិធីផ្នែកទី ៤.២ ខាងលើ។ ជាបន្ថែមទៀត នៅក្នុងអង្គប្រជុំជាមួយមាតាបិតា ការពិនិត្យសើរើអំពីការប្រព្រឹត្តនៃអាកប្បកិរិយា នឹងត្រូវលើកយកមកពិភាក្សា។

៤.៤.២. ការិយាល័យផ្លាស់ប្តូរនិងការសិក្សាម្យ៉ាងទៀត ត្រូវធ្វើការសំរេច ថាតើការផ្លាស់ប្តូរនេះ មានលក្ខណៈត្រឹមត្រូវឬទេ ហើយត្រូវប្រាប់ទៅមាតាបិតា/អណាព្យាបាល អំពីការសំរេចនេះ។

៤.៤.៣. ជាបន្ថែមទៀត សិស្សត្រូវចូលរួមក្នុងការតវ៉ាមួយ ដែលត្រូវ៖

ក. ប្រព្រឹត្តទៅក្រោមការដឹកនាំរបស់ភ្នាក់ងារតវ៉ាដាច់ឡែកម្នាក់;

ខ. ផ្តល់ឲ្យមាតាបិតា/អណាព្យាបាល ធ្វើការពិនិត្យសើរើ ពីឯកសាររបស់សិស្ស ភ័ស្តុតាង និងសាក្សីថ្មីៗ ហើយនិងអាចសួរសំនួរដល់សាក្សីពីក្រសួងអប់រំ បើគាត់នៅទីនោះ។

## ៤.៥ វិធីរៀបរាប់អំពី ការដេញសិស្សចេញពីសាលារៀន

៤.៥.១. សិស្សណាដែលបានប្រព្រឹត្តល្មើសច្បាប់ ដែលតម្រូវឲ្យមានការបណ្តេញចេញពីសាលារៀន សិស្សនោះត្រូវទទួលការព្យួរទោស និងត្រូវធ្វើទៅតាមច្បាប់ផ្នែកទី ៤.២ ដូចបានរៀបរាប់ពីខាងលើដែរ។

៤.៥.២. ការិយាល័យផ្លាស់ប្តូរនិងការសិក្សាម្យ៉ាងទៀត ត្រូវប្តូរសិស្សទៅសាលាម្យ៉ាងទៀត ហើយផ្តល់យោបល់ជូនមាតាបិតា/អណាព្យាបាល អំពីការសំរេចរបស់ក្រសួង យោងទៅលើសេចក្តីរង់ចាំពីការតវ៉ានៃការដេញសិស្សចេញពីសាលារៀន។

៤.៥.៣. ជាបន្ថែមទៀត សិស្សត្រូវចូលរួមក្នុងការតវ៉ានៃការដេញសិស្សចេញ ដែលនឹងត្រូវដឹកនាំដោយភ្នាក់ងារតវ៉ាដោយឡែកម្នាក់ ដែលបានទទួលការចាត់តាំងឡើង ដោយគណកម្មការកែទំរង់សាលារៀន។ សិស្ស៖

ក. អាចមានអ្នកតំណាងសំរាប់ផ្តល់យោបល់ម្នាក់ ទៅតាមការចំណាយរបស់មាតាបិតា;

ខ. មានសិទ្ធិទទួលដំណឹងពីឈ្មោះនៃសាក្សីដើមចោទដល់សិស្ស ហើយនិងពាក្យចម្លងអំពីសេចក្តីចោទប្រកាន់ ព្រមទាំងពាក្យចោទជាផ្លូវការរបស់សិស្សទាំងនោះផង;

គ. មានសិទ្ធិស្នើសុំឲ្យសាក្សីបង្ហាញខ្លួន និងឆ្លើយចំពោះសំនួរផ្សេងៗ ឬទទួលការសាកសួរតពីដីកាម្ខាងទៀត;

ឃ. មានសិទ្ធិក្នុងការសំដែងឲ្យឃើញ និងបង្ហាញពីសាក្សីរបស់ខ្លួន ឬតំណាងរបស់ខ្លួន។

## ៤.៦ វិធីរៀបរាប់អំពី វិន័យសំរាប់សិស្សសិក្សាពិសេស

៤.៦.១. <u>ការព្យួរទោសមិនឲ្យរៀនសំរាប់សិស្សសិក្សាពិសេស ផ្នែកឃឹតឃូរខាងការចំរើនខួរក្បាល</u>។ ក្រសួងអាចធ្វើការព្យួរទោសមិនឲ្យរៀន ដល់សិស្សផ្នែកឃឹតឃូរខាងការចំរើនខួរក្បាល ដោយមាន (ក) សេចក្តីយល់ព្រមជាលាយល័ក្ខអក្សរ ពីមាតាបិតា ឬ (ខ) នៅក្នុងករណីអាសន្ន ដោយសិស្សអាចធ្វើឲ្យមានគ្រោះថ្នាក់ដល់ខ្លួនឯង ឬដល់អ្នកដទៃ ហើយនិង ដោយមានសេចក្តីអនុញ្ញាតិពីការិយាល័យ នៃក្រសួងអប់រំប្រចាំរដ្ឋផិនស៊ីលវេនីញ៉ា។

៤.៦.២. <u>ការព្យួរទោសមិនឲ្យរៀន ការបណ្តេញចេញពីសាលារៀន និងការផ្លាស់ប្តូរ សំរាប់សិស្សសិក្សាពិសេសផ្សេងទៀត</u>។ ក្រសួង អាចធ្វើការព្យួរទោសមិនឲ្យរៀន ដល់សិស្សពិការភាព ហើយថែមទាំងអាចបញ្ឈប់ការផ្តល់សិក្សាមិនឲ្យសិស្សរៀន ចំនួន៥ថ្ងៃជាប់គ្នា ឬ១៥ថ្ងៃនៃថ្ងៃសិក្សា ក្នុងកំលុងមួយឆ្នាំ ដោយមិនចាំបាច់ផ្តល់មធ្យោបាយដោះស្រាយផ្នែកសិក្សាពិសេស។

ក. ក្រសួងអាចផ្តល់មធ្យោបាយដោះស្រាយផ្សេងៗ ទៅឲ្យសិស្សដែលត្រូវទទួលការបណ្តេញចេញមិនឲ្យចូលសាលា ទទួលការផ្លាស់ប្តូរទៅសាលាម្យ៉ាងទៀត យោងទៅតាមមូលហេតុផ្នែកវិន័យ ឬដាក់ព្យួរទោសសិស្សមិនឲ្យរៀនចំនួន៥ថ្ងៃជាប់គ្នា ឬច្រើនជាងនេះ ឬក៏ចំនួន១៥ថ្ងៃក្នុងមួយឆ្នាំ៖

១. កំណត់ពាក្យជាលាយល័ក្ខអក្សរមួយ នឹងផ្ញើជូនមាតាបិតា/អាណាព្យាបាល ជំរាបអំពីសេចក្តីស្នើ ដាក់ទណ្ឌកម្ម និងថ្ងៃខែនៃអង្គប្រជុំស្តីអំពីកម្មវិធីសំរាប់បុគ្គលម្នាក់ៗ (Individualized Education Program – IEP);

២. ក្រុមមួយ ត្រូវរៀបចំអង្គប្រជុំសំរាប់ធ្វើការសំរេច ក្នុងកំលុង២៤ម៉ោង ក្រោយពីអំពើល្មើសច្បាប់ ដោយមានអញ្ជើញមាតាបិតាមកចូលរួមប្រជុំផង;

៣. នៅក្នុងអង្គប្រជុំ IEP នេះ ក្រុម IEP ត្រូវពិនិត្យសើរើអំពីការឲ្យតម្លៃដល់សិស្សថ្មីៗ អំពី IEP និង អំពីការចាត់តាំងបញ្ជូនសិស្ស ដើម្បីបញ្ជាក់ឲ្យច្បាស់ថា តើអាកប្បកិរិយាល្មើសច្បាប់របស់សិស្ស មានទាក់ទងដល់ពិការភាពរបស់សិស្សដែរឬទេ។ ការប្រព្រឹត្តល្មើសច្បាប់ មិនអាចចាត់ទុកថាទាក់ទងទៅនឹងភាពពិការរបស់សិស្សទេ ប្រសិនបើ (១) IEP ថ្មីៗ មានសភាពសមរម្យ និងកំពុងដាក់ឲ្យធ្វើ និង (២) ភាពពិការមិនអាចធ្វើឲ្យសិស្សមិនយល់ដល់ផលវិបាកនៃអំពើ និងការត្រួតត្រាដល់អាកប្បកិរិយារបស់ខ្លួនឡើយ។

**៤. ប្រសិនបើអាកប្បកិរិយា របស់សិស្ស មិនមែនជាសេចក្តីសំដែងនូវភាពពិការរបស់ខ្លួនទេ, បុគ្គលិកសិក្សាទាំងឡាយ អាចប្រើច្បាប់ផ្នែកវិន័យជាឯកច្ឆ័ន្ទ, ដោយមានយោងទៅលើការសិក្សាពិសេស និងឯកសារផ្នែកវិន័យ របស់សិស្ស។ ទោះជាក្នុងករណីណាក៏ដោយ, សិស្សមិនអាចទទួលការព្យួរទោសមិនឲ្យរៀនលើសពី ប្រាំថ្ងៃជាប់គ្នា ឬលើសពីដប់ប្រាំថ្ងៃទេក្នុងមួយឆ្នាំ។ NOREP មួយត្រូវរៀបចំសំរាប់ឲ្យសិស្សក្រោយពីលទ្ធផលនៃការសំរេចចុងក្រោយ។**

**៥. ក្រុម IEP ត្រូវធ្វើការពិនិត្យសើរើ និងរៀបចំឡើងវិញ, បើសិនជាការចាំបាច់, អំពីគំរោងការការពារផ្នែកអាកប្បកិរិយា ឬ, យោងទៅតាមសេចក្តីត្រូវការ, ធ្វើការឲ្យតំលៃពេញលេញអំពីការប្រព្រឹត្តិទៅនៃអាកប្បកិរិយា និងគំរោងការការពារដែលមានរៀបរាប់ពីអំពើល្មើសរបស់សិស្ស;**

៦. ក្រុម IEP ត្រូវធ្វើសេចក្តីសំរេច អំពីសភាពសមរម្យនៃការចាត់តាំងការសិក្សាម្យ៉ាងទៀត, ដូចបានបញ្ជាក់មកហើយ, ដោយមានរួមបញ្ចូលនៅក្នុង IEP អំពីជំនួយផ្សេងៗ និងសេចក្តីកែតំរូវ ដែលនឹងអាចឲ្យសិស្សបន្តការចូលរួមក្នុងការសិក្សា ព្រមទាំងរៀបបញ្ជាក់អំពីអាកប្បកិរិយាសមរម្យ ដើម្បីកុំឲ្យមានអំពើល្មើស កើតឡើងទៀតទៅអនាគត;

៧. ក្រុម IEP ត្រូវបញ្ចេញ NOREP ដោយមានលទ្ធផលអំពីសេចក្តីសំរេចចុងក្រោយ;

ការចាត់តាំងសិស្សផ្នែកសិក្សាពិសេស អាចផ្លាស់ប្តូរទៅតាមកន្លែងរៀបចំសិក្សាឲ្យបានសមរម្យសំរាប់សិស្ស, លើកលែងតែសិស្សមានកាន់អាវុធណាមួយទៅសាលារៀន ឬក៏ក្នុងកម្មវិធីសិក្សា ឬក៏ដឹងថាខ្លួនមានអាវុធ ឬ ប្រើឬលក់គ្រឿងញៀនខុសច្បាប់ ឬផ្សាយលក់គ្រឿងញៀន នៅក្នុងសាលា ឬនៅក្នុងកម្មវិធីសិក្សាណាមួយ។ បើមាតាបិតាស្នើសុំឲ្យមានការប្តឹងតវ៉ាមួយ, ការចាត់តាំងម្យ៉ាងទៀត ត្រូវក៏រិតទៅត្រឹមតែ៤៥ថ្ងៃប៉ុណ្ណោះ។

ក្រសួងអប់រំ អាចសុំឲ្យមានការតវ៉ា និងស្នើឲ្យភ្នាក់ងារផ្នែកតវ៉ា សុំឲ្យមានការចាត់តាំងចំនួន៤៥ថ្ងៃជាបណ្តោះអាសន្ន បើសិនជាសិស្សមានលក្ខណៈអាចធ្វើអ្វីមួយបណ្តាលឲ្យមានគ្រោះថ្នាក់ដល់ខ្លួនឯង ឬអ្នកដទៃ។

សិស្សដែលមានភាពពិការ, ទោះជាត្រូវបណ្តេញចេញពីសាលាក៏ដោយ, ត្រូវបានទទួលការសិក្សាដ៏សមរម្យ ដោយគ្មានយកថ្លៃ (FAPE)។

<u>ពិធីការសំរាប់បញ្ជូនទៅវិជ្ជាស្ថានJoseph J. Peter ខាងក្រោមនេះ គឺជាពិធីការដែលនឹងត្រូវដើរតាម បើសិនជាសិស្សបានបំពានទៅលើក្រមសីលធម៌នៃអាកប្បកិរិយាសិស្ស និង/ឬក៏បង្ហាញនូវអ្វីឲ្យឃើញថា មិនមានភាពសមរម្យ ផ្នែកខាងអាកប្បកិរិយាជាប់ទាក់ទងនឹងភេទ។ មនុស្សដែលបានឃើញនូវអាកប្បកិរិយានោះ បានជូនពត៌មានទៅនាយក-នាយិកាសាលានិងខោនសីល័រ។ ឧប្បត្តិហេតុនោះ ត្រូវរាយការណ៏ទៅការិយាល័យនៃឧប្បត្តិហេតុធ្ងន់ធ្ងរ នៃក្រសួងអប់រំក្រុង។ សាលារៀនកំណត់ថា បើសិនជាមានទង្វើវិន័យណាមួយ ដែលត្រូវធ្វើជាចាំបាច់។ ក្រសួងអប់រំទីក្រុង នឹងទាក់ទងទៅមាតាបិតា/អាណាព្យាបាល ដើម្បីជូនពត៌មានទៅពួកគាត់ អំពីឧប្បត្តិហេតុ និងទង្វើដាក់វិន័យណាមួយ។ ជំនួយជំនួបប្រជុំសិស្ស ត្រូវបានកំណត់ដើម្បីស្វែងយល់អំពីអំពីធម្មជាតិនៃសភាពការណ៏ជាមួយនិងការផ្តោតអារម្មណ៏ទៅលើអាកប្បកិរិយាដែលពិនិត្យឃើញ, និងការសំភាសដ៏ខ្លីមួយ បានធ្វើឡើងជាមួយនឹងសិស្ស ដើម្បីថ្លឹងថ្លែងអំពីការបញ្ជាក់ដ៏សំខាន់នៃការរំលោភនោះ។ ក្នុងនាមជាអ្នករាយការណ៏ដែលខានមិនបាន បើសិនជាបុគ្គលិកសាលារៀនមានមូលហេតុដ៏សមហេតុសមផល ដើម្បដាក់ការចោទប្រកាន់ទៅលើការរំលោភកុមារ និងឬក៏ត្រូវទទួលការធ្វេសប្រហែសណាមួយពីមនុស្សចាស់ក្នុងទំនាក់ទំនងអាណាព្យាបាល, DHS នឹងត្រូវជូនពត៌មាន ហើយសាលារៀននឹងជួយDHS ក្នុងជំនួបប្រជុំជាសេចក្តីត្រូវការរបស់សិស្ស។ បើសិនជាមូលហេតុសមហេតុសមផលមិនមានឬក៏មិនច្បាស់លាស់, សាលារៀននឹងទាក់ទងជាមួយការិយាល័យអាកប្បកិរិយាសុខភាពនៃតំបន់អប់រំដើម្បីពិនិត្យឡើងវិញ នូវសភាពការណ៏ហើយកំណត់ថា តើត្រូវបញ្ជូនទៅវិជ្ជាស្ថានJJPI ដើម្បីឲ្យការពិនិត្យមានភាពសមហេតុសមផល។ បើសិនជាការបញ្ជូនទៅវិជ្ជាស្ថានJJPI យល់ឃើញថាសមរម្យខោនសីល័ររបស់សាលារៀន នឹងទូរស័ព្ទទៅមាតាបិតា/អាណាព្យាបាល ដើម្បីពិភាក្សាអំពីដំណើរការនៃការពិនិត្យនោះ ហើយបញ្ជាក់ថា មាតាបិតា/អណាព្យាបានផ្តល់នូវ ការយល់ព្រមនៃការជូនពត៌មានជាលាយលក្ខណ៏អក្សរហើយ។ ក្នុងរយៈពេល៧២ម៉ោងហើយនិងជាមួយនឹងការយល់ព្រមនៃការជូនពត៌មាន, វិជ្ជាស្ថានJJPI នឹងរៀបចំនូវការពិនិត្យ ហើយទាក់ទងជាមួយសាលារៀនដើម្បីបញ្ជាក់ថាមិនមានអនុសាសន៏(មូលវិចារណ៏)ណាមួយសំរាប់ការវាយតំលៃទូលំទូលាយឬក៏បានបញ្ជាក់ថា មានមូលវិចារណ៏សំរាប់សំរាប់ការវាយតំលៃខាងមុខទៀត ហើយនិងតាមដានបន្តជាមួយគ្រួសារ។</u>

## ៤.៧ ផលវិបាកនៃយុត្តិធម៌យុវវ័យ និងយុត្តិធម៌ឧក្រិដ្ឋកម្ម សំរាប់ការបំពានទៅលើក្រមសីលធម៌នៃអាកប្បកិរិយាសិស្ស

បន្ថែមទៅលើអន្តរាគមន៏ដែលកំណត់ដោយក្រមសីលធម៌នៃអាកប្បកិរិយាសិស្ស, ជាមួយនេះដែរ បទល្មើសបានបង្កើតឥរិយាបថបំពាន និងឧក្រិដ្ឋកម្មនៅក្រោមក្រឹត្យច្បាប់នៃយុវជន នៅក្នុងច្បាប់ឧក្រិដ្ឋកម្មរបស់រដ្ឋផិនស៊ិលវ៉េនីញ៉ាជាបន្តបន្ទាប់ អាចនឹងយកសិស្សទៅកាន់សាលាជំនុំជំរះនៃតុលាការគ្រួសារ ឬក៏ឧក្រិដ្ឋកម្មមនុស្សពេញវ័យ។ សិស្សដែលបានប្រព្រឹត្តអំពើល្មើសច្បាប់នៅក្រោយគេអាយុបាន១០ឆ្នាំ និងនៅមុនគេអាយុបាន១៨ឆ្នាំ អាចយកទៅកាត់ទោសក្នុងប្រព័ន្ធយុត្តិធម៌យុវជនដូចដែលមានករណីដែលបានទទួលនៅតុលាការគ្រួសារ ដែលស្ថិតនៅ1801 Vine Street, Philadelphia ។ អំពើប្រព្រឹត្តនៅក្រោយអាយុ១៨ឆ្នាំ

ត្រូវបានធ្វើនៅតុលាការសំរាប់មនុស្សពេញវ័យ។

ដូច្នេះហើយ នៅពេលដែលសិស្សអាយុបាន១៥ឆ្នាំឬចាស់ជាងនេះ ហើយគេបានប្រព្រឹត្តការរំលោភដ៏ធ្ងន់ធ្ងរ, រំលោភដោយផ្លូវភេទ, ការរួមភេទដោយមិនមានការស្ម័គ្រចិត្ត, ការបំពានធ្ងន់ធ្ងរដោយគ្មានសីលធម៌, ជាអ្នកប្លន់, ប្រព្រឹត្តអំពើប្លន់ ឬក៏បានប្លន់ទោចក្រយានយន្ត, **ប្រើអាវុធដែលអាចសំលាប់មនុស្សបាន**, ករណីទាំងនេះត្រូវធ្វើឡើងនៅតុលាការមនុស្សពេញវ័យ។

## ៤.៨ វិធីរៀបរាប់សំរាប់សិស្ស ដែលត្រឡប់មកពីការទទួលចាត់តាំង ពីតុលាការ

នេះគឺជានយោបាយរបស់ក្រសួងអប់រំ ក្នុងការចាត់បញ្ជូនសិស្ស, ក្រោយពីត្រឡប់មកសាលារៀនវិញទៅតាមបញ្ជារបស់តុលាការផ្នែកអ្នកពឹងផ្អែក (Dependent Court Placement) ឬការចាត់តាំងក្រោយពីប្រព្រឹត្តិល្មើសច្បាប់ (Delinquent Court Placement), ឲ្យទៅរៀននៅសាលា ឬក្នុងក្នុងកម្មវិធីសិក្សាទាំងឡាយណា ដែលនឹងអាចឲ្យសិស្ស មានលទ្ធភាពអាចរៀនឲ្យបានជោគជ័យ ដោយមានសេចក្តីគិតគូរយ៉ាងហ្មត់ចត់ដល់សន្តិសុខទូទៅរបស់សហគមន៍សាលា ដែលសិស្សត្រូវត្រឡប់ទៅរៀនវិញ។

៤.៨.១. ការត្រឡប់មកពីការចាត់តាំង ក្រោយពីប្រព្រឹត្តិល្មើសច្បាប់។ មុនពេលត្រឡប់ទៅបន្ទប់រៀនវិញ, សិស្សដែលត្រូវបញ្ជូនដោយតុលាការផ្នែកអំពើល្មើសច្បាប់, ត្រូវចូលរៀនក្នុងកម្មវិធីចាប់ផ្តើមផ្លាស់ប្តូរជាដំបូង ក្នុងការស្វាគមន៍ត្រឡប់មកវិញ (RETI_WRAP)។ សិស្សត្រូវចូលរៀនក្នុងកម្មវិធីនេះ ចំនួន៤អាទិត្យ។ នៅពេលកំពុងរៀនក្នុងកម្មវិធីនេះ សិស្សនឹងត្រូវទទួលការឲ្យតម្លៃ និងឲ្យពិន្ទុ ដើម្បីធ្វើការចាត់តាំងបញ្ជូនសិស្សឲ្យបានត្រឹមត្រូវ។

៤.៨.២. ការត្រឡប់មកពីការចាត់តាំងដោយតុលាការផ្នែកអ្នកពឹងផ្អែក។ សិស្សដែលត្រឡប់មកពីការចាត់តាំងរបស់តុលាការផ្នែកអ្នកពឹងផ្អែក នឹងត្រូវបញ្ជូនទៅសាលាប្រចាំសហគមន៍ ដោយការិយាល័យផ្នែកផ្លាស់ប្តូរ និងការសិក្សាម្យ៉ាងទៀត។

# ផ្នែកទី៥. ការផ្តើមបន្ថយការឈប់ឥតច្បាប់

## ៥.១ ជំនួយដល់សេចក្តីការពារកុំឲ្យមានការឈប់ឥតច្បាប់ (Attendance &Truancy Intervention/Prevention Supports–“ATIPS”) និង ភ្នាក់ងារមាតាបិតាផ្នែកសិស្សឈប់ឥតច្បាប់ (Parent Truancy Officers–“PTO”)។

**ATIPS** គឺជាក្បួនយុទ្ធសាស្ត្រមួយបង្កើតឡើងដោយក្រសួងអប់រំ ដែលមានរួមបញ្ចូលសមាជិកពីក្រុមសហគមន៍ផ្សេងៗ, ក្រុមប្រចាំតំបន់, សហគមន៍ខាងសាសនា, មាតាបិតា និង សមាជិកដ៏ទៃទៀត នៃសហគមន៍ ដើម្បីជួយធ្វើការក្នុងការជួយសិស្សឲ្យទៅរៀនបានរៀងរាល់ថ្ងៃ និងជួយបន្ថយការឈប់ឥតច្បាប់នៅតាមសាលាទូទៅក្នុងក្រុង។ ក្រសួងយល់ឃើញថា ការឈប់ឥតច្បាប់ គឺជាសញ្ញាដំបូងប្រាប់ឲ្យដឹងថា សិស្សត្រូវការការរារាំង ដែលនឹងអាចជួយផ្តល់អំណាច និងផ្តល់ជំនួយគ្រប់បែបយ៉ាងដល់គ្រួសារទាំងឡាយ សំរាប់រៀបចំការរស់នៅក្នុងជីវិត។

**ATIPS** បានបង្កើតឡើងដោយសម្ព័ន្ធដែលមានរួចមកហើយ ដើម្បីធ្វើការរារាំងដល់សិស្សនិងគ្រួសារ កុំឲ្យធ្លាក់ទៅដល់តុលាការផ្នែកការឈប់ឥតច្បាប់, ជាទូទៅ បើសិស្សបានឈប់ឥតច្បាប់ចំនួន៣ដង ឬច្រើនជាង។ ក្រុមភ្នាក់ងារមាតាបិតាផ្នែកឈប់ឥតច្បាប់ នឹងដើរទៅតាមផ្ទះគ្រួសាររបស់សិស្ស ហើយនិងផ្តល់ជូននូវព័តមានអំពីនយោបាយរបស់ក្រសួង ផ្នែកការទៅរៀនឲ្យបានទៀងទាត់, ការសិក្សាជាការចាំបាច់, និងប្រភពជំនួយ ទៅតាមសេចក្តីត្រូវការ។

## ៥.២ កម្មវិធីបោសសំអាតនៃការឈប់ឥតច្បាប់ (Truancy Sweep Program)។

កម្មវិធីនេះនឹងធ្វើការរារាំងដល់ជីវិតរបស់សិស្សណាដែលសំរេចចិត្តឈប់មិនទៅសាលា ហើយនិងសំរាប់ជួយបញ្ចូលសិស្សទាំងនេះ ទៅក្នុង បរិដ្ឋានរបស់សាលារៀនវិញ។ ការបោសសំអាត ដល់ការឈប់ឥតច្បាប់ បានរៀបចំប្រព្រឹត្តិទៅ ដោយការរួមដៃគ្នារវាងតំរួតប្រចាំក្រុង និងតំរួត SEPTA។

**៥.៣ មជ្ឈមណ្ឌលនៃការឈប់ឥតច្បាប់** (Truancy Centers)។ សព្វថ្ងៃនេះ ក្រសួងមានមជ្ឈមណ្ឌលជំនួយដល់ការឈប់ឥតច្បាប់ពីរកន្លែង។ មណ្ឌលទាំងនេះ បានធ្វើការយ៉ាងជិតស្និទ្ធជាមួយកម្មវិធីបោសសំអាត ហើយនិងជាកន្លែងសំរាប់ទទួលសិស្សរាប់ពាន់នាក់ ដែលត្រូវតំរួតនាំយកមក ពីតាមផ្លូវនានានៅក្នុងក្រុង។

# ផ្នែកទី៦. គោលនយោបាយ

## ៦.១ នយោបាយមិនប្រកាន់ និងមិនរំខានយាយី

ក្រសួងបានរក្សាយ៉ាងមាំមួន នូវនយោបាយដែលមិនអនុញ្ញាតិឲ្យមានការប្រកាន់ និងរំខានយាយី។ ផ្នែកនៃច្បាប់នេះបានបង្កើតឡើងសំរាប់គ្រាន់តែផ្តល់ព័តមានសង្ខេបខ្លីៗរបស់នយោបាយទាំងមូល។ លោកអ្នក អាចអាននយោបាយទាំងមូលនេះ តាមwww.phila.k12.pa.us។

សិស្សទាំងអស់ មានសិទ្ធិក្នុងបរិដ្ឋានសិក្សាមួយដែលគ្មានការរំខាន និងការប្រកាន់។ ការរំខានយាយី មានន័យថា ជាការទាមទារក្នុងផ្លូវកាម ឬអំពើណាមួយដែលរំខានយាយី, គំរាម, កំហែង ឬក៏បង្កើតឲ្យមានបរិយាកាសច្រួលច្របល់នៅសាលារៀន ពីព្រោះដោយយោងទៅលើ ភេទ, អាយុ, ពូជ, ព៌ណសម្បុរ, ភាពតំរង់តាមភេទ (ដឹង ឬយល់ឃើញ), ការបញ្ចេញពីលក្ខណៈខាងភេទ (ដឹង ឬយល់ឃើញ), ប្រភពសញ្ជាតិ, សាសនា, ភាពពិការ, ឋានៈក្នុងសេដ្ឋកិច្ចនៃសង្គម និង/ឬជំនឿផ្នែកនយោបាយ។ ការប្រកាន់ មានន័យថា ជាការរាប់អានអ្នកណាម្នាក់ខុសពីគេ ដោយយោងទៅតាម ភេទ, អាយុ, ពូជ, ព៌ណសម្បុរ, ភាពតំរង់តាមភេទ (ដឹង ឬយល់ឃើញ), ការបញ្ចេញពីលក្ខណៈខាងភេទ (ដឹង ឬយល់ឃើញ), ប្រភពសញ្ជាតិ, សាសនា, ភាពពិការ, ឋានៈក្នុងសេដ្ឋកិច្ចនៃសង្គម និង/ឬជំនឿផ្នែកនយោបាយ។ បញ្ជីរៀបរាប់ពីមុននេះ មិនបានរៀបរាប់គ្រប់ទាំងអស់ទេ។

បើសិស្សណាមួយយល់ដឹងថាខ្លួនជាអ្នករងគ្រោះ ដោយសារការប្រកាន់ ឬការរំខានយាយី, សិស្សនេះត្រូវធ្វើសេចក្តីរាយការណ៍ពីអាកប្បកិរិយាទាំងនេះ ទៅតាមសេចក្តីរៀបរាប់ តាមផ្នែក ៦.២ ខាងក្រោម។ ដោយមានសេចក្តីតវ៉ានេះ, ក្រសួងត្រូវធ្វើសេចក្តីស៊ើបអង្កេតពីពាក្យបណ្តឹងឲ្យបានហ្មត់ចត់ និងពេញលេញ។ យោងទៅតាមលទ្ធភាព និងសេចក្តីរបស់ច្បាប់, ក្រសួងត្រូវរក្សាការសម្ងាត់ នៅក្នុងរង្វង់នៃការស៊ើបអង្កេត ឬអាកប្បកិរិយាល្មើសច្បាប់។ ក្រុមដើមចោទនិងចុងចោទ នឹងត្រូវទទួលការរាប់រកដោយភាពថ្លៃថ្នូរ ហើយក្រសួងមិនត្រូវធ្វើការសងសឹកទៅលើជនណាមួយ ដែលធ្វើរបាយការណ៍ទេ។

នយោបាយខាងលើនេះ មិនអាចឃាត់មិនឲ្យសិស្សធ្វើសេចក្តីរាយការណ៍ទៅតំរួត ប្រសិនបើអំពើល្មើសដែលកើតឡើង មានទាក់ទងទៅឧក្រិដ្ឋកម្ម។

បើសិស្សណាម្នាក់មានសំនួរផ្សេងៗ អំពីនយោបាយមិនរំខាន, សិស្សអាចទាក់ទងទៅនាយកសាលា ឬនាយកតំបន់សិក្សា។

## ៦.២ នយោបាយនៃការតវ៉ា/ពាក្យបណ្តឹង

៦.២.១. វិធិរៀបរាប់ពាក្យបណ្តឹងក្រៅផ្លូវការ

ក. បើសិស្សណាម្នាក់មានជំនឿថា ខ្លួនបានទទួលការរំខានយាយី ឬការប្រកាន់ ឬក៏ដឹងពីរឿងអ្នកណាម្នាក់ដែលបានទទួលការរំខានយាយី ឬប្រកាន់, សិស្សនេះគួរតែទាក់ទងប្រាប់ទៅនាយកសាលារៀន ដើម្បីរាយការណ៍ពីសកម្មភាពនេះ។

ខ. បើសិនជានាយកសាលាបានទទួលការចោទប្រកាន់ថាជាអ្នកធ្វើការរំខានយាយី ឬប្រកាន់ ឬក៏សិស្សយល់ថា នាយកសាលាជាអ្នកទទួលខុសត្រូវដល់ការរំខានយាយី ឬប្រកាន់, សិស្សនេះគួរតែធ្វើសេចក្តីរាយការណ៍ អំពីសកម្មភាពនេះទៅ នាយកតំបន់សិក្សា នៅការិយាលប្រចាំតំបន់។

៦.២.២. នយោបាយអំពីការគំរាមកំហែងជាផ្លូវការ។ ក្រសួងមានវិធីរៀបរាប់ផ្នែកការគំរាមមួយ សំរាប់ឲ្យសិស្សធ្វើសេចក្តីរាយការណ៍ អំពីការរំខានយាយី, ការប្រកាន់ ឬ ការគំរាមកំហែង ដែលបានប្រព្រឹត្តិទៅដោយសមាជិកនៃសហគមន៍សាលាណាមួយ។ សន្លឹកខាងក្រោយនៃច្បាប់ មានពាក្យមួយសំរាប់ឲ្យសិស្ស ដែលមានជំនឿថា ខ្លួនគេត្រូវបានទទួលការរំខានយាយី, ប្រកាន់, ឬគំរាមកំហែង ដោយសមាជិកនៃសហគមន៍របស់សាលារៀន។ ជាបន្ថែមទៅលើវិធីរៀបរាប់នេះ, សិស្សតែងបានទទួលការរំលឹកដាស់តឿន ឲ្យធ្វើសេចក្តីរាយការណ៍អំពីសភាពល្មើសច្បាប់ទាំងអស់ ដោយទូរស័ព្ទតាម Bully Hotline ឬទៅនាយកសាលា ឬអ្នកតំណាងប្រចាំក្រសួងអប់រំណាម្នាក់។ សេចក្តីរៀបរាប់ខាងក្រោម គឺជាពាក្យចម្លងនៃវិធីដែលត្រូវធ្វើ ៖

ក. អ្នកតវ៉ាធ្វើសេចក្តីរាយការណ៍ទៅនាយកសាលា, អ្នកតំណាងនាយកសាលា ឬអ្នកតំណាងក្រសួងអប់រំ, ហើយនឹងត្រូវបានទទួលរបាយការណ៍ពីពាក្យតវ៉ា។

ខ. អ្នកតវ៉ាបំពេញពាក្យរាយការណ៍នៃការតវ៉ា។ បើអ្នកតវ៉ាត្រូវការ ឬធ្វើសេចក្តីស្នើសុំជំនួយ ក្នុងការបំពេញពាក្យនេះ, សាលារៀន ឬការិយាល័យដែលទទួលពាក្យ ត្រូវរៀបចំផ្តល់ការបកប្រែជូនដោយសមរម្យ។

គ. ពាក្យចម្លងនៃពាក្យតវ៉ា ដែលមានចុះហត្ថលេខា ត្រូវមានជូនទៅអ្នកតវ៉ា ដោយបុគ្គលិកនៃក្រសួងអប់រំ។

ឃ. ពាក្យចម្លងមួយទៀត ត្រូវមានជូនទៅនាយកសាលារៀន។

ង. នាយកសាលា ត្រូវធ្វើការស៊ើបអង្កេតមួយ ក្នុងកម្លុង៤៨ម៉ោង ហើយនិងត្រូវមានចាត់វិធានការឲ្យបានត្រឹមត្រូវ។

ច. នាយកសាលាត្រូវធ្វើសេចកតីរាយការណ៍អំពីព្រឹត្តិការណ៍ដ៏ធ្ងន់ធ្ងរមួយ, ហើយនិងត្រូវភ្ជាប់ពាក្យនៃសេចក្តីរាយការណ៍ពីការតវ៉ា ទៅនឹងពាក្យចម្លងប្រចាំសាលាលេខ EH-31, ដែលជាពាក្យបញ្ជាក់ពីសេចក្តីរាយការណ៍បន្តភ្ជាប់ពីព្រឹត្តិការណ៍ដែលបានកើតមានឡើង។

ឆ. នាយកសាលាត្រូវផ្តល់ពាក្យចម្លងនៃសេចក្តីរាយការណ៍ពីការតវ៉ាមួយ ព្រមទាំងពាក្យលេខ EH-31 ទៅនាយកចាត់ការប្រចាំក្រសួងផ្នែក Title IX។

ជ. ប្រសិនជាពាក្យចោទបានធ្វើឡើងចំពោះនាយកសាលា, នាយកតំបន់ ឬអ្នកតំណាងរបស់គាត់ ត្រូវធ្វើការស៊ើបអង្កេតមួយ ក្នុងកម្លុង៤៨ម៉ោង ហើយត្រូវចាត់វិធានការឲ្យបានត្រឹមត្រូវ។

## ៦.៣ នយោបាយនៃការឆែកឆេរកូនទូដាក់ឥវ៉ាន់នៅសាលារៀន

ក្រសួងអប់រំយល់ឃើញថា សាលារៀននិមួយៗ ត្រូវមានទីកន្លែងសំរាប់ទុកសៀវភៅ, ខោអាវ, គ្រឿងប្រដាប់ប្រដារសំរាប់សាលា និងគ្រឿងប្រើប្រាស់ផ្ទាល់ខ្លួន សំរាប់បុគ្គលម្នាក់ៗ។ ហេតុនេះហើយទើបសាលារៀន តែងមានផ្តល់កូនទូ និងទូផ្សេងៗ សំរាប់ទុកដាក់។

កូនទូទាំងអស់ ជាទ្រព្យសម្បត្តិរបស់ក្រសួងអប់រំ។ សិស្សមិនអាចប្រើកូនទូជាមួអ្នកណាមួយបានទេ, ហើយគួរតែចាក់សោរកូនទូរបស់ខ្លួន ដើម្បីកុំឲ្យសិស្សដទៃទៀត អាចបើកបាន។ ប៉ុន្តែសិស្សមិនអាចយកកូនទូ ធ្វើជាកន្លែងសំរាប់ទុកវត្ថុមានតម្លៃ ឬគ្រឿងដែលត្រូវហាមឃាត់មិនឲ្យប្រើ ឬដែលបណ្តាលឲ្យមានគ្រោះថ្នាក់ដល់សុខភាព, សន្តិសុខ ឬដល់សេចក្តីសុខសាន្ត របស់ជនគ្រប់រូប នៅសាលារៀន ឬក៏មានការខូចខាតដល់សាលារៀនផងដែរ។ សិស្សមិនអាចដូរសោរ ដែលសាលាចេញឲ្យទេ។ សាលារៀន មានរក្សាទុកនូវលេខចម្លងនៃសោរនិមួយៗ។

ក្រសួងអប់រំ នឹងចេញបញ្ជាឲ្យបុគ្គលិកសិក្សាធ្វើការឆែកឆេរកូនទូរបស់សិស្ស ប្រសិនបើគេមានការសង្ស័យ ហើយបើគេជឿថា សិស្សបានប្រើកូនទូមិនត្រឹមត្រូវ ដូចជាមានទុកដាក់គ្រឿងរត់ពន្ធដោយលួចលាក់, វត្ថុ ឬគ្រឿងប្រើប្រាស់ខុសច្បាប់, ឬក៏ប្រដាប់ប្រដារដែលអាចបណ្តាលឲ្យមានគ្រោះថ្នាក់ដល់សន្តិសុខ និងដល់ពិធីចាត់ការឲ្យមានសណ្តាប់ធ្នាប់នៅសាលារៀន។

## ៦.៤ ឯកសាររបស់សិស្ស

ក្រសួងអប់រំរក្សានយោបាយមួយ ក្នុងការរក្សាទុកឯកសារផ្សេងៗរបស់សិស្សទាំងអស់។ លោកអ្នកអាចសុំពាក្យចម្លងនៃនយោបាយនេះ តាម www.phila.k12.pa.us ។

## ៦.៥ នយោបាយនៃការរក្សាទុកប៊ីពឺរ, ទូរស័ព្ទដៃ និងគ្រឿងទូរស័ព្ទផ្សេងៗ

ក្រសួងអប់រំមានចេញច្បាប់ហាមឃាត់ មិនឲ្យមានក្នុងខ្លួន ឬប្រើគ្រឿងអេឡិកត្រូនិក ផេជឺរ, នៅក្នុងបរិវេណសាលារៀន, នៅតាមសកម្មភាពរបស់សាលាផ្សេងៗ ហើយនិងនៅលើបឺស ឬរថយន្តផ្សេងៗផ្តល់ដោយក្រសួងអប់រំ។

ជាបន្ថែមទៀត, ក្រសួងមានធ្វើការហាមឃាត់ មិនឲ្យសិស្សប្រើទូរស័ព្ទដៃ នៅក្នុងបរិវេណសាលារៀន នៅពេលម៉ោងសិក្សា។ នាយកសាលារៀន មានអំណាចក្នុងការពន្យល់បកស្រាយពីបញ្ហានេះ ដែលអាចបណ្តាលឲ្យមានការរំខានដល់ការសិក្សា ព្រោះតែការប្រើទូរស័ព្ទមិនសមរម្យ។ សូមអានពាក្យចំលងពេញលេញអំពីនយោបាយនេះ នៅតាម www.phila.k12.pa.us។

## ៦.៦ នយោបាយនៃការបញ្ចេញបង្ហាញខ្លួនរបស់សិស្ស

សិស្សានុសិស្ស មានសិទ្ធិបញ្ចេញបង្ហាញខ្លួនឯង លើកលែងតែក្នុងករណីណាដែលការបង្ហាញជាគ្រឿងសម្ភារៈ ឬជាអត្ថន័យ មានការប៉ះទង្គិចទៅលើដំណើរការនៃការសិក្សា, មានការគំរាមកំហែងភ្លាមៗ ទៅលើសភាពសុខសាន្តរបស់សាលារៀន ឬសហគមន៍, មានជួយពន្យុះឲ្យមានសកម្មភាពខុសច្បាប់, ឬមានការរំខានដល់សិទ្ធិរបស់បុគ្គលណាម្នាក់។ បើលោកអ្នកចង់បានពាក្យចម្លងនៃនយោបាយនៃការបញ្ចេញបង្ហាញ ខ្លួនរបស់សិស្ស សុំអានតាម www.phila.k12.pa.us។ សិស្សទាំងអស់គួរតែ ហើយត្រូវតែអានឡើងវិញ នូវនយោបាយនៃការបញ្ចេញបង្ហាញខ្លួន។

# ផ្នែកទី៧. លេខទូរស័ព្ទ ដែលត្រូវយកមកប្រើជាញឹកញាប់

មន្ទីរផ្នែកការបន្តភ្ជាប់ និងការសិក្សាម្យ៉ាងទៀត ២១៥-៤០០-៤២២០
(Office of Transition and Alternative Education)

ការទៅរៀនទៀងទាត់ និងការឈប់ឥតច្បាប់ ២១៥-៤០០-៤២២០
(Attendance and Truancy)

ការស្វាគមន៍ត្រឡប់មកវិញ(Reti-Wrap) ២១៥-៨៧៥-៨០៧៥

វិន័យសំរាប់សិស្ស (Student Discipline) ២១៥-៤០០-៤២២០

មណ្ឌលជំនួយដល់គ្រួសារ ២១៥-៤០០-៤២២០

មន្ទីរចាត់តាំងសិស្ស (Office of Student Placement) ២១៥-៤០០-៤២៩០

មន្ទីរភាសា វប្បធម៌ និងសិល្បៈ ២១៥-៤០០-៤២៩០
(Office of Language, Cultures and the Arts)

មន្ទីរផ្នែកផ្សាយការពារសន្តិសុខដល់សាលារៀន ២១៥-៦៤៤-១២៧៧
(Office of Safe Schools Advocate)

មន្ទីរផ្នែកសន្តិសុខ និងបរិយាកាសនៅសាលារៀន ២១៥-៤០០-៤៧១០
(Office of School Climate and Safety)

មន្ទីរផ្នែកជំនួយពិសេស (Office of Specialized Services) ២១៥-៤០០-៤១៧០

ទូរស័ព្ទសំខាន់ សំរាប់មាតាបិតា (Parent Support Hotline) ២១៥-៤០០-៤០០០

លេខទូរស័ព្ទសំខាន់របស់ក្រសួងអប់រំផ្នែកសន្តិសុខ ២១៥-៤០០-៧២៣៣
(School District Safety Hotline)

## ការិយាល័យតំបន់

ការិយាល័យកណ្តាលក្រុង (Center City Regional Office) ២១៥-៣៥១-៣៨០៧

ការិយាល័យ CEO/EMO ២១៥-៦៨៤-៥១៣២

ការិយាល័យតំបន់ខាងកើត (East Regional Office) ២១៥-២៩១-៥៦៨៨

មន្ទីរប្រចាំតំបន់ខាងជើង (North Regional Office) ២១៥-៤៥៦-០៩៩៨

មន្ទីរប្រចាំតំបន់ឦសាន (Northeast Regional Office) ២១៥-២៨១-៥៩០៣

មន្ទីរប្រចាំតំបន់ពាយ័ព្យ (Northwest Regional Office) ២១៥-២៤៨-៦៦៨៤

មន្ទីរប្រចាំតំបន់ខាងត្បូង (South Regional Office) ២១៥-៣៥១-៧៤៤៥

មន្ទីរប្រចាំតំបន់ខាងលិច (West Regional Office) ២១៥-៤៧១-២២៧១

## ក្រសួងអប់រំនៃក្រុងហ្វីឡាដែលហ្វីយ៉ា
## ពាក្យសំរាប់រាយការណ៍អំពីសេចក្តីតវ៉ារបស់សិស្ស

ក្រសួងអប់រំនៃក្រុងហ្វីឡាដែលហ្វីយ៉ា រក្សានយោបាយមួយ ហាមមិនឲ្យមានការប្រកាន់និងបំពានយាយី (សូមអាននយោបាយលេខ១០២)។ ជនគ្រប់រូបត្រូវបានទទួលសេចក្តីគោរព ដោយភាពថ្លៃថ្នូរ។ ពាក្យនេះ គឺសំរាប់សិស្សទាំងឡាយណា ដែលជឿថា ខ្លួនត្រូវបានទទួលការប្រកាន់ ឬបំពានយាយី ពីសិស្ស ឬបុគ្គលិកសិក្សាណាម្នាក់។ សិស្សក៏អាចធ្វើសេចក្តីរាយការណ៍ អំពីរឿងដែលកើតឡើង តាមលេខទូរស័ព្ទទាក់ទងផ្ទាល់ (Bully Hotline), ទៅនាយកសាលា ឬអ្នកតំណាងប្រចាំក្រសួងអប់រំ។

ឈ្មោះអ្នកតវ៉ា______________________________ ថ្ងៃខែកំណើត______________

ឈ្មោះសាលា______________________________ ថ្នាក់ទី________ លេខបន្ទប់/advisory________

អាស័យដ្ឋានផ្ទះ______________________________ លេខទូរស័ព្ទផ្ទះ______________

ថ្ងៃទីនិងពេលម៉ោងរបស់រឿងដែលបានកើតឡើង______________________________

ឈ្មោះជនទាំងឡាយណា ដែលបានធ្វើការប្រកាន់ ឬបំពានយាយីដល់អ្នក______________________________

រាយបញ្ជី ឬរៀបរាប់ពីសាក្សីនៅពេលរឿងបានកើតឡើង______________________________

______________________________________________________________

តើរឿងនេះបានកើតឡើងនៅទីណា? ______________________________

រៀបរាប់ពីរឿងដែលបានកើតឡើង ឲ្យបានច្បាស់លាស់, រួមទាំងពាក្យសំដីនិយាយ (ដូចជា ការគំរាមកំហែង ទាមទារជាដើម); តើមានប៉ះពាល់ដល់រាងកាយឬទេ; តើមានប្រើកម្លាំងអ្វីឬទេ; តើអ្នកបានធ្វើអ្វីខ្លះ ដើម្បីចៀសវាងពីស្ថានការណ៍នោះ។ល។ (បើសិនជាចាំបាច់ សូមសរសេរបន្តនៅលើក្រដាសមួយទៀត)។______________________________

______________________________________________________________

______________________________________________________________

______________________________________________________________

ពាក្យតវ៉ានេះ បានធ្វើឡើង ដោយយោងទៅតាមជំនឿដ៏ស្មោះត្រង់របស់ខ្ញុំ ថាជនឈ្មោះ ______________________________ បានប្រព្រឹត្តិអំពើប្រកាន់ និង/ឬ បំពានយាយីមកលើខ្ញុំ។ ខ្ញុំ សូមបញ្ជាក់ថា ព័តមានដែលខ្ញុំបានចុះលើពាក្យនេះ ជាការពិត, ត្រឹមត្រូវ និងពេញលេញ ទៅតាមការយល់ដឹង និងជំនឿរបស់ខ្ញុំ។

______________________________ ______________

ហត្ថលេខាអ្នកតវ៉ា ថ្ងៃខែ

ទទួលដោយ______________________________ ______________

អ្នកតំណាងក្រសួងអប់រំនៃក្រុងហ្វីឡាដែលហ្វីយ៉ា និងមុខតំណែង ថ្ងៃខែ

ខ្ញុំ, អ្នកតវ៉ា, បានទទួលពាក្យចម្លងពេញលេញ ពីក្រសួងអប់រំ។

______________________________ ______________

ហត្ថលេខាអ្នកតវ៉ា ថ្ងៃខែ

**កំណត់ហេតុសំរាប់អ្នកចាត់ការ៖ សេចក្តីរាយការណ៍អំពីរឿងដ៏ធ្ងន់ធ្ងរមួយ ត្រូវបានបំពេញឲ្យបានហ្មត់ចត់។ ភ្ជាប់ពាក្យរាយការណ៍តវ៉ានេះ ទៅនឹងពាក្យចម្លងប្រចាំសាលាលេខ EH-31, ដែលជាសេចក្តីរាយការណ៍បន្តភ្ជាប់អំពីរឿងដែលបានកើតឡើង។**

ព័ត៌មាននៅក្នុងកូនសៀវភៅនេះ
អាចទទួលការផ្លាស់ប្តូរ
នៅក្នុងកម្លុងឆ្នាំសិក្សា។

បំណាក់ស្រាយចុងក្រោយ នឹងមានជូននៅតាមសម្ព័ន្ធអ៊ិនធឺណិត របស់ក្រសួងអប់រំ។

www.phila.k12.pa.us

បើចង់បានកូនសៀវភៅជាភាសាក្រៅពីភាសាអង់គ្លេស, សូមមេត្តាទាក់ទងទៅមន្ទីរទំនាក់ទំនង (Office of Communications) តាមលេខ២១៥-៤០០-៤០៤០។

ក្រសួងអប់រំទីក្រុងហ្វីឡាដែលហ្វីយ៉ា, ជាក្រសួងផ្តល់ការងារស្មើភាពមួយ, នឹងមិនប្រកាន់ក្នុងការផ្តល់ការងារ ឬកម្មវិធីសិក្សា ឬសកម្មភាពផ្សេងៗ ដោយយោងទៅលើ ពូជសាសន៍ លទ្ធិ ព៌ណសម្បុរ សញ្ជាតិដើម សាសនា បុព្វការីជន អាយុ ក្របខ័ណ្ឌរៀបការ ភាពតំរង់តាមភេទ (ដឹង ឬយល់ឃើញ) ការបញ្ចេញពីសញ្ញាណភាពខាងភេទ (ដឹង ឬយល់ឃើញ) ភេទ ពិការភាព សញ្ជាតិ ភាពជាពលរដ្ឋ សមាជិកក្រុមការពារកម្មករ ឬការចេះដឹងភាសាអង់គ្លេសតិចតួចទេ។ នយោបាយនៃការមិនប្រកាន់នេះ នឹងមានបន្តទៅគ្រប់ស្រទាប់ជាន់ថ្នាក់ ដែលមានសេចក្តីការពារទៅតាមច្បាប់។ ការផ្សាយព័ត៌មាននេះ នៅក្នុងឯកសារនេះ គឺបានធ្វើឡើង ឲ្យបានស្របទៅតាមច្បាប់របស់រដ្ឋ និងសហរដ្ឋ ដោយរួមទាំងច្បាប់ Title IX of the Education Amendments of 1972 and Sections 503 and 504 of the Rehabilitation Act of 1973។ សំនួរគ្រប់បែបយ៉ាង អាចសួរបានទៅ Reba Smallwood, Esq., Equal Opportunity Compliance Officer, 734 Schuykill Avenue, 1st Floor, Philadelphia, PA 19146, (215) 400-4380។

440 N. Broad Street
Philadelphia, PA 19130